ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# វិធីសាស្ត្រ
# ដែលមនុស្សមានជោគជ័យ
# ប្រើប្រាស់សម្រាប់ការគិត

បកប្រែ និងចងក្រងដោយ៖
ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការព្រឹទ្ធសភា

ខែមិថុនា ឆ្នាំ២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# អារម្ភកថា

ចាស់ៗរបស់យើងបានបន្សល់ទុកនូវពាក្យមួយឃ្លាដ៏មានតម្លៃថា " **គិតហើយចាំគូរ** "។

មួយឃ្លាដែលជាមរតកដ៏ថ្លៃថ្លានេះ បង្រៀនដល់កូនខ្មែរជំនាន់ក្រោយថា " មុននឹងធ្វើអ្វី សូមព្យាយាមគិតពិចារណាឱ្យបានហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយ មើលឆ្វេងមើលស្តាំ មើលមុខមើលក្រោយ មើលលើមើលក្រោម មើលថ្ងៃនេះមើលថ្ងៃស្អែក មើលជិតមើលឆ្ងាយ មើលធំមើលតូច គិតគាប់ចិត្តយើងក្រែងចិត្តគេ " ។

ពិភពលោកយើងសព្វថ្ងៃបានផ្តល់កំណើតដល់មនុស្សគ្រប់ៗគ្នាដោយស្មើភាព ។ តែមនុស្សលោកទោះបីជាស្មើគ្នាពីកំណើតក្តី នៅតែខុសគ្នានៅក្នុងដំណើរជីវិត ដូចជាខ្លះមានខ្លះក្រ ខ្លះមានមុខមានមាត់ក្នុងសង្គម ខ្លះអន់ថយ ខ្លះល្អខ្លះអាក្រក់ ខ្លះឧស្សាហ៍ខ្លះខ្ជិល ខ្លះពូកែខ្លះល្ងង់.....។ តើនេះមកពីកម្មផល ឬព្រេងវាសនាទេវតាចារមកអញ្ចឹងឬ ?

ពិនិត្យឱ្យគ្រប់សព្វ មនុស្សដែលជោគជ័យ និងមនុស្សដែលមិនជោគជ័យ ខុសគ្នាតែនៅត្រង់ការគិតប៉ុណ្ណោះ ។ គិតល្អ គិតត្រូវ គិតវែងឆ្ងាយ គិតដោយវិជ្ជមាន គិតដោយមានប្រយោជន៍ នោះហើយជាផ្លូវទៅកាន់ជោគជ័យ (ស្ថានសួគ៌) ។ គិតអាក្រក់ គិតខុស គិតខ្លីចង្អៀត គិតដោយអវិជ្ជមាន គិតអត់ប្រយោជន៍ នោះហើយជាផ្លូវទៅកាន់បរាជ័យ (ស្ថាននរក) ។

គ្រប់គ្នាសុទ្ធតែមានឱកាសដើម្បីជោគជ័យក្នុងជីវិត សំខាន់ត្រង់របៀបនៃការគិតរបស់ម្នាក់ៗ ។ គ្មាននរណាអាចនាំទុក្ខសោក ឬការសប្បាយមកឱ្យយើងបានទេ លុះត្រាតែខួរក្បាលយើងព្រមទទួលយកទុក្ខសោក ឬការសប្បាយនោះដោយខ្លួនឯង ។

ខ្ញុំមានបំណងបកប្រែនិងចងក្រងឯកសារនេះ ដើម្បីឱ្យបានជាប្រយោជន៍ដល់អ្នកដឹកនាំ និងមន្ត្រីគ្រប់អង្គភាពក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាយើង ។

ទាំងអស់គ្នានៅមានអនាគតវែងឆ្ងាយទៅមុខ មានឱកាស សក្តានុពល និងបញ្ញាញាណគ្រប់

គ្រាន់ដើម្បីជោគជ័យ ។ អ្វីដែលជាចម្បងនោះគឺការគិតរបស់ម្នាក់ៗ ។ អាទិទេព មេឃ ដី និងពេលវេលា ពុំអាចជួយនរណាម្នាក់បានឡើយ ប្រសិនបើការគិតរបស់ម្នាក់ៗនៅតែចង្អៀត អាត្មានិយម មើលមិនផុតពីចុងច្រមុះ.....។ល។

ការគិតពុំបានរើសអើងតួអង្គអ្នកគិតឡើយ មិនថាអ្នកមានអ្នកក្រ អ្នកមានឋានៈឬអត់ឋានៈ អ្នកពិការឬអ្នកធម្មតាក្តី ។

តាមរយៈការគិតរបស់អ្នក អ្នកអាចបង្កើតស្ថានសួគ៌ និងជោគជ័យដ៏ត្រចះត្រចង់នៅលើផែនដីបាន ។ ចំពោះមុខសូមនាំគ្នារៀនគិតដើម្បីចេះគិតបានល្អ ត្រឹមត្រូវ វែងឆ្ងាយ វិជ្ជមាន និងមានប្រយោជន៍ ។

ការគិតដ៏ត្រឹមត្រូវមួយពុំមែនជារឿងសាមញ្ញទេ ព្រោះត្រូវមានទម្លាប់ចេះត្រិះរិះ ពិចារណា វិភាគ និងវាយតម្លៃឲ្យបាន ÷

- ត្រូវពេលវេលា (កាលៈទេសៈ, ចេះផ្សារភ្ជាប់បច្ចុប្បន្នកាលជាមួយអតីតកាល ដើម្បីអនាគតកាល)
- ត្រូវបរិយាកាស (ស្ថានការណ៍)
- ត្រូវទីកន្លែង (ទីតាំង)
- ត្រូវបញ្ហា (បច្ចុប្បន្នភាព តម្រូវការ)
- ត្រូវបុគ្គល (ឋានៈក្នុងសង្គម)
- ត្រូវទំនាក់ទំនង (សម្ព័ន្ធភាពកម្លាំង)
- ត្រូវទស្សនវិស័យ និងចក្ខុវិស័យ

បទពិសោធន៍ទាំងឡាយ គឺជាមេរៀនដ៏សំខាន់សម្រាប់ជីវិត ។ ការចេះគិតតាមប្រភេទនៃការគិតទាំង ១១ប្រភេទ គឺជាផែនទីបង្ហាញផ្លូវឆ្ពោះទៅកាន់ជោគជ័យ ។

ភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១



**អ៊ុំ សារិទ្ធ**

**អគ្គលេខាធិការព្រឹទ្ធសភា**

# បញ្ជីមាតិកា

ទំព័រ


**១_សេចក្តីផ្តើម**......................................................................១

**២_តើហេតុអ្វីបានជាអ្នកត្រូវផ្លាស់ប្តូរការគិត?**..........................................២

២.១- ពុំមែនដោយស្វ័យប្រវត្តិ..........................................................២

២.២-ជារឿងដ៏ពិបាក....................................................................២

២.៣-មានតម្លៃស្មើនឹងការវិនិយោគ....................................................២

**៣_តើត្រូវក្លាយជាអ្នកពូកែគិតតាមរបៀបណា?**..........................................៣

៣.១-ដាក់ខ្លួនឯងទទួលយកការបំពេញបន្ថែមដ៏ល្អ.......................................៣

៣.២-ដាក់ខ្លួនឯងនៅជិតអ្នកពូកែគិត.....................................................៣

៣.៣-ជ្រើសរើសយកមកគិតនូវគំនិតល្អៗ.................................................៣

៣.៤-ប្រព្រឹត្តតាមគំនិតល្អរបស់អ្នក.......................................................៤

៣.៥-សូមប្រើការរំភើបចិត្តរបស់អ្នកដើម្បីបង្កើតគំនិតល្អផ្សេងទៀត....................៤

៣.៦-ធ្វើដំណើរការសារចុះសារឡើង....................................................៤

**៤_ដាក់ខ្លួនឯងនៅកន្លែងដ៏ត្រឹមត្រូវដើម្បីគិត**..........................................៥

៤.១-ស្វែងរកកន្លែងដើម្បីគិត...........................................................៥

៤.២-ស្វែងរកកន្លែងដើម្បីរចនាគំនិត...................................................៥

៤.៣-ស្វែងរកកន្លែងដើម្បីពុះលំអិតគំនិត...............................................៦

៤.៤-ស្វែងរកកន្លែងដើម្បីចុះចតគំនិត...................................................៦

**៥_ស្វែងរកកន្លែងដើម្បីបង្ហោះគំនិត**.....................................................៧

**៦_រូបភាពរបស់អ្នកពូកែគិត**..............................................................៨


## ជំពូកទី១

## តើមនុស្សដែលមានជោគជ័យគិតយ៉ាងដូចម្តេច?


**១_បណ្តុះការគិតដល់រូបភាពធំ**..........................................................១០

១.១-រៀនជាបន្តបន្ទាប់...... ១១

១.២-ស្តាប់ដោយយកចិត្តទុកដាក់...... ១១

១.៣-សម្លឹងមើលឱ្យធំទូលាយ...... ១២

១.៤-រស់នៅដោយពេញលេញ...... ១៣

**២-ហេតុអ្វីបានជាអ្នកត្រូវទទួលផលប្រយោជន៍ពីការគិតដល់រូបភាពធំ...... ១៣**

២.១-ការគិតដល់រូបភាពធំផ្តល់ឱកាសឱ្យអ្នកដឹកនាំ...... ១៤

២.២-ការគិតដល់រូបភាពធំថែរក្សារូបអ្នកឱ្យទៅដល់គោលដៅ...... ១៥

២.៣-ការគិតដល់រូបភាពធំនាំឱ្យអ្នកមើលឃើញនូវអ្វីដែលអ្នកដទៃមើលឃើញ...... ១៥

២.៤-ការគិតដល់រូបភាពធំនឹងបង្កើនជម្រុញការងារជាក្រុម...... ១៦

២.៥-ការគិតដល់រូបភាពធំថែរក្សារូបអ្នកឱ្យដើរទាន់សភាពការណ៍...... ១៦

២.៦-ការគិតដល់រូបភាពធំជួយអ្នកឱ្យដើរចូលតំបន់ដែលពុំធ្លាប់ចូល...... ១៦

**៣-តើត្រូវធ្វើដូចម្តេចដើម្បីបានទទួលផលពីការគិតដល់រូបភាពធំ...... ១៧**

៣.១-កុំស្វះស្វែងរកភាពច្បាស់លាស់...... ១៧

៣.២-រៀនសូត្រពីបទពិសោធន៍នីមួយៗ...... ១៧

៣.៣-ដឹងជម្រៅរឿងរ៉ាវពីមនុស្សប្លែកៗគ្នា...... ១៨

៣.៤-អនុញ្ញាតឱ្យខ្លួនអ្នកពង្រីកពិភពរបស់ខ្លួន...... ១៨


## <u>ជំពូកទី២</u>

## ប្រឡូកនឹងការគិតដោយប្រមូលផ្តុំ


**១-ការគិតដោយប្រមូលផ្តុំនាំឱ្យមានថាមពលឆ្ពោះទៅកាន់គោលបំណងដែលចង់បាន...... ២០**

**២-ការគិតដោយប្រមូលផ្តុំផ្តល់ពេលវេលាឱ្យគំនិតអភិវឌ្ឍន៍...... ២១**

**៣-ការគិតដោយប្រមូលផ្តុំនាំឱ្យមានភាពច្បាស់លាស់ចំពោះគោលដៅ...... ២១**

**៤-ការគិតដោយប្រមូលផ្តុំនឹងនាំអ្នកទៅកាន់គំនិតថ្មី...... ២២**

**តើកន្លែងណាខ្លះដែលត្រូវប្រមូលផ្តុំការគិតរបស់អ្នក...... ២២**

**១-កំណត់អាទិភាពរបស់អ្នក...... ២២**

២.រកឱ្យឃើញនូវចំណុចខ្សោយរបស់អ្នក................................................................២៣
៣.ពង្រីកសុបិនរបស់អ្នក.................................................................................២៤
តើធ្វើយ៉ាងដូចម្តេចដើម្បីឱ្យខ្លួនអ្នកគិតដោយប្រមូលផ្តុំបាន......................................២៥
១.ទម្លាក់ចោលការលេងសើច..........................................................................២៥
២.ត្រូវប្រើពេលវេលាសម្រាប់ការគិតដោយប្រមូលផ្តុំ...................................................២៦
៣.ថែរក្សារបៀបរារៈនៃការយកចិត្តទុកដាក់ចំពោះមុខអ្នក.............................................២៦
៤.កំណត់គោលដៅ.......................................................................................២៦
៥.ចោទសួរអំពីទន្លេនភាពរបស់អ្នក.....................................................................២៧
តើអ្វីដែលអ្នកត្រូវជម្រុះចោលដើម្បីឡើងបានកាន់តែខ្ពស់........................................ ២៨

## ជំពូកទី៣

## ប្រមូលការគិតដោយច្នៃប្រឌិត

១.លក្ខណៈវិនិច្ឆ័យរបស់អ្នកគិតដោយច្នៃប្រឌិត.........................................................៣១
- អ្នកគិតដោយច្នៃប្រឌិតតែងផ្តល់តម្លៃដល់គំនិតទាំងឡាយ.............................................៣១
- អ្នកគិតដោយច្នៃប្រឌិតស្វះស្វែងរកជម្រើស..............................................................៣១
- អ្នកគិតដោយច្នៃប្រឌិតទទួលយកភាពស្រពិចស្រពិល...................................................៣២
- អ្នកគិតដោយច្នៃប្រឌិតអបអរសាទរនូវភាពប្លែកមិនធម្មតា..............................................៣២
- អ្នកគិតដោយច្នៃប្រឌិតភ្ជាប់ទៅកន្លែងដែលពុំធ្លាប់តភ្ជាប់.............................................៣២
- អ្នកគិតដោយច្នៃប្រឌិតពុំភ័យខ្លាចចំពោះបរាជ័យ......................................................៣៣
តើហេតុដូចម្តេចបានជាអ្នកត្រូវរកឱ្យឃើញនូវក្តីសប្បាយរីករាយនៃការគិតដោយ
ច្នៃប្រឌិត...................................................................................................៣៤
១.ការគិតដោយច្នៃប្រឌិតបង្កើតតម្លៃដល់អ្វីៗទាំងអស់...................................................៣៤
២.ការច្នៃប្រឌិតគួបផ្សំផ្តុំ...................................................................................៣៤
៣.ការគិតដោយច្នៃប្រឌិតទាក់ទាញមនុស្សឱ្យមករកអ្នក និងគំនិតរបស់អ្នក..........................៣៥
៤.ការគិតដោយច្នៃប្រឌិតជួយឱ្យអ្នករៀនបានច្រើន.......................................................៣៥

៥-ការគិតដោយច្នៃប្រឌិត ប្រឈមនឹងការរក្សាស្ថានភាពដដែល............................ ៣៥
តើរកឃើញក្តីរីករាយនៃការគិតដោយច្នៃប្រឌិតយ៉ាងដូចម្តេច............................ ៣៦
១-ជម្រុះចោលនូវពួកឃាតករនៃការច្នៃប្រឌិត............................ ៣៦
២-គិតដោយច្នៃប្រឌិត ដោយការសាកសួរសំណួរដ៏ត្រឹមត្រូវ............................ ៣៧
៣-បង្កើតនូវបរិស្ថាននៃការច្នៃប្រឌិត............................ ៣៨
- ឱបក្រសោបអ្នកដែលច្នៃប្រឌិត............................ ៣៩
- យកចិត្តទុកដាក់លើការកែប្រែថ្មី ដោយពុំត្រឹមតែការបង្កើតថ្មី............................ ៣៩
- មានបំណងប្រាថ្នាអនុញ្ញាតឱ្យមនុស្សដើរចេញពីខ្សែបន្ទាត់............................ ៤០
- វាយតម្លៃដល់អំណាចនៃក្តីប្រម័យ............................ ៤០
- ចំណាយពេលវេលាជាមួយមនុស្សច្នៃប្រឌិតដទៃទៀត............................ ៤១
៥-ចេញពីប្រអប់របស់អ្នក ............................ ៤១

## <u>ជំពូកទី៤</u>

## ការប្រើប្រាស់ការគិតដោយប្រាកដនិយម

ការពិនិត្យមើលអំពីការពិត............................ ៤៣
១-ហេតុអ្វីអ្នកត្រូវទទួលស្គាល់សារសំខាន់នៃការគិតដោយប្រាកដនិយម............................ ៤៣
១.១- ការគិតដោយប្រាកដនិយមធ្វើឱ្យហានិភ័យតូច-ធំកើតមានជាអប្បបរមា............................ ៤៣
១.២- ការគិតដោយប្រាកដនិយមផ្តល់ឱ្យអ្នកនូវគោលដៅ និងផែនការនៃល្បែង............................ ៤៤
១.៣- ការគិតដោយប្រាកដនិយមជាកត្តាលីករនៃការផ្លាស់ប្តូរ............................ ៤៤
១.៤- ការគិតដោយប្រាកដនិយមផ្តល់នូវសន្តិសុខ............................ ៤៥
១.៥- ការគិតដោយប្រាកដនិយមផ្តល់ឱ្យអ្នកនូវភាពគួរជឿជាក់............................ ៤៥
១.៦- ការគិតដោយប្រាកដនិយមផ្តល់នូវគ្រឹះដើម្បីកសាងឡើង............................ ៤៦
១.៧- ការគិតដោយប្រាកដនិយមគឺជាមិត្តសម្រាប់អ្នកណាដែលជួបវិបត្តិ............................ ៤៦
១.៨- ការគិតដោយប្រាកដនិយមនាំសុបិនទៅកាន់ផ្លែផ្កា............................ ៤៧
២-តើទទួលស្គាល់សារសំខាន់នៃការគិតដោយប្រាកដនិយមយ៉ាងដូចម្តេច............................ ៤៧

២.១- អភិវឌ្ឍការឱ្យតម្លៃទៅលើការពិត......................................................៤៧
២.២- ធ្វើកិច្ចការផ្ទះរបស់អ្នក......................................................................៤៨
២.៣- គិតតាមរយៈការគាំទ្រ និងការប្រឆាំង......................................................៤៩
២.៤- មើលឃើញសេណារីយ៉ូនៃករណីអាក្រក់បំផុត.............................................៤៩
២.៥- តម្រង់ជួរការគិតរបស់អ្នកជាមួយធនធានរបស់អ្នក......................................៥០
**៣-មូលមហាធំ កំពូលវិមានមហាធំ មហាសន្តិសុខ**..............................................៥១

## ជំពូកទី៥

## សូមប្រើប្រាស់ការគិតជាយុទ្ធសាស្ត្រ

**១-ធ្វើផែនការសម្រាប់ជីវិតអ្នក ធ្វើឱ្យផែនការឱ្យរស់រានសម្រាប់ជីវិតអ្នក**..................៥២
**២-ហេតុដូចម្តេចបានជាអ្នកគួរបញ្ចេញអំណាចនៃការគិតជាយុទ្ធសាស្ត្រ**....................៥២
២.១- ការគិតជាយុទ្ធសាស្ត្រធ្វើឱ្យការលំបាកក្លាយជាសាមញ្ញ...................................៥៣
២.២- ការគិតជាយុទ្ធសាស្ត្រតម្រូវឱ្យអ្នកចោទសួរនូវសំណួរដ៏ត្រឹមត្រូវ..........................៥៣
២.៣- ការគិតជាយុទ្ធសាស្ត្របណ្តាលឱ្យត្រូវប្រែប្រួលសេចក្តីត្រូវការ...........................៥៤
២.៤- ការគិតជាយុទ្ធសាស្ត្ររៀបចំខ្លួនអ្នកនាថ្ងៃនេះ ដើម្បីភាពមិនច្បាស់លាស់នាថ្ងៃស្អែក......៥៥
២.៥- ការគិតជាយុទ្ធសាស្ត្រកាត់បន្ថយខ្ទង់នៃការភ័ន្តច្រឡំ......................................៥៥
២.៦- ការគិតជាយុទ្ធសាស្ត្រផ្តល់ឱ្យអ្នកនូវឥទ្ធិពលទៅលើអ្នកដទៃ..............................៥៦
**៣-តើត្រូវបញ្ចេញអំណាចនៃការគិតជាយុទ្ធសាស្ត្រយ៉ាងដូចម្តេច?**..............................៥៦
៣.១- បំបែកបញ្ហាជាចំរៀក.......................................................................៥៦
៣.២- សូមសួរសំណួរ Why មុន How ...........................................................៥៧
៣.៣- សូមកំណត់បញ្ហាជាក់ស្តែង និងគោលដៅ..................................................៥៨
៣.៤- ត្រួតពិនិត្យមើលធនធានរបស់អ្នក..........................................................៥៨
៣.៥- អភិវឌ្ឍន៍ផែនការរបស់អ្នក..................................................................៥៩
៣.៦- ដាក់មនុស្សឱ្យត្រូវនៅចំកន្លែងត្រូវ.........................................................៥៩
៣.៧- សូមថែរក្សាធ្វើដំណើរការដដែល............................................................៦០

## ជំពូកទី៦

## សូមរកការគិតអំពីលទ្ធភាព


១-ការគិតដល់លទ្ធភាពបង្កើនលទ្ធភាពរបស់អ្នក............ ៦១

២-ការគិតអំពីលទ្ធភាពទាក់ទាញឱកាស និងមនុស្សឱ្យមករកអ្នក............ ៦១

៣-ការគិតដល់លទ្ធភាពបង្កើនលទ្ធភាពដទៃទៀត............ ៦១

៤-ការគិតដល់លទ្ធភាពអនុគ្រោះឱ្យអ្នកសុបិនឃើញសុបិនកាន់តែធំទៅៗ............ ៦២

៥-ការគិតដល់លទ្ធភាពធ្វើឱ្យមានលទ្ធភាពដើម្បីខ្ពស់ឡើងជាងធម្មតា............ ៦២

៦-ការគិតដល់លទ្ធភាពផ្តល់ឱ្យអ្នកនូវថាមពល............ ៦២

៧-ការគិតដល់លទ្ធភាពថែរក្សាអ្នកមិនឱ្យចុះចាញ់............ ៦៣

តើត្រូវមានអារម្មណ៍ទទួលបានថាមពលពីការគិតអំពីលទ្ធភាពយ៉ាងដូចម្តេច............ ៦៣

១-ឈប់ផ្តោតលើអលទ្ធភាព............ ៦៤

២-ស្ថិតនៅឱ្យឆ្ងាយពីអ្នកឯកទេស............ ៦៤

៣-សម្លឹងមើលលទ្ធភាពនៅក្នុងគ្រប់ស្ថានការណ៍ទាំងអស់............ ៦៥

៤-មានសុបិន្តកាន់តែធំឡើង............ ៦៥

៥-ចោទសួរសំណួរអំពីស្ថានភាពដដែល............ ៦៦

៦-រកមៀនសូត្រពីសមិទ្ធករដ៏ពូកែៗ............ ៦៧


## ជំពូកទី៧

## សូមរៀនអំពីការគិតដោយត្រិះរិះ (សញ្ជឹងគិត)


១-ការគិតដោយត្រិះរិះផ្តល់ឱ្យអ្នកនូវទស្សនវិស័យពិតប្រាកដ............ ៦៨

២-ការគិតដោយត្រិះរិះផ្តល់ភាពសុចរិតខាងអារម្មណ៍ដល់ជីវិតនៃគំនិតរបស់អ្នក............ ៦៩

៣-ការគិតដោយត្រិះរិះបង្កើនការជឿទុកចិត្តរបស់អ្នកនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត. ៧០

៤-ការគិតដោយត្រិះរិះបំភ្លឺដល់រូបភាពធំ............ ៧០

៥-ការគិតដោយត្រិះរិះចាប់យកនូវបទពិសោធន៍ល្អៗ ហើយធ្វើឱ្យបទពិសោធន៍
នោះក្លាយជាបទពិសោធន៍មានតម្លៃ............ ៧១

**តើត្រូវឱបក្រសោបមេរៀននៃការគិតដោយត្រិះរិះយ៉ាងដូចម្តេច?**.......................................៧២
១. ធ្វើឱ្យខ្លួនអ្នកមានស្មារតីមូល (កុំបែកកម្មដ្ឋាន).......................................៧៣
២. ពិនិត្យមើលឡើងវិញជារឿយៗនូវកម្មវិធី ឬកំណត់ត្រារបស់អ្នក.......................................៧៣
៣. សូមសាកសួរនូវសំណួរដ៏ត្រឹមត្រូវ.......................................៧៤
៤. ផ្សារភ្ជាប់ការរៀនរបស់អ្នកតាមរយៈអំពើ.......................................៧៦

## ជំពូកទី៨

## សាកសួរសំណួរអំពីការគិតរបស់មហាជន

១. ការគិតរបស់មហាជនពេលខ្លះមានន័យថាពុំមែនគិតឡើយ.......................................៧៩
២. ការគិតរបស់មហាជនផ្តល់នូវសេចក្តីសង្ឃឹមខុស.......................................៧៩
៣. ការគិតរបស់មហាជនគឺយឺតយ៉ាវ ដើម្បីឱបក្រសោបយកការផ្លាស់ប្តូរ.......................................៨១
៤. ការគិតដោយមហាជននាំមកតែលទ្ធភាពធម្មតា.......................................៨១
**តើត្រូវលើកសំណួរសួរអំពីការយល់ព្រមទទួលយកនូវការគិតរបស់មហាជន យ៉ាងដូចម្តេច?**.......................................៨២
១. គិតមុននឹងអ្នកដើរតាម.......................................៨២
២. វាយតម្លៃដល់ការគិតដោយខុសប្លែកពីការគិតរបស់អ្នកផ្ទាល់.......................................៨៣
៣. សូមលើកសំណួរជាបន្តបន្ទាប់អំពីការគិតរបស់ខ្លួនអ្នកផ្ទាល់.......................................៨៤
៤. សាកល្បងរឿងថ្មីតាមរបៀបថ្មី.......................................៨៤
៥. សូមទម្លាប់ដើម្បីមិនសុខស្រួល.......................................៨៥

## ជំពូកទី៩

## ទទួលផលប្រយោជន៍ពីការគិតដោយចែករំលែក

១. ការគិតដោយចែករំលែកលឿនជាងការគិតតែម្នាក់ឯង.......................................៨៧
២. ការគិតដោយចែករំលែកគឺមានលក្ខណៈកែប្រែថ្មីច្រើនជាងការគិតតែម្នាក់ឯង.......................................៨៨
៣. ការគិតដោយចែករំលែកនាំមកនូវភាពចាស់ទុំជាងការគិតតែម្នាក់ឯង.......................................៨៧

៤-ការគិតដោយចែករំលែកខ្លាំងជាងការគិតតែម្នាក់ឯង..............................................៨៩
៥-ការគិតដោយចែករំលែកផ្តល់ត្រឡប់មកវិញនូវតម្លៃធំជាងការគិតតែម្នាក់ឯង......... ៨៩
៦-ការគិតដោយចែករំលែកគឺជាវិធីតែមួយគត់ដើម្បីទទួលបានការគិតដ៏ល្អប្រសើរ........៨៩
**តើត្រូវលើកទឹកចិត្តដល់ការចូលរួមនៃការគិតដោយចែករំលែកយ៉ាងដូចម្តេច?**.................. ៩០
១-ផ្តល់តម្លៃដល់ការគិតរបស់អ្នកដទៃ.....................................................................៩០
២-ដកថយចេញពីការប្រកួតប្រជែងទៅកាន់សហប្រតិបត្តិការ.........................................៩២
៣-សូមមានរបៀបវារៈមួយកាលណាអ្នកជួប............................................................ ៩២
៤-ស្វែងរកមនុស្សត្រឹមត្រូវនៅជុំវិញគេ...................................................................... ៩២
៥-ទូទាត់ឱ្យបានល្អរវាងអ្នកគិតដ៏ពូកែ និងសហការី.................................................... ៩៤

## ជំពូកទី១០

## អនុវត្តនូវការគិតដោយមិនអាត្មានិយម

១-ការគិតដោយមិនអាត្មានិយមនាំឱ្យសម្រេចការបំពេញចិត្តផ្ទាល់ខ្លួន........................ ៩៥
២-ការគិតដោយមិនអាត្មានិយមផ្តល់តម្លៃដល់អ្នកដទៃ............................................ ៩៦
៣-ការគិតដោយមិនអាត្មានិយមលើកទឹកចិត្តដល់គុណធម៌ដទៃទៀត.........................៩៧
៤-ការគិតដោយមិនអាត្មានិយមបង្កើនគុណភាពនៃជីវិត...........................................៩៧
៥-ការគិតដោយមិនអាត្មានិយមធ្វើឱ្យផ្លែកអ្វីមួយរបស់អ្នកធំជាងអ្នក.......................... ៩៨
៦-ការគិតដោយមិនអាត្មានិយមបង្កើននូវកេរ្តិ៍ដំណែលជាមរតក.................................៩៨
**តើត្រូវពិសោធន៍អំពីការពេញចិត្តចំពោះការគិតដោយមិនអាត្មានិយមយ៉ាងដូចម្តេច?**......... ៩៩
១-ដាក់អ្នកដទៃជាទី១..........................................................................................៩៩
២-ដាក់ខ្លួនឯងទៅក្នុងស្ថានការណ៍ដែលមនុស្សមានតម្រូវការ.....................................១០០
៣-ផ្តល់ដោយស្ងប់ស្ងាត់ ឬជាអនាមិក....................................................................១០០
៤-វិនិយោគដោយមានឆន្ទៈទៅក្នុងមនុស្ស.............................................................១០១
៥-សូមត្រួតពិនិត្យមើលនូវហេតុផលរបស់អ្នក........................................................ ១០២

## ជំពូកទី១១

## សូមផ្តោតលើការគិតឈរលើមូលដ្ឋានគ្រឹះ


មូលដ្ឋានគ្រឹះនៃការមិនរកផលចំណេញ........................................................................១០៤

តើហេតុដូចម្តេចបានយើងត្រូវរីករាយជាមួយនឹងលទ្ធផលនៃការគិតឈរលើមូលដ្ឋានគ្រឹះ..... ១០៤

១-ការគិតឈរលើមូលដ្ឋានគ្រឹះផ្តល់នូវភាពច្បាស់លាស់ជាក់ស្តែង........................................ ១០៥

២-ការគិតឈរលើមូលដ្ឋានគ្រឹះជួយឱ្យអ្នកវាយតម្លៃបានអំពីស្ថានការណ៍នីមួយៗ......... ១០៦

៣-ការគិតឈរលើមូលដ្ឋានគ្រឹះជួយអ្នកឱ្យធ្វើសេចក្តីសម្រេចដ៏ល្អប្រសើរបំផុត............. ១០៦

៤-ការគិតឈរលើមូលដ្ឋានគ្រឹះបង្កើតឡើងនូវសីលធម៌ខ្ពស់........................................ ១០៦

៥-ការគិតឈរលើមូលដ្ឋានគ្រឹះធានានូវអនាគតរបស់អ្នក...........................................១០៦

❶-សូមកំណត់អំពីមូលដ្ឋានគ្រឹះជាក់ស្តែង........................................................ ១០៧

❷-សូមដាក់មូលដ្ឋានគ្រឹះជាចំណុចគន្លឹះ.........................................................១០៨

❸-បង្កើតផែនការយុទ្ធសាស្ត្រដើម្បីសម្រេចមូលដ្ឋានគ្រឹះ.......................................... ១០៩

❹-សូមតម្រង់ជួរសមាជិកក្រុមការងារជាមួយនឹងមូលដ្ឋានគ្រឹះ......................................១០៩

❺-ប្រកាន់ជាប់ស្អិតជាមួយប្រព័ន្ធតែមួយ និងតាមដានលទ្ធផលជាប់ជាបន្តបន្ទាប់............................................................................................................១១០

គំនិតមួយចុងក្រោយ................................................................................................ ១១២

១-អ្វីៗចាប់ផ្តើមជាមួយការគិត.................................................................................... ១១២

២-អ្វីដែលយើងគិតវាកំណត់ថាតើយើងជានរណា តើយើងជានរណាវាកំណត់នូវអ្វីដែលយើងធ្វើ................................................................................................... ១១២

៣-គំនិតរបស់យើងកំណត់នូវជោគវាសនារបស់យើង ជោគវាសនារបស់យើងកំណត់នូវមរតករបស់យើង......................................................................................... ១១២

៤-មនុស្សដែលធ្វើដំណើរទៅកាន់កន្លែងខ្ពស់គិតខុសប្លែកពីអ្នកដទៃ.................................. ១១២

៥-យើងអាចផ្លាស់ប្តូរនូវវិធីដែលយើងគិត................................................................ ១១២

# តើមនុស្សដែលមានជោគជ័យគិតយ៉ាងដូចម្ដេច?

## ១.សេចក្ដីផ្ដើម

- អ្នកពូកែគិត ÷
  - ✱ អាចមានការងារធ្វើជានិច្ច នរណាដែលដឹងថាត្រូវធ្វើយ៉ាងដូចម្ដេច (Who knows **How**)
  - ✱ អាចក្លាយជាមេ (Boss) នរណាដែលដឹងថា ពីព្រោះអ្វី (Who knows **Why**)
- អ្នកពូកែគិតជាអ្នកមានជោគជ័យ ÷
  - ✱ ដោះស្រាយបញ្ហា
  - ✱ ពុំដែលខ្វះយោបល់ដែលអាចកសាងស្ថាប័ន
  - ✱ មានក្ដីសង្ឃឹមចំពោះអនាគតកាន់តែល្អប្រសើរ
  - ✱ ពុំដែលចាញ់បោកមនុស្សពុំបានការដែលចង់ចម្រាញ់ផលប្រយោជន៍ ឬធ្វើឲ្យគេអស់សង្ឃឹម
  - ✱ អាចត្រួតត្រាខ្លួនឯងបានមិនថាស្ថិតក្រោមអ្នកផ្ដាច់ការ ឬក៏ស្ថិតនៅកាលៈទេសៈដ៏ពិបាកយ៉ាងណាក្ដី ។
- អ្វីដែលបែងចែកមនុស្សដែលមានជោគជ័យ និងមនុស្សដែលបរាជ័យ ÷ តើគេគិតយ៉ាងដូចម្ដេច ?
- អ្វីដែលមនុស្សមានជោគជ័យគិតយ៉ាងដូចម្ដេច អាចរៀនបាន ។
- ប្រសិនបើអ្នកផ្លាស់ប្ដូរ *(ការគិតរបស់អ្នក)* អ្នកអាចផ្លាស់ប្ដូរជីវិតរបស់អ្នកបាន ។

✕

✕ ✕

## ២_តើហេតុអ្វីបានជាអ្នកត្រូវផ្លាស់ប្តូរការគិត?

+ ការគិតដោយល្អ អាចជួយអ្នកច្រើនយ៉ាង ÷

* បង្កើនចំណូល
* ដោះស្រាយបញ្ហា
* បង្កើតឱកាស
* នាំអ្នកទៅដល់កំរិតថ្មីទាំងបុគ្គលខ្លួនឯង ទាំងវិជ្ជាជីវៈ
* ផ្លាស់ប្តូរជីវិតអ្នក

+ ការផ្លាស់ប្តូរការគិត

### ២.១ - ពុំមែនដោយស្វ័យប្រវត្តិ

- លើបចង់បានគំនិតល្អ អ្នកត្រូវតែស្វែងរកវា
- បើអ្នកចង់ក្លាយជាអ្នកគិតដ៏ពូកែ អ្នកចាំបាច់ត្រូវរៀន
  * ពេលអ្នកចាប់ផ្តើមក្លាយជាអ្នកពូកែគិត គំនិតល្អៗតែងតែរត់មករកអ្នកជានិច្ច
  * បរិមាណនៃការគិតដោយល្អចំណុះត្រង់ថា តើអ្នកប្រឹងប្រែកប៉ុណ្ណានឹងការគិត

### ២.២ - ជារឿងដ៏ពិបាក

- អ្នកដែលនិយាយថាការគិតមិនពិបាក គឺអ្នកនោះពុំដែលធ្លាប់គិតទេ
- លោក Albert Einstein និយាយថា ÷ Thinking is hard word; that's why so few do it.

### ២.៣ - មានតម្លៃស្មើនឹងការវិនិយោគ

- អ្នកប្រាជ្ញនិយាយថា "More gold has been mined from the thoughts of man than has ever been taken from the earth"
- កាលណាអ្នកប្រើពេលវេលាដើម្បីរៀនផ្លាស់ប្តូរការគិត ហើយបានក្លាយជាអ្នកពូកែគិត នោះហើយគឺជាការវិនិយោគសម្រាប់ខ្លួនអ្នក : វាំមាសនឹងផុសឡើងជាកំណាប់

✱ ទីផ្សារហ៊ុនអាចដួលរលំ, ការវិនិយោគលើអចលនទ្រព្យអាចរីករវដួរចត់

✱ តែសមត្ថភាពគិតដោយល្អ គឺជាកែវពេជ្រដែលយកពុំអស់

## ៣.តើត្រូវក្លាយជាអ្នកពូកែគិតតាមរបៀបណា?

~ យើងសុទ្ធតែចង់ក្លាយជាអ្នកពូកែគិត (ថ្ងៃស្អែកឲ្យល្អជាងថ្ងៃនេះ)

~ ត្រូវគិតថានេះគឺជាដំណើរមួយជាប្រចាំ (អត់ឈប់ឈរ) ដែលលើកតម្កើងការគិតរបស់អ្នក

~ តើត្រូវធ្វើយ៉ាងដូចម្តេច ?

### ៣.១ ~ ដាក់ខ្លួនឯងទទួលយកការបំពេញបន្ថែមដ៏ល្អ (Good input)

~ អ្នកពូកែគិតតែងតែជាអ្នកប្រមូលគំនិត

~ គេស្វែងរកអ្វីៗដើម្បីឲ្យដំណើរការគិតចាប់ផ្តើម ពីព្រោះអ្វីដែលបញ្ចូលតែងតែមានឥទ្ធិពលដល់អ្វីដែលត្រូវបញ្ចេញ

~ ត្រូវអានសៀវភៅ ទស្សនាវដ្តី កាសែត ស្តាប់វិទ្យុ មើលទូរទស្សន៍ និងចំណាយពេលវេលាជាមួយអ្នកពូកែគិត

~ បើមានអ្វីដែលអ្នកចាប់អារម្មណ៍ (ជាគំនិតអ្នកដទៃ ឬគ្រាប់ពូជនៃគំនិតដែលអ្នកមានខ្លួនឯង) សូមកត់ត្រាសរសេរទុកនៅកន្លែងណាមួយដែលអ្នកចូលចិត្ត ដើម្បីជំរុញការគិតរបស់អ្នក

### ៣.២ ~ ដាក់ខ្លួនឯងទៅជិតអ្នកពូកែគិត

~ សុភាសិតបរទេសមួយនិយាយថា "មនុស្សដ៏មុតស្រួចនឹងសំរួចមនុស្សឲ្យមុតស្រួចដូច្នេះពុំមែនតែដែកប៉ុណ្ណោះទេដែលសំរួចដែក" ។

~ ប្រសិនបើអ្នកចង់ក្លាយទៅជាអ្នកគិតដ៏មុតស្រួច សូមអ្នកទៅក្បែរមនុស្សដែលមុតស្រួច ។

### ៣.៣ ~ ជ្រើសរើសយកមកគិតនូវគំនិតល្អៗ

~ ដើម្បីក្លាយទៅជាអ្នកពូកែគិត ទាល់តែអ្នកមានឆន្ទៈប្រឹងប្រឡូកអំពីដំណើរការគិត

- ជាទៀងទាត់ដាក់ខ្លួនឱ្យត្រូវកន្លែងដើម្បីគិត របនា ច្រៀក និងទាញគំនិតឱ្យចុះចត ÷ នេះគឺជារឿងអាទិភាព

- ការគិតគឺជាវិស័យមួយ

- អ្នកត្រូវរៀបចំពេលវេលា និងវិធីសាស្ត្រផ្ទាល់ខ្លួន

- ទោះជាអ្នកធ្វើបែបណាក្តី សូមទៅកាន់ទីកន្លែងគិតជាមួយនឹងក្រដាស និងប៊ិច ហើយសូមឱ្យច្បាស់ថា អ្នកចាប់ក្រសោបគំនិតរបស់អ្នកដោយសរសេរ

៣.៤ - <u>ប្រព្រឹត្តតាមគំនិតល្អរបស់អ្នក</u>

- គំនិតតែងមានអាយុខ្លី អ្នកត្រូវប្រព្រឹត្តតាមវាមុនពេលត្រូវផុតកំណត់

- មាន ៦ពាក្យសម្រាប់ជោគជ័យ ÷ Think things through-then follow through

៣.៥ - <u>សូមប្រើការរំភើបចិត្តរបស់អ្នក ដើម្បីបង្កើតគំនិតល្អផ្សេងទៀត</u>

- ដើម្បីផ្តើមដំណើរការគិត អ្នកពុំអាចពឹងផ្អែកលើអារម្មណ៍របស់អ្នកនោះទេ ។

- បើអ្នករង់ចាំរហូតដល់ពេលអ្នកមានអារម្មណ៍ចង់ធ្វើអ្វីមួយនោះ អ្នកប្រហែលជាពុំអាចសម្រេចវាបានឡើយ : ដូចគ្នានឹងការគិតដូច្នេះដែរ ។

- អ្នកពុំអាចរង់ចាំរហូតដល់អ្នកមានអារម្មណ៍ចង់គិតទើបគិតបានឡើយ ។

- តែបើអ្នកបានប្រឡូកនឹងការគិតដ៏ពូកែហើយ អ្នកអាចប្រើប្រាស់ការរំភើបចិត្ត ដើម្បីបិញ្ចឹមដំណើរការ និងបង្កើតភាពចំពេលវេលានៃការប្រើខួរក្បាល ។

៣.៦ - <u>ធ្វើដំណើរការសារចុះសារឡើង</u>

- គំនិតដ៏ល្អមួយពុំអាចធ្វើឱ្យជីវិតបានល្អនោះទេ ។

- ជួនកាល មួយអាជីពធ្វើតាមគំនិតនោះ បែរជាបញ្ចប់ដោយក្តីមិនសប្បាយចិត្ត និងអាប់ឱន ។

- ជោគជ័យនឹងតាមរកមនុស្សណាដែលមានភ្នំមាសទាំងមូល ដែលគេអាចយកវាជាបន្តបន្ទាប់ ។

- ដើម្បីក្លាយជាអ្នកអាចយកវិមាសដ៏សំបូរ អ្នកចាំបាច់ត្រូវថែរក្សាដំណើរការគិតដ៏ល្អ

## ៤-ដាក់ខ្លួនឯងនៅកន្លែងដ៏ត្រឹមត្រូវដើម្បីគិត

ភាពជាអ្នកគិតដ៏ពូកែ គឺជាវិន័យមួយ (Discipline) ដែលមានដំណើរការជាប្រចាំថ្ងៃ ។

៤.១ - ស្វែងរកកន្លែងដើម្បីគិត

- ម្នាក់ៗតែងមានចំណូលចិត្តខុសគ្នា : ពេលងូតទឹក, សួន, រថយន្ត, យន្តហោះ និង កន្លែង Spa ឬលើគ្រែដេក ។

- តាមទំលាប់ និងចំណង់របស់ម្នាក់ៗ ដើម្បីបណ្តុះការគិតឲ្យចេញជាគំនិត តាមរយៈ ការចាប់យកគំនិត សរសេរនៅលើក្រដាសដើម្បីជៀសវាងការបាត់បង់ទៅវិញ ។

- យើងរកកន្លែងដើម្បីគិត គំនិតរកកន្លែងដើម្បីបញ្ចេញមកយើងវិញ ។

៤.២ - ស្វែងរកកន្លែងដើម្បីរចនាគំនិត

- ជាកម្រណាស់ គំនិតចេញមកទាំងស្រុង និងអាចយកទៅប្រើការបាន ។

- ជាទូទៅ វាត្រូវការឲ្យរចនារហូតដល់មានន័យគ្រប់គ្រាន់ ។

- នៅពេលដែលត្រូវរចនាគំនិត អ្នកចាប់គំនិតឲ្យជាប់ដើម្បីត្រួតពិនិត្យមើល ÷ សាក ល្បងសួរសំណួរដើម្បីរចនាវាឲ្យបានសមស្របយកទៅប្រើប្រាស់ ។ ធ្វើបែបនេះបានល្អ លុះ ណាតែសរសេរគំនិតនោះជាលាយលក្ខណ៍អក្សរ ។

- សមាជិកព្រឹទ្ធសភាអាមេរិកនិយាយថា : "រៀនសរសេរ គឺរៀនគិត អ្នកពុំអាចដឹងអ្វី ច្បាស់លាស់ទេ លុះណាតែអ្នកអាចថ្លែងចេញជាការសរសេរ" ។

- ក្នុងពេលវេលានៃការរចនាគំនិត វានាំមក :

✶ *ភាពសប្បាយ* : គំនិតដែលពុំបានការ តែនាំមកភាពកំសាន្តសប្បាយ

✶ *ភាពឱនលំទោន* : ការគិតជាពេលវេលាដែលយើងទាក់ទងជាមួយព្រះ

✶ *ភាពរំភើប* : ការគិតជាពេលវេលានៃការប្រើប្រាជ្ញា

✶ *ភាពថ្លៃប្រឌិត* : ការគិតជាពេលវេលានៃការផ្សារភ្ជាប់ទៅនឹងការពិត

✶ *ភាពពេញចិត្ត* : ការគិតជាការប្រើប្រាស់ឧបនិស្ស័យផ្ទាល់ខ្លួន

✷ *ភាពស្មោះត្រង់* : កាលបើរកឃើញគំនិតណាមួយក្នុងខួរក្បាល នេះហើយគឺជាការជំរុញទឹកចិត្ត

✷ *ភាពអត់ធ្មត់* : ពេលដែលអ្នករចនាគំនិត អ្នករកឃើញអ្វីដែលអ្នកជឿជាក់ និងអ្វីដែលអ្នកអាចពឹងផ្អែកបាន

✷ *ការផ្លាស់ប្តូរ* : អ្វីជាការផ្លាស់ប្តូរក្នុងជីវិត ជាលទ្ធផលនៃការគិតទៅលើបញ្ហាណាមួយ

៤.៣ ~ <u>ស្វែងរកកន្លែងដើម្បីពុះលំអិតគំនិត</u>

~ បើអ្នករកបានគំនិតដ៏ប្រសើរហើយ តាមរយៈប្រាជ្ញាខំរចនាវានោះមិនមានន័យថាចប់នោះទេ ។

~ ជំហានបន្ទាប់ត្រូវធ្វើនោះ គឺអ្នកត្រូវនាំគំនិតនោះទៅចែករំលែកជាមួយអ្នកដទៃ ដើម្បីធ្វើឱ្យគំនិតនោះកាន់តែមានសក្តានុពលខ្លាំងឡើង ។

~ អាចដើរបានឆ្ងាយជាងគិតតែខ្លួនឯងម្នាក់ បើគិតជាក្រុម ។

~ *រូបមន្ត* :

✷ គំនិតត្រឹមត្រូវ បូកជាមួយមនុស្សត្រឹមត្រូវ នៅក្នុងបរិយាកាសត្រឹមត្រូវ ត្រូវពេលវេលា ដើម្បីបុព្វហេតុត្រឹមត្រូវ = លទ្ធផលត្រឹមត្រូវ ។

៤.៤ ~ <u>ស្វែងរកកន្លែងដើម្បីចុះបតគំនិត</u>

~ គំនិតល្អប្រសើរចាំបាច់ត្រូវមានល្បឿនចុះបត និងស្លាប

~ គំនិតដែលនៅតែជាគំនិត ពុំដែលមានឥទ្ធិពលល្អប្រសើរឡើយ

~ អំណាចនៃគំនិតចេញជាលទ្ធផល កាលណាគំនិតនោះវាដើរចេញពីភាពអរូបីទៅកាន់ការអនុវត្ត (នេះជាទ្រឹស្តីទំនាក់ទំនងគ្នារបស់លោក Einstein's Theory of relativity)

✷ ជាទ្រឹស្តីរកឃើញនៅឆ្នាំ ១៩០៥ និង ១៩១៦ វានៅតែជាទ្រឹស្តី លុះណាតែវាក្លាយទៅជា Nuclear Reactor នៅឆ្នាំ ១៩៤២ និងអាវុធបរមាណូ

នៅឆ្នាំ ១៩៤៥

✱ ពេលដែលអ្នកវិទ្យាសាស្ត្រអនុវត្តនូវទ្រឹស្តីនោះ ពិភពលោកទាំងមូលត្រូវផ្លាស់ប្តូរ

~ ក្នុងដំណាក់កាលរៀបចំផែនការអនុវត្តគំនិតរបស់អ្នក អ្នកត្រូវបុះចតគំនិតរបស់អ្នកតាមដំហានបន្តបន្ទាប់ដូចតទៅ :

✱ **ខ្លួនអ្នក** : បុះចតគំនិតរបស់អ្នកជាដំបូងជាមួយខ្លួនឯង វាបង្ហាញពីសុចរិតភាពផ្ទាល់ខ្លួន

◈ មហាជនជឿលើគំនិតណាមួយ លុះត្រាតែគេជឿជាក់លើអ្នកដឹកនាំដែលប្រាប់ទៅលើគេពីរឿងនេះ

◈ ត្រូវសួរខ្លួនឯងនូវសំណួរ ៣ :

**ទី១**~ តើខ្ញុំខ្លួនឯងជឿជាក់លើគំនិតនេះដែរឬទេ?

**ទី២**~ តើខ្ញុំគាំទ្រប្តូរផ្តាច់ចំពោះគំនិតនេះដែរឬទេ?

**ទី៣**~ តើខ្ញុំជឿជាក់ថា អ្នកដទៃគាំទ្រប្តូរផ្តាច់ដែរឬទេ?

បើពុំអាចឆ្លើយនឹងសំណួរទាំងបីនេះបានទេ បានន័យថាអ្នកពុំទាន់អាចធ្វើគំនិតខ្លួនឯងបុះចតបាននៅឡើយទេ ។

✱ **តួអង្គសំខាន់ៗ (គន្លឹះ)** ÷ គំនិតពុំអាចហោះហើរឡើងបានឡើយ បើអ្នកមានឥទ្ធិពលពុំទទួលយក ។ ពួកគេជាមនុស្សដែលត្រូវយកគំនិតនោះទៅអនុវត្ត ។

✱ **តួអង្គដែលត្រូវប៉ះពាល់** ÷ បញ្ហានៅត្រង់អ្នកដែលត្រូវប៉ះពាល់ព្រមទទួលយកគំនិតថ្មី ÷ ការអានអំពីការពិត (Reality read) ។ មិនចំណុះថាអ្នកមានគំនិតល្អ បានរចនាវា ពុះលំអិតគំនិតនោះជាមួយអ្នកពូកែគិត តែនៅតែពុំទាន់អាចមានលទ្ធភាព បើតួអង្គដែលត្រូវប៉ះពាល់ពុំផ្តល់ការគាំទ្រ និងទទួលយកទៅអនុវត្តន៍ ។

## ៥_ស្វែងរកកន្លែងដើម្បីបង្ហោះគំនិត

~ ទស្សនវិទូល្បីឈ្មោះជនជាតិបារាំង Henri-Louis Bergson និយាយថា :

✶ មនុស្សគួរគិតដូចជាមនុស្សកំពុងធ្វើសកម្មភាព ធ្វើសកម្មភាពដូចជាមនុស្សដែលមានគំនិត ។

- តើការគិតបានល្អស្អី ប្រសិនបើការគិតនោះគ្មានការអនុវត្តនៅក្នុងគំនិតជាក់ស្តែង ។

✶ គំនិតដែលលែងលះគ្នាជាមួយសកម្មភាព ពិតជាពុំអាចបានផលឡើយ ។

✶ ត្រូវរៀនគិតដើម្បីធ្វើម្ចាស់លើដំណើរការគិតឲ្យបានល្អ ដែលនាំឲ្យមានការគិតដោយមានផ្លែផ្កា ។

✶ កាលណាបេះអភិវឌ្ឍន៍ដំណើរការគិតឲ្យបានល្អហើយ ក្លាយជាទម្លាប់ក្នុងជីវិត អ្នកនឹងមានជោគជ័យ ហើយបានទទួលផលផ្លែផ្កាក្នុងជីវិតរបស់អ្នក (កុំគិតចោល ថាចោល និយាយចោល) ។

✶ កាលណាបង្កើតគំនិតមួយបានហើយ រចនាវា ពុះលំអិតវា ចុះចតវា បន្ទាប់មកបង្ហោះវាដោយសប្បាយ និងដោយងាយស្រួល ។

## ៦.រូបភាពរបស់អ្នកពូកែគិត

- អ្នកខ្លះនិយាយថា អ្នកពូកែគិត :

✶ ជាអ្នកមានប្រាជ្ញាខ្ពស់ 1Q, ជាអ្នកដឹងរឿងសំខាន់ៗ, ជាអ្នកចេះមើលធ្លុះអាថិកំបាំង

✶ ការគិតដ៏ពូកែ ចាំបាច់ត្រូវមានជំនាញគិតជាក់ស្តែងជាច្រើន (Specific thinking skills)

✶ ក្លាយជាអ្នកពូកែគិត មានន័យថា អភិវឌ្ឍន៍ជំនាញនៃការគិតទាំងនោះដើម្បីពង្រីកសមត្ថភាពខ្លួនឯងឲ្យបានប្រសើរបំផុត

✶ មិនថាកើតមកក្របុមាន, មិនថាមានសញ្ញាប័ត្រជាន់ខ្ពស់ Ph.D ឬក៏គ្មាន, មិនថាខ្លួនពិការឬសុខភាពល្អ, មិនថាកាលៈទេសៈណាក៏ដោយ អ្នកសុទ្ធតែអាចក្លាយទៅជាអ្នកគិតដ៏ពូកែ ប្រសិនបើអ្នកប្រឹក្សាកនឹងការគិតជារៀងរាល់ថ្ងៃ

✶ អ្នកត្រូវគិតលើគ្រប់ផ្នែក (រូបភាពធំផង តូចផង) ដើម្បីក្លាយទៅជាមនុស្សមាន

ជោគជ័យ ។

ផ្នែកៗទាំងនោះមានជំនាញចំនួន ១១ គឺ ÷

១- មើលឃើញផលប្រយោជន៍នៃការគិតជារូបភាពធំ (Big-Picture Thinking)

២- ប្រកាន់យកសក្ដានុពលនៃការគិតដោយប្រមូលផ្ដុំ (Focused Thinking)

៣- រកឲ្យឃើញការសប្បាយនៃការគិតដោយច្នៃប្រឌិត (Creative Thinking)

៤- ទទួលស្គាល់សារសំខាន់នៃការគិត ឈរលើភាពប្រាកដនិយម (Realistic Thinking)

៥- បញ្ចេញនូវអំណាចនៃការគិតជាយុទ្ធសាស្ត្រ (Strategic Thinking)

៦- ចាប់អារម្មណ៍ពីថាមពលនៃការគិតអំពីលទ្ធភាព (Possibility Thinking)

៧- ឱបក្រសោបយកនូវមេរៀននៃការគិតដោយមានការត្រិះ (Reflective Thinking)

៨- ចោទសួរអំពីការព្រមទទួលយកនៃការគិតរបស់មហាជន (Popular Thinking)

៩- លើកទឹកចិត្តការចូលរួមនៃការគិតដែលមានការចែករំលែកគ្នា (Shared Thinking)

១០- សិក្សាពិសោធន៍អំពីការពេញចិត្តចំពោះការគិតដោយមិនអាត្មានិយម (Unselfish Thinking)

១១- ពេញចិត្តនឹងផលត្រឡប់បានមកវិញនៃការគិតអំពីមូលដ្ឋានគ្រឹះ (Bottom-Line Thinking)

✶ នេះជាការប្រាប់ឲ្យអ្នកដឹង ពុំមែនអំពីអ្វីដែលត្រូវគិតឡើយ (what to think) តែនេះជាការបង្រៀនឲ្យអ្នកចេះថា ត្រូវគិតតាមរបៀបយ៉ាងដូចម្ដេច (how to think) ។

✶ ក្នុងជំនាញទាំង១១ ជំនាញខ្លះអ្នកអាចធ្វើបានល្អ ជំនាញខ្លះពុំទាន់បានល្អ ។

✶ លុះណាតែអ្នកអភិវឌ្ឍន៍ជំនាញនីមួយៗ នោះអ្នកក្លាយជាអ្នកពូកែគិត ជីវិតរបស់អ្នកនឹងផ្លាស់ប្ដូរ ព្រោះចំណុចខ្សោយរបស់អ្នកត្រូវបានលុបបំបាត់ជាជំហានៗ ទៅតាមពេលវេលាដែលអ្នកបានប្រែក្លាយពីការពុំចេះគិតទៅជាអ្នកចេះគិត ។

×

× ×

# ជំពូកទី១
# តើមនុស្សដែលមានជោគជ័យគិតយ៉ាងដូចម្តេច?

## ១-បណ្តុះការគិតដល់រូបភាពធំ (Cultivate Big-Picture Thinking)

- លោក David Schwarts និយាយថា :
  - ✶ បើនិយាយពីជោគជ័យទាំងឡាយនោះ មនុស្សពុំត្រូវបានវាស់វែងដោយ inches ឬ pounds ឬកំរិតសិក្សា ឬប្រវត្តិគ្រួសារឡើយ ។ ជោគជ័យទាំងនោះត្រូវបានវាស់វែងដោយទំហំនៃការគិតរបស់ពួកគេ (Size of thinking) ។
- ការគិតដល់រូបភាពធំផ្តល់ផលប្រយោជន៍ដល់មនុស្សគ្រប់រូប មិនថាទោះមានមុខវិជ្ជាជីវៈណាក្តី ។
  - ✶ ទំនាក់ទំនងជាប់បន្តវាងនិយោជិត និងអតិថិជន វាសំខាន់ជាងការលក់ផលិតផលរបស់បុគ្គលណាម្នាក់ ÷ នេះគឺជារូបភាពធំដែលត្រូវចងចាំ
  - ✶ ការរំលឹកគ្នាថា ការលំបាកពេលបច្ចុប្បន្នគ្រាន់តែជារដូវបណ្តោះអាសន្នប៉ុណ្ណោះ គឺជាការទាញផលប្រយោជន៍ពីការគិតដល់រូបភាពធំ
  - ✶ អ្នកលក់អចលនវត្ថុនិយាយថា : អ្នកត្រូវគិតជាចាំបាច់ ហេតុអ្វីពុំហ៊ានគិតពីរូបភាពធំ
- ការគិតដល់រូបភាពធំនាំមកនូវភាពគ្រប់ជ្រុងជ្រោយ (Wholeness) និងភាពចាស់ទុំ (Maturity) ចំពោះការគិតរបស់បុគ្គលណាម្នាក់ វានាំមកនូវទស្សនវិស័យ (Perspective)
- វាហាក់ដូចជាការធ្វើស៊ុមរូបថតឲ្យបានធំ(ជាងរូបភាព) ដើម្បីដំណើរការពង្រីកវាឲ្យធំជាងរូបភាពដែលយើងកំពុងមើលឃើញ ជាអ្វីដែលយើងអាចធ្វើបាន

- អ្នកគិតដល់រូបភាពធំជាមនុស្សដែល :

១.១ - រៀនជាបន្តបន្ទាប់

- អ្នកគិតដល់រូបភាពធំ ពុំដែលពេញចិត្តជាមួយអ្វីដែលបានចេះដឹងរួចហើយឡើយ : គេតែង ទៅទស្សនាកន្លែងថ្មីៗ អានសៀវភៅថ្មី ជួបមនុស្សថ្មី រៀនជំនាញថ្មី ។
- តាមការអនុវត្តបែបនេះ ជាញឹកញាប់ពួកគេអាចតភ្ជាប់ខ្លួនបានទៅនឹងអ្វីដែលមិនតភ្ជាប់ គ្នា ÷ ពួកគេជាអ្នករៀនមួយជីវិត ។
- ដើម្បីថែរក្សាឥរិយាបថជាអ្នកចង់រៀន (a learner attitude) រៀងរាល់ព្រឹកត្រូវចំណាយ ពេលគិតអំពីឱកាសនៃការរៀន (learning opportunities) ។
- តាមរយៈការពិនិត្យមើលប្រតិទិនការងារ និងបញ្ជីការងារ : អាចដឹងថានរណាខ្លះត្រូវជួប ក្នុងថ្ងៃនេះ អ្វីខ្លះដែលត្រូវការ ការប្រជុំអ្វីខ្លះដែលត្រូវចូលរួម ដូច្នេះត្រូវធ្វើកំណត់សម្គាល់ អំពីខ្លះដែលអាចរៀនសូត្របាន ។ ធ្វើបែបនេះជាការលើកកម្ពស់ការយកចិត្តទុកដាក់ដល់ អ្វីដែលអាចធ្វើឲ្យខ្លួនឯងល្អប្រសើរឡើង ។
- ដើម្បីថែរក្សាការរៀន ត្រូវពិនិត្យអំពីថ្ងៃរបស់អ្នក ហើយត្រូវស្វែងរកឱកាសដើម្បីរៀន ។

១.២ - ស្តាប់ដោយយកចិត្តទុកដាក់

- វិធីដ៏ល្អដើម្បីពង្រីកនូវបទពិសោធន៍របស់អ្នក គឺត្រូវស្តាប់នរណាម្នាក់ដែលមានឯកទេស លើវិស័យណាមួយ ដែលអ្នកគ្មានឯកទេសនោះ ។
- ការស្តាប់គេជាការបង្រៀនអ្នកឲ្យបានចេះច្រើនជាងការនិយាយ ។
- ក្នុងពេលជួបនរណាម្នាក់ ជាការល្អអ្នកត្រូវមានរបៀបវារៈមួយ ដែលអ្នកអាចរៀនសូត្រពី អ្នកនោះ ។
- វាជាការគាប់ប្រសើរ ដែលត្រូវសេពគប់ចងជាដៃគូជាមួយមនុស្សដែលអាចធ្វើអ្វីៗដែល អ្នកពុំអាចធ្វើបានដោយខ្លួនឯង ។

- អ្នកគិតដល់រូបភាពធំ តែងទទួលស្គាល់ថាពួកគេពុំទាន់យល់ដឹងអំពីរឿងជាច្រើន ។ ពួកគេតែងលើកសំណួរបើកទូលាយ (penetrating questions) ដើម្បីពង្រីកការយល់ដឹង និងការគិតរបស់ពួកគេ ។
- ប្រសិនបើអ្នកចង់ក្លាយទៅជាអ្នកពូកែគិតដល់រូបភាពធំនោះ ទាល់តែអ្នកជាអ្នកពូកែស្តាប់គេឯង (good listener) ។

១.៣- <u>សម្លឹងមើលឲ្យធំទូលាយ</u>

- អ្នកនិពន្ធ Henry David Thoreau សរសេរថា : "ភាគច្រើននៃរបស់មួយត្រូវបានគេមើលមិនឃើញ ទោះបីរបស់នោះវាធ្លាក់ចុះមកក្រោមភ្នែកយើងក៏ដោយ ពីព្រោះរបស់នោះពុំបានមកដល់ក្រោមចម្ងាយនៃប្រាជ្ញារបស់យើង ។
- ជាទម្លាប់មនុស្សតែងមើលឃើញជាអាទិភាពនូវពិភពរបស់ខ្លួនឯងផ្ទាល់ ។
    - ✶ ជាឧទាហរណ៍ ទៅចូលរួមសិក្ខាសាលានិយាយអំពីភាពជាអ្នកដឹកនាំ អ្នកចូលរួមតែងចង់ដឹងជាបឋមថា :
        - ✶ តើចតរថយន្តនៅកន្លែងណា?
        - ✶ តើមានកៅអីអង្គុយចំកន្លែងល្អ និងមានផាសុកភាពដែរឬទេ?
        - ✶ តើមេក្រូនិយាយកើតដែរឬទេ?
        - ✶ ពេលសម្រាករៀបចំចន្លោះពេលដោយត្រឹមត្រូវដែរឬទេ?
        - ✶ តើពន្លឺវាគ្រប់គ្រាន់ដែរឬទេ?
        - ✶ បរិក្ខាសម្លេងដំណើរការដោយប្រសិទ្ធភាពដែរឬទេ?
        - ✶ តើអ្នកឧទ្ទេសនាមមានកន្លែងឈរភ្ញៀវអ្នកស្តាប់ដែរឬទេ?
    - ✶ តើរូបអ្នកជានរណា វាកំណត់នូវអ្វីដែលអ្នកមើលឃើញ និងអ្វីដែលអ្នកគិត (Who you are determines what you see and how you think)
    - ✶ អ្នកគិតដល់រូបភាពធំតែងយល់ថា មានពិភពលោកមួយដែលដាច់ដោយឡែកពីពិភពរបស់ខ្លួនឯងផ្ទាល់ ។ ពួកគេខិតខំដើរចេញពីក្នុងខ្លួនឯង ដើម្បីសម្លឹងមើលដោយភ្នែកខ្លួនឯងទៅលើពិភពរបស់អ្នកដទៃ ។

✶ គឺពិបាកណាស់នឹងឃើញរូបភាពធំ បើដាក់ខ្លួនឯងនៅក្នុងស៊ុមនោះ ។

✶ ដើម្បីមើលឃើញដូចអ្នកដទៃមើលឃើញនោះ អ្នកត្រូវរកឱ្យឃើញថា តើអ្នកដទៃគិតយ៉ាងដូចម្តេច? ក្លាយជាអ្នកពូកែស្តាប់វាប្រាកដជានឹងជួយដល់រូបអ្នក ។

✶ ត្រូវដើរឱ្យហួសរបៀបវារៈផ្ទាល់ខ្លួន ដើម្បីមើលឃើញនូវទស្សនៈវិស័យរបស់អ្នកដទៃ

១.៣ ~ <u>រស់នៅដោយពេលពេញ</u>

~ អ្នកនិពន្ធបារាំង Michel Eyquenn de Montaigne បានសរសេរថា : "តម្លៃរបស់ជីវិតពុំមែនស្ថិតនៅចំនួននៃថ្ងៃឡើយ តែតម្លៃនោះស្ថិតនៅលើការដែលយើងប្រើប្រាស់ថ្ងៃទាំងនោះ ។ មនុស្សអាចរស់នៅបានយូរយា តែជីវិតមានតម្លៃតិចតួច" ។

✶ ជាការពិត អ្នកអាចចំណាយជីវិតរបស់អ្នកទៅតាមចំណង់របស់អ្នក តែអ្នកអាចចំណាយជីវិតនោះបានតែម្តងទេ ។

✶ ក្លាយជាអ្នកគិតដល់រូបភាពធំ អាចជួយឱ្យអ្នកឱ្យរស់នៅដោយគ្រប់ជ្រុងជ្រោយ ជាជីវិតបានសម្រេចប្រកបដោយជោគជ័យ ។

✶ មនុស្សដែលមើលឃើញរូបភាពធំពង្រីកនូវបទពិសោធន៍របស់ខ្លួន ពីព្រោះពួកគេពង្រីកនូវពិភពរបស់ពួកគេ ។ ជាលទ្ធផល ពួកគេអាចសម្រេចអ្វីៗបានច្រើនជាងពួកគិតដោយចង្អៀត (Narrow-minded people) ។

✶ ពួកគេជួបប្រទះតិចតួចនូវភាពភ្ញាក់ផ្អើលដែលពុំចង់ឱ្យកើតមាន (unwanted surprises) ពីព្រោះពួកគេតែងចង់មើលឃើញអង្គធាតុជាច្រើន ដែលពាក់ព័ន្ធនៅក្នុងស្ថានការណ៍ណាមួយនោះ ជាអាទិ៍ បញ្ហា(Issues), មនុស្ស(People), ទំនាក់ទំនង(Relationships), ពេលវេលា(Timing) និងតម្លៃ(Values) ។

✶ ជាធម្មតា ពួកគេកាន់តែមានអធ្យាស្រ័យចំពោះមនុស្សដទៃ និងការគិតរបស់មនុស្សដទៃ ។

## ២.ហេតុអ្វីអ្នកត្រូវទទួលផលប្រយោជន៍ពីការគិតដល់រូបភាពធំ

**Why you should receive the wisdom of Big-Picture Thinking**

~ មានមនុស្សមួយចំនួនតូចតែងចង់ក្លាយជាអ្នកបិទគំនិត (closed minded people)

- ជាទូទៅ ការគិតដល់រូបភាពធំពិតជាមានផលប្រយោជន៍ច្រើនយ៉ាង

២.១ - <u>ការគិតដល់រូបភាពធំផ្ដល់ឱកាសឱ្យអ្នកដឹកនាំ</u>

- អ្នកអាចមើលឃើញ អ្នកគិតដល់រូបភាពធំជាច្រើនដែលពុំមែនជាអ្នកដឹកនាំ តែអ្នកមើលឃើញថា អ្នកដឹកនាំតិចតួចប៉ុណ្ណោះដែលពុំមែនជាអ្នកគិតដល់រូបភាពធំ ។
- អ្នកដឹកនាំត្រូវមានសមត្ថភាពធ្វើកិច្ចការសំខាន់ៗជាច្រើនសម្រាប់មនុស្សក្រោមឱវាទរបស់ពួកគេ ÷
    - ✶ មើលឃើញនូវចក្ខុវិស័យ (Vision) មុនកូនចៅរបស់ខ្លួនមើលឃើញ ។
    - ✶ ចាប់ឱកាស គិតដល់កត្តាប្រែប្រួលទាំងឡាយ ÷ អ្នកដឹកនាំដែលមើលឃើញរូបភាពធំបែងចែកលទ្ធភាព(Possibilities) ក៏ដូចជាបញ្ហា(Problems) ដើម្បីបង្កើតជាគ្រឹះសម្រាប់ការកសាងនូវចក្ខុវិស័យ ។
    - ✶ ពុះចែកលំអិតរូបភាពអំពីទីកន្លែងដែលក្រុមត្រូវធ្វើដំណើរទៅ រួមទាំងការប្រឈម ឬឧបសគ្គជាសក្ដានុពល (Any potential challenges or obstacles) ។ អ្នកដឹកនាំតែងមានបំណង ពុំត្រឹមតែឱ្យកូនចៅខ្លួនមានអារម្មណ៍ល្អប៉ុណ្ណោះទេ តែត្រូវជួយពួកគេឱ្យក្លាយជាអ្នកល្អ និងសម្រេចបាននូវក្ដីស្រម័យជាលទ្ធផលនៃចក្ខុវិស័យមួយច្បាស់លាស់ ។
    - ✶ បង្ហាញពីអនាគតផ្សារភ្ជាប់នឹងអតីតកាលយ៉ាងដូចម្ដេច ដើម្បីឱ្យការធ្វើដំណើរកាន់តែមានន័យ ÷ នេះជាការទទួលស្គាល់អំពីការផ្សារភ្ជាប់គ្នា (Connection) និងចង់ធ្វើជាស្ពានតភ្ជាប់ ។
    - ✶ ចាប់ឱកាសកាលណាពេលវេលាមកដល់ត្រឹមត្រូវក្នុងការដឹកនាំ ពេលដែលត្រូវទៅមុខមានសារសំខាន់ដូចអ្វីដែលយើងធ្វើដែរ ។
- នាយករដ្ឋមន្ត្រីអង់គ្លេស Winston Churchill និយាយថា : "មានពេលវេលាពិសេសមកដល់នៅក្នុងជីវិតមនុស្សម្នាក់ៗ គឺជាពេលវេលាដែលមនុស្សនោះបានកើត... កាលណាគេចាប់បានពេលវេលានោះ នោះហើយគឺជាម៉ោងពេលដ៏ល្អបំផុតរបស់ពួកគេ" ។

- មិនថាកសាងផ្លូវ រៀបចំផែនការធ្វើដំណើរ ឬចូលទៅកាន់ភាពដឹកនាំ ការគិតដល់រូបភាពធំធ្វើឱ្យអ្នកកាន់តែទទួលបានជោគជ័យ ។ ក្នុងការសម្រេចកិច្ចការអ្វីក៏ដោយ មនុស្សដែលទម្លាប់គិតដល់រូបភាពទាំងមូល តែងមានសំណាងល្អបំផុតដើម្បីទទួលបានជោគជ័យ ។

២.២- ការគិតដល់រូបភាពធំថែរក្សារូបអ្នកឱ្យទៅដល់គោលដៅ

- លោក Thomas Fuller ជាសេនារបស់ស្តេចអង់គ្លេស Charles II កត់សម្គាល់ថា : "នរណាម្នាក់ដែលមាននៅគ្រប់កន្លែង គឺរូបគាត់នោះគ្មាននៅកន្លែងណាទាំងអស់ (He that is everywhere is nowhere) ÷ ដើម្បីសម្រេចបានការងារ អ្នកចាំបាច់ត្រូវមានគោលដៅ (To get things done, you need focus) ។
- ដើម្បីសម្រេចបាននូវការងារដ៏ល្អត្រឹមត្រូវ អ្នកក៏ត្រូវគិតដល់រូបភាពធំដែរ ÷ លុះណាតែអ្នកដាក់សកម្មភាពប្រចាំថ្ងៃរបស់អ្នកនៅក្នុងបរិបទនៃរូបភាពធំទើបអ្នកថែរក្សាខ្លួនឯងបានទៅតាមគោលដៅ ។
- លោក Alvin Toffler និយាយថា : "អ្នកត្រូវគិតដល់កិច្ចការធំៗ ក្នុងពេលដែលអ្នកធ្វើកិច្ចការតូចតាច ដើម្បីឱ្យកិច្ចការតូចតាចទាំងនោះដើរទៅតាមទិសដៅដ៏ត្រឹមត្រូវ" ។

២.៣- ការគិតដល់រូបភាពធំនាំឱ្យអ្នកមើលឃើញនូវអ្វីដែលអ្នកដទៃមើលឃើញ

- ជំនាញដ៏សំខាន់បំផុតដែលអ្នកត្រូវអភិវឌ្ឍន៍សម្រាប់ទំនាក់ទំនងរវាងមនុស្ស គឺសមត្ថភាពដើម្បីមើលឃើញរឿងរ៉ាវទៅតាមទស្សនៈរបស់មនុស្សដទៃ ។
- នេះជាគន្លឹះមួយសម្រាប់ធ្វើការជាមួយអតិថិជន បំពេញចិត្តអតិថិជន ថែរក្សាចំណងអាពាហ៍ពិពាហ៍ ថែទាំកូនចៅ ជួយដល់អ្នកពុំសូវមានទ្រព្យសម្បត្តិ....។ល។
- អន្តរកម្មទាំងអស់រវាងមនុស្សត្រូវបានលើកតម្កើង ដោយសមត្ថភាពដាក់ខ្លួនឯងនៅក្នុងស្បែកជើងរបស់អ្នកដទៃ (the ability to put yourself in another person's shoes)
- តើត្រូវធ្វើយ៉ាងដូចម្តេច ?
  - ✶ មើលខាងក្រៅខ្លួនឯង

* ✶ មើលខាងក្រៅផលប្រយោជន៍ផ្ទាល់ខ្លួន
* ✶ មើលខាងក្រៅពិភពផ្ទាល់ខ្លួន

- កាលណាអ្នកគិតគូរពិចារណាលើបញ្ហាមួយពីគ្រប់ជ្រុងដែលអ្នកមាន (From every possible angle) ពិនិត្យដោយយោងដល់ពន្លឺនៃប្រវត្តិរបស់អ្នកដទៃ រកឲ្យឃើញនូវផលប្រយោជន៍ និងកង្វល់របស់អ្នកដទៃ ហើយខិតខំដាក់របៀបវារៈផ្ទាល់ខ្លួននៅម្ខាង ពេលនោះអ្នកចាប់ផ្តើមមើលឃើញនូវអ្វីដែលអ្នកដទៃមើលឃើញ ÷ នេះជារបស់ដែលមានអំណាច ។

## ២.៤- ការគិតដល់រូបភាពធំនឹងបង្កើនជម្រុញការងារជាក្រុម

- ប្រសិនបើអ្នកចូលរួមក្នុងសកម្មភាពជាក្រុមណាមួយក៏ដោយ អ្នកនឹងយល់ដឹងអំពីសារៈសំខាន់ដែលសមាជិកក្រុមមើលឃើញរូបភាពធំ ពុំត្រឹមតែចំណែកផ្ទាល់ខ្លួនប៉ុណ្ណោះទេ ។
- គ្រប់ពេលវេលា ជនម្នាក់តែងតែពុំបានដឹងថាតើការងាររបស់គេវាសមស្របទៅនឹងក្រុមរបស់ខ្លួនដែរឬអត់ ។ ពេលនោះ ការពុំដឹងបែបនេះនឹងធ្វើឲ្យក្រុមទាំងមូលជួបចលាចល ។
- ជាប្រសើរបំផុត សមាជិកក្រុមត្រូវតែមើលឃើញរូបភាពធំ ពេលនោះសក្តានុពលនៃការធ្វើការងារក្រុមកាន់តែឡើងខ្ពស់ ។

## ២.៥- ការគិតដល់រូបភាពធំថែរក្សារូបអ្នកឲ្យដើរទាន់សភាពការណ៍

- ទិដ្ឋភាពខ្លះនៃជីវិតរាល់ថ្ងៃតែងតែចាំបាច់ជាចាំខាត តែមិនសូវមានសារសំខាន់ឡើយ ។ អ្នកគិតដល់រូបភាពធំ ពុំទុកឲ្យរឿងកំប៉ិកកំប៉ុករុករានរូបគេ ពីព្រោះពួកគេពុំបាត់បង់ការមើលឃើញទិដ្ឋភាពសំខាន់ៗរួមទាំងអស់ឡើយ (The all-important overview) ។
- ពួកគេដឹងថា ជនណាដែលភ្លេចគោលដៅចុងក្រោយ (The ultimate) គឺជាទាសករនៃភាពបន្ទាន់ភ្លាមៗចំពោះមុខ (The immediate) ។

## ២.៦- ការគិតដល់រូបភាពធំជួយអ្នកឲ្យដើរចូលតំបន់ដែលពុំធ្លាប់ចូល

**(To Chart Uncharted Territory)**

- គេនិយាយថា : "យើងនឹងឆ្លងផុតស្ពាននោះ កាលណាយើងទៅដល់ទីនោះ" ។ ឃ្លានេះចង់និយាយដល់ជនដែលមានបញ្ហាក្នុងការមើលឲ្យឃើញរូបភាពធំ ។
- ពិភពលោកយើងត្រូវបានកសាងដោយក្រុមមនុស្សដែលបាន"ឆ្លងកាត់ស្ពាន" នៅក្នុងគំនិតរបស់ពួកគេជាយូរយា មុននរណាម្នាក់ផ្សេងទៀតគិតឃើញ ។
- វិធីសាស្ត្រតែមួយគត់ដើម្បីឈានជើងដល់ដែនដីថ្មី ឬឈានចូលដែនដីដែលពុំធ្លាប់ចូល គឺត្រូវមើលឲ្យហួសពីភាពបន្ទាន់ភ្លាមៗចំពោះមុខ និងមើលឃើញនូវរូបភាពធំ ។

## ៣_តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីបានទទួលផលពីការគិតដល់រូបភាពធំ

**How to Acquire the Wisdom of Big-Picture Thinking**

- ប្រសិនបើអ្នកចង់ចាប់ឱកាសថ្មី និងបើកជើងមេឃថ្មី អ្នកចាំបាច់ត្រូវបន្ថែមសមត្ថភាពដើម្បីចេះគិតដល់រូបភាពធំ ។
- ដើម្បីក្លាយជាអ្នកគិតដ៏ពូកែ ដែលអាចមើលឃើញរូបភាពធំ ÷

### ៣.១~ កុំស្វះស្វែងរកភាពច្បាស់លាស់ (Certainty)

- អ្នកគិតដល់រូបភាពធំដាក់ខ្លួនស្រណុកជាមួយនឹងភាពស្រពិចស្រពិល(Ambiguity)។សូមកុំសាកល្បងបង្ខំលើការសង្កេតណាមួយ ឬទិន្នន័យណាមួយធ្វើជារូបមន្តគិតដំបូង ។ ពួកគេគិតដោយទូលំទូលាយ ហើយក្នុងខួរក្បាលរបស់ពួកគេមានគំនិតបញ្ច្រាស-បណ្តោយ ។
- ប្រសិនបើអ្នកចង់មានសមត្ថភាពគិតដល់រូបភាពធំ អ្នកត្រូវទម្លាប់ដើម្បីឱបក្រសោប និងដោះស្រាយជាមួយគំនិតស្មុគ្រស្មាញនិងប្លែកៗគ្នា ។

### ៣.២~ រៀនសូត្រពីបទពិសោធន៍នីមួយៗ

- អ្នកគិតដល់រូបភាពធំពង្រីកការមើលឃើញរបស់ពួកគេ តាមរយៈការរៀនសូត្រអំពីបទពិសោធន៍នីមួយៗ ។ ពួកគេពុំមែនសម្រាកនៅលើជោគជ័យរបស់ពួកគេឡើយ ពួកគេរៀនអំពីជោគជ័យទាំងនេះ ។ ជាសំខាន់នោះ ពួកគេរៀនសូត្រអំពីបរាជ័យរបស់ពួកគេ ។ ពួកគេអាចធ្វើបានយ៉ាងនេះ ពីព្រោះពួកគេដាក់ខ្លួនជាអ្នករៀនសូត្របាន ។

- បទពិសោធន៍ទាំងឡាយ ទាំងវិជ្ជមាន ទាំងអវិជ្ជមាន នាំឲ្យអ្នកមើលឃើញនូវរូបភាពធំ ។ បើអ្នកមានបទពិសោធន៍ និងជោគជ័យប្លែកៗជាច្រើន នោះអ្នកនឹងមានសក្តានុពលដើម្បីរៀនសូត្រ ។
- បើចង់ក្លាយជាអ្នកគិតដល់រូបភាពធំ សូមអ្នកខិតខំ និងសាកល្បងលើរឿងជាច្រើន ជួបសំណាងច្រើន ហើយទុកពេលរៀនសូត្រអំពីជោគជ័យ ឬបរាជ័យនីមួយៗ ។

៣.៣~ <u>ដឹងដម្រៅរឿងរ៉ាវពីមនុស្សប្លែកៗគ្នា</u>

- អ្នកគិតដល់រូបភាពធំរៀនសូត្រអំពីបទពិសោធន៍របស់ខ្លួន ប៉ុន្តែពួកគេក៏រៀនសូត្រអំពីបទ~ពិសោធន៍ដែលខ្លួនគ្មានដែរ ។ បានន័យថា ពួកគេរៀនសូត្រដោយទទួលយកដម្រៅរឿងរ៉ាវពីអ្នកដទៃដូចជា ពីអតិថិជន និយោជិក សហសេវិក និងអ្នកដឹកនាំ ។
- ប្រសិនបើអ្នកចង់ពង្រីកការគិតរបស់អ្នក និងចង់មើលឃើញរូបភាពកាន់តែធំ នោះអ្នកត្រូវស្វែងរកទីប្រឹក្សាឲ្យជួយ ។ តែអ្នកត្រូវឲ្យវាងវៃក្នុងការជ្រើសយកនរណាធ្វើជាអ្នកផ្តល់យោបល់ឲ្យ ។
- ដឹងដម្រៅរឿងរ៉ាវពីមនុស្សប្លែកៗគ្នា ពុំមែនជាការបញ្ឈប់នរណាម្នាក់នៅតាមផ្លូវ ឬតាមហាងលក់ទំនិញដើម្បីសាកសួរអំពីកម្មវត្ថុណាមួយឡើយ ។ ត្រូវចេះជ្រើសសម្រាំងរកមនុស្ស ។ ត្រូវនិយាយជាមួយមនុស្សដែលដឹងរឿងរ៉ាវ និងយកចិត្តទុកដាក់ចំពោះអ្នកដែលដឹងអំពីវិស័យរបស់ខ្លួន ហើយនាំមកនូវបទពិសោធន៍ជ្រាលជ្រៅ និងទូលំទូលាយជាងរូបអ្នក ។

៣.៤~ <u>អនុញ្ញាតឲ្យខ្លួនអ្នកពង្រីកពិភពរបស់ខ្លួន</u>

- ប្រសិនបើអ្នកចង់ក្លាយជាអ្នកគិតដល់រូបភាពធំ អ្នកត្រូវដើរបញ្ហោសទៅនឹងលំហូរនៃពិភពលោក ។ សង្គមតែងចង់ឲ្យមនុស្សថែរក្សាខ្លួននៅក្នុងប្រអប់ ។ មនុស្សភាគច្រើនតែងតែជាស្មារតីរៀបការខ្លួនឯងជាមួយនឹងការថែរក្សាស្ថានភាពដដែល ។
- អ្វីដែលមនុស្សភាគច្រើនចង់គឺឲ្យដូចពីដើម ពុំមែនចង់ឲ្យខ្លួនប្រសើរជាងមុនឡើយ។ ពួកគេស្វះស្វែងរកសុវត្ថិភាព និងសំណួរសាមញ្ញៗ ។

- ដើម្បីគិតដល់រូបភាពធំ អ្នកចាំបាច់ត្រូវអនុញ្ញាតឱ្យខ្លួនអ្នកដើរនៅក្នុងផ្លូវវៀង និងដើរចូលដែនដីថ្មី រកឃើញនូវពិភពលោកថ្មីដើម្បីកាន់កាប់ ។ កាលណាពិភពរបស់អ្នកកាន់តែរីកធំឡើង អ្នកចាំបាច់ត្រូវតែត្រេកអរ ។
- សូមកុំភ្លេចថា មានពិភពលោកថ្មីដែលខុសពីពិភពលោកដែលអ្នកធ្លាប់មានបទពិសោធន៏
- សូមបន្តរៀនសូត្រ បន្តរីកចំរើន ហើយបន្តមើលរូបភាពធំ ។ នេះហើយជារបៀបដែលអ្នកចង់ក្លាយជាអ្នកគិតដ៏ពូកែ ។

×

× ×

# ជំពូកទី២

# ប្រឡូកនឹងការគិតដោយប្រមូលផ្តុំ
# ENGAGE IN FOCUSED THINKING

- អ្នកនិពន្ធ Charles Dickens និយាយថា : "វាធ្វើអ្វីនីមួយៗហាក់ដូចជាវាពុំធ្លាប់បានធ្វើអ្វីសោះ" ។
- ទស្សនវិទូ Bertrand Russel អះអាងថា : "ត្រូវប្រមូលផ្តុំគិតរយៈពេលយូរ គឺជាសារវ័ន្តសម្រាប់កិច្ចការដ៏ពិបាកៗ" ។
- សង្គមវិទូ Robert Lynd កត់សម្គាល់ថា : "ចំណេះដឹងគឺជាអំណាច ប្រសិនបើមនុស្សណាម្នាក់ដឹងថា តើហេតុការណ៍ផ្សេងៗណាខ្លះដែលពុំមែនជាការរំខាន ។
- ការគិតដោយប្រមូលផ្តុំ ទម្លាក់ចោលនូវការរវេសរវាយ (Distractions) និងរបាំងខាងស្មារតីដើម្បីអ្នកអាចប្រមូលផ្តុំលើបញ្ហាណាមួយ និងគិតវាដោយច្បាស់លាស់ ។

## ១‐ ការគិតដោយប្រមូលផ្តុំនាំឱ្យមានថាមពលឆ្ពោះទៅកាន់គោលបំណងដែលចង់បាន

- ការប្រមូលផ្តុំយកចិត្តទុកដាក់នាំមកនូវថាមពល និងអំណាចដើម្បីអ្វីៗទាំងអស់ មិនថារាងកាយ ឬស្មារតី ។
  - ✶ ប្រសិនបើអ្នកធ្វើឲ្យដំណើរការផលិតផលិតផលកាន់តែប្រសើរ ការគិតដោយប្រមូលផ្តុំនឹងជួយអ្នករកឃើញនូវវិធីដ៏ល្អបំផុត ។
  - ✶ ប្រសិនបើអ្នកចង់ដោះស្រាយចំណោទខាងគណិតវិទ្យាដ៏ពិបាក ការគិតដោយប្រមូលផ្តុំនឹងជួយឲ្យអ្នកបំបែករកឃើញនូវចម្លើយ ។
- ចំណោទ ឬបញ្ហាកាន់តែពិបាកបំផុតនោះ ពេលវេលានៃការគិតប្រមូលផ្តុំកាន់តែចាំបាច់ដើម្បីដោះស្រាយវា ។

## ២~ ការគិតដោយប្រមូលផ្តុំ ផ្តល់ពេលវេលាឱ្យគំនិតអភិវឌ្ឍន៍

- ដើម្បីរកឱ្យឃើញគំនិត និងអភិវឌ្ឍន៍គំនិត ក្រុមការងារដែលមានស្មារតីច្នៃប្រឌិតជួបជុំគ្នាដើម្បីលើកគំនិត (Brainstorming) និងផ្តល់គំនិតច្នៃប្រឌិត (Creative Think) ។
  - ✶ នេះជាការប្រមូលផ្តុំការគិត ដើម្បីបង្កើតគំនិតឱ្យបានច្រើនតាមដែលអាចធ្វើបាន
  - ✶ កំណើតនៃការបង្កើតរកឃើញជាញឹកញាប់បានមកពីការចែករំលែកគំនិតល្អជាមួយគ្នា ។
  - ✶ ប៉ុន្តែដើម្បីនាំគំនិតទៅកាន់ការគិតថ្មី អ្នកត្រូវផ្លាស់ពីការគិតដោយលាតសន្ធឹងទូលំទូលាយ ទៅកាន់ការគិតកាន់តែសម្រិតសម្រាំង ។
  - ✶ គំនិតដែលល្អអាចក្លាយទៅជាគំនិតដ៏ខ្ពង់ខ្ពស់ កាលណាមានពេលវេលាប្រមូលផ្តុំយកចិត្តទុកដាក់លើវា (Focus Time) ។
  - ✶ ជាការពិត គិតតែលើរឿងមួយដោយប្រើរយៈពេលយូរ អាចធ្វើឱ្យធុញទ្រាន់ ។
- ពេលខ្លះ យើងគិតលើរឿងមួយ និងខិតខំធ្វើឱ្យវារីកចំរើនឡើង ដោយគ្រាន់តែរកឱ្យឃើញថាតើអាចធ្វើឱ្យគំនិតនោះល្អប្រសើរបានដែរឬទេ ។
- ពេលខ្លះ ការព្យាយាមគិតដោយប្រមូលផ្តុំបានសម្រេច ដែលនាំឱ្យក្តីសប្បាយរីករាយ ព្រោះពុំត្រឹមតែគំនិតរីកចំរើនប៉ុណ្ណោះទេ ខ្លួនយើងផ្ទាល់ក៏រីកចំរើនដែរ ។

## ៣~ ការគិតដោយប្រមូលផ្តុំនាំឱ្យមានភាពច្បាស់លាស់ចំពោះគោលដៅ

- ✶ បើលើកយកវិស័យកីឡាជាឧទាហរណ៍ (កីឡា Golf) ដើម្បីក្លាយជាអ្នកលេង Golf ដ៏ពូកែ អ្នកលេងនោះចាំបាច់ត្រូវប្រមូលផ្តុំយកចិត្តទុកដាក់លើគោលដៅច្បាស់លាស់ ។
- ✶ ដូចគ្នានឹងការគិតដែរ ការប្រមូលផ្តុំជួយអ្នកឱ្យស្គាល់គោលដៅ និងសម្រេចគោលដៅនោះឱ្យបាន ។

## ៤. ការគិតដោយប្រមូលផ្តុំនឹងនាំអ្នកទៅកាន់គំនិតថ្មី

- ពុំមាននរណាម្នាក់ក្លាយជាអ្នកល្បីដោយក្លាយខ្លួនជាអ្នកឯកទេសទូទៅឡើយ
  - ✶ អ្នកពុំអាចចាប់យកជំនាញណាមួយបានឡើយ ដោយពុំយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍជំនាញនោះ
  - ✶ វិធីតែមួយគត់ដើម្បីទៅដល់កំរិតថ្មី នោះគឺការប្រមូលផ្តុំយកចិត្តទុកដាក់ (Focus)
- មិនថាគោលដៅអ្នកដើម្បីបង្កើតកំរិតនៃការលេង ធ្វើឲ្យផែនការធុរកិច្ចកាន់តែមុត ស្រួច ធ្វើឲ្យល្អប្រសើរនៅថ្នាក់ខាងក្រោម អភិវឌ្ឍន៍អ្នកក្រោមឱវាទ ឬដោះស្រាយ បញ្ហាផ្ទាល់ខ្លួន អ្នកត្រូវការចាំបាច់នូវការប្រមូលផ្តុំយកចិត្តទុកដាក់ ។
- អ្នកនិពន្ធ Harry A. Overstreet កត់សម្គាល់ថា : "គំនិតដែលពុំទាន់ចាស់ទុំលោតពីកន្លែងមួយទៅកន្លែងមួយទៀត គំនិតដែលចាស់ទុំស្វះស្វែងដើរតាមដល់ទីបញ្ចប់" ។

## .តើកន្លែងណាខ្លះដែលត្រូវប្រមូលផ្តុំការគិតរបស់អ្នក

- តើគ្រប់ជង្ហើមនៃជីវិតរបស់អ្នក ចាំបាច់ត្រូវព្យាយាមប្រើពេលវេលាគិតដោយប្រមូលផ្តុំដែរឬទេ ?
  - ✶ ចម្លើយគឺទេ ។ សូមសម្រិតសម្រាំងជ្រើសរើសដើម្បីកុំឲ្យគិតហួសហេតុ
  - ✶ ជាធម្មតា ការប្រើពេលវេលាគិតគួរប្រមូលផ្តុំលើវិស័យ ៤ គឺ :
    - + ការដឹកនាំ
    - + ការច្នៃប្រឌិត
    - + ការប្រាស្រ័យទាក់ទង
    - + ការរៀបចំបណ្តាញ (Intentional networking)

## ១.កំណត់អាទិភាពរបស់អ្នក

- ជាទី១ ត្រូវគិតដល់អាទិភាពរបស់អ្នក ÷ សម្រាប់ខ្លួនឯង សម្រាប់គ្រួសារខ្លួនឯង និងក្រុមខ្លួនឯង

✶ ទីបញ្ចប់គឺជាកន្លែងដែលអ្នកឈប់គិតទៀតហើយ

✶ មនុស្សជាច្រើនគិតដល់អាទិភាពទាំងឡាយដែលធ្វើឱ្យគេរួចចាកផុតពីលោកទឹកក្តៅ

- មានវិធីជាច្រើនដើម្បីកំណត់អាទិភាព

✶ បើស្គាល់ខ្លួនឯងច្បាស់ សូមចាប់ផ្តើមពីការយកចិត្តទុកដាក់លើចំណុចខ្លាំងរបស់ខ្លួន អ្វីៗដែលធ្វើឱ្យប្រើប្រាស់ជំនាញរបស់អ្នកឱ្យបានល្អបំផុត និងទេពកោសល្យដែលព្រះប្រទានឱ្យ

✶ អ្នកត្រូវយកចិត្តទុកដាក់លើអ្វីដែលនាំឱ្យអ្នកបានត្រឡប់មកវិញនូវចំណូល និងរង្វាន់ខ្ពស់បំផុត

✶ សូមធ្វើអ្វីដែលធ្វើឱ្យអ្នករីករាយបំផុត និងសូមធ្វើឱ្យបានល្អបំផុត ។

✶ អ្នកអាចប្រើប្រាស់រូបមន្ត 80/20 ÷ ផ្តល់ការខិតខំ ៨០% របស់អ្នកដើម្បីសម្រេចសកម្មភាពសំខាន់បំផុត ២០%

✶ វិធីមួយទៀត គឺយកចិត្តទុកដាក់លើឱកាសពិសេសដែលអាចនាំឱ្យមានចំណូលសន្ទឹកសន្ធាប់ ÷ ផ្តល់ការយកចិត្តទុកដាក់ទៅលើវិស័យដែលនាំឱ្យមានផ្លែផ្កា

## ២-គេឱ្យឃើញនូវឧបនិស្ស័យរបស់អ្នក

- ពុំមែនសុទ្ធតែមនុស្សទាំងអស់បានដឹងដោយខ្លួនឯង និងចេះប្រើប្រាស់ឱ្យបានល្អនូវជំនាញ ឧបនិស្ស័យ និងទេពកោសល្យរបស់ខ្លួនឯង

✶ ខ្លះចង់ចំណាយពេលវេលាដើម្បីក្លាយជាតារា ដោយពុំបានដឹងថា តើខ្លួនមានជំនាញ ឧបនិស្ស័យ និងទេពកោសល្យផ្ទាល់ខ្លួនប៉ុណ្ណាទេ ហើយក៏ពុំដឹងថាត្រូវចាប់ផ្តើមពីចំណុចណា ត្រូវទៅដល់ចំណុចណាដែរ ។

✶ អ្នកខ្លះគិតឆ្ងាយទៅមុខពេក ដោយពុំដឹងពីគោលដៅចំពោះមុខ (Immediate goal) ម្ល៉ោះហើយអាចប្រឈមនឹងការបាត់បង់គោលដៅ

✶ មានតែអ្នកនៅជុំវិញខ្លួនយើងដូចជា មិត្តភក្តិ និងសមាជិកគ្រួសារជាដើម ដែលដឹងថាយើងពូកែខាងអី

✶ សូមប្រើពេលវេលាគិតដោយផ្ចុះបញ្ចាំងពីជោគជ័យពីអតីតកាល

- ប្រសិនបើអ្នកចង់គិតដោយប្រមូលផ្តុំទៅលើវិស័យដែលខ្លួនអ្នកខ្លាំង អ្នកចាំបាច់ត្រូវដឹងថាខ្លួនអ្នកខ្លាំងលើវិស័យអ្វីខ្លះ

## ៣.៣ទិកសុបិនរបស់អ្នក

- ប្រសិនបើអ្នកចង់សម្រេចបានកិច្ចការដ៏ធំធេង អ្នកចាំបាច់ត្រូវមានសុបិនដ៏ធំធេង

✶ ប្រសិនបើអ្នកពុំច្បាស់លាស់អំពីសុបិនរបស់អ្នក សូមប្រើពេលវេលានៃការគិតដោយប្រមូលផ្តុំរបស់អ្នក ដើម្បីជួយអ្នកឲ្យរកឃើញនូវសុបិននោះ

✶ ប្រសិនបើការគិតរបស់អ្នកវិលត្រឡប់មកលើវិស័យណាមួយច្រើនលើកច្រើនសារ អ្នកប្រហែលជាអាចរកឃើញសុបិនរបស់អ្នកនៅទីនោះ

✶ សូមប្រើពេលវេលានៃការប្រមូលផ្តុំគិត និងមើលឲ្យឃើញនូវអ្វីដែលកើតឡើង

✶ បើអ្នកឃើញនូវក្តីសុបិននោះហើយ សូមបន្តគិតទៅមុខទៀត កុំបីស្ទាក់ស្ទើរសង្ស័យឡើយ (កុំមើលក្រោយ អ្វីមួយនឹងធ្វើឲ្យអ្នកបានចំណេញ)

✶ បើអ្នកនៅកាន់តែក្មេង អ្នកប្រហែលជាយកចិត្តទុកដាក់គិតដោយរាយមាយច្រើនមុខ ។ នេះជារឿងល្អ ព្រោះបើខ្លួនអ្នកនៅក្មេង អ្នកចង់ស្គាល់ខ្លួនឯង ចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួនឯង

✶ បើអ្នកប្រមូលផ្តុំការគិតតែលើរឿងមួយ ហើយបំណងប្រាថ្នារបស់អ្នកបានផ្លាស់ប្តូរ នោះអ្នកត្រូវបង់ខាតនូវថាមពលនៃការគិតដ៏ល្អរបស់អ្នក

✶ ប្រសិនបើអ្នកកាន់តែចាស់ និងកាន់តែមានបទពិសោធន៍ សេចក្តីត្រូវការប្រមូលផ្តុំការគិតក្លាយជារឿងសំខាន់ ។ បើចង់ដើរទៅកាន់តែឆ្ងាយ និងកាន់តែខ្ពស់ អ្នកកាន់តែត្រូវយកចិត្តទុកដាក់គិតជាចាំបាច់បំផុត ។

## ~តើធ្វើយ៉ាងដូចម្ដេចដើម្បីឱ្យខ្លួនអ្នកគិតដោយប្រមូលផ្ដុំបាន

~ ពេលដែលអ្នកដោះស្រាយបានអំពីអ្វីដែលអ្នកគួរគិត រួចហើយអ្នកត្រូវសម្រេចចិត្តថា តើត្រូវយកចិត្តទុកដាក់គិតអំពីបញ្ហានោះយ៉ាងដូចម្ដេច ?

~ មានអនុសាសន៍ ៥ ចំណុច ដែលជួយដល់ដំណើរការនេះបាន :

## ១~ទម្លាក់ចោលការលេងសើច

~ ការទម្លាក់ចោលនូវការលេងសើច គឺជារឿងតូចតាចនៅក្នុងវប្បធម៌របស់យើង តែនេះជារឿងដ៏ពិបាក

~ តើត្រូវធ្វើយ៉ាងដូចម្ដេច ?

ទី១~ ដោយថែរក្សាវិស័យនៃការអនុវត្តតាមអាទិភាពរបស់អ្នក

កុំធ្វើការងារងាយស្រួលមុន (Easy thing first)

កុំធ្វើការងារពិបាកមុន (Hard things first)

កុំធ្វើការងារប្រញាប់មុន (Urgent things first)

ត្រូវធ្វើការងារជាអាទិភាពទី១មុន (First things first)

គឺសកម្មភាពដែលផ្ដល់ឱ្យអ្នកនូវលទ្ធផលខ្ពស់បំផុត (The highest return)។ ធ្វើរបៀបនេះអ្នកអាចថែរក្សាការលេងសើចឱ្យនៅជាអតិបរមា ។

ទី២~ រារាំងខ្លួនឯងកុំឱ្យបែកកម្មដ្ឋាន ចាំបាច់ត្រូវថែរក្សាការកំណត់ពេលវេលា (Blocks of time) ដើម្បីគិតដោយគ្មានការរំខាន ។ ជាសំខាន់ ត្រូវកំណត់ពេលវេលាសម្រាប់គិត និងជ្រើសយកទីកន្លែងសម្រាប់គិត ។ ត្រូវធ្វើឱ្យមានតុល្យភាពរវាងពេលទំនាក់ទំនងជាមួយអ្នកដទៃក្នុងនាមជាអ្នកដឹកនាំ និងពេលវេលាដកថយពីកូនចៅដើម្បីគិត ។

សកម្មភាពទាំងពីរមានតម្លៃដូចគ្នា (ត្រូវផ្ដល់តម្លៃ និងការយកចិត្តទុកដាក់ដូចគ្នា) ÷

~ ដើរកាត់ហ្វូងមហាជននាំឱ្យអ្នកទាក់ទងជាមួយមនុស្ស និងបានដឹងអំពីសេចក្ដីត្រូវការរបស់ពួកគេ ។

- ដកខ្លួនថយពីមហាជន អនុគ្រោះឲ្យអ្នកគិតអំពីវិធីដើម្បីបន្ថែមតម្លៃដល់មនុស្ស ។

## ២-ត្រូវប្រើពេលវេលាសម្រាប់ការគិតដោយប្រុងប្រយ័ត្ន

- ពេលដែលអ្នកមានកន្លែងមួយដើម្បីគិត អ្នកត្រូវការពេលវេលាដើម្បីគិត ។
- តាមល្បឿនដ៏លឿននៃវប្បធម៌របស់យើង មនុស្សមានទំនោរទៅរកពហុភារកិច្ច (People tend to multi-task) ។
    - ✶ ផ្លាស់ប្តូរពីភារកិច្ចមួយទៅកាន់ភារកិច្ចមួយទៀត ធ្វើឲ្យអ្នកអាចបាត់បង់ប្រសិទ្ធផលរហូតដល់ ៤០% ។
    - ✶ តាមអ្នកស្រាវជ្រាវ ប្រសិនបើអ្នកខិតខំសម្រេចរឿងច្រើនក្នុងពេលតែមួយ អ្នកត្រូវធ្វើបានផលច្រើនជាង ដោយយកចិត្តទុកដាក់លើភារកិច្ចមួយក្នុងពេលតែមួយ ពុំមែនដោយផ្លាស់ប្តូរជាដរាបពីភារកិច្ចមួយទៅកាន់ភារកិច្ចមួយទៀត ។
    - ✶ អ្នកខ្លះមានពេលវេលាគិតបានល្អនៅពេលព្រឹក ដូច្នេះត្រូវដកខ្លួនថយចេញពីការងារផ្សេងៗរហូតយ៉ាងតិចដល់ម៉ោង ១០:០០ព្រឹក ដើម្បីគិត ។

## ៣-ថែរក្សារបៀបវារៈនៃការយកចិត្តទុកដាក់ចំពោះមុខអ្នក

- លោក Ralph Waldo Emerson ជាអ្នកគិតដ៏ល្បីជឿថា : ការប្រមូលផ្តុំយកចិត្តទុកដាក់ (Concentration) គឺជាការសម្ងាត់នៃភាពខ្លាំងនៅក្នុងនយោបាយ សង្គ្រាម ពាណិជ្ជកម្ម និយាយឲ្យខ្លីនៅក្នុងការគ្រប់គ្រងកិច្ចការរបស់មនុស្ស ។
- ត្រូវយកចិត្តទុកដាក់ទៅលើរឿងដែលសំខាន់ៗ ហើយត្រូវដាក់របៀបវារៈសំខាន់ៗនៅចំពោះមុខអ្នក ។
- ត្រូវមាន File ឬក្រដាសមួយសន្លឹកនៅលើតុ ដើម្បីអ្នកបានមើលឃើញរបៀបវារៈទាំងនោះនៅពេលអ្នកធ្វើការ ÷ នេះគឺជាយុទ្ធសាស្ត្រដើម្បីជួយឲ្យមានជោគជ័យ ដើម្បីជម្រុញនិងសម្រួចគំនិត ។

## ៤-កំណត់គោលដៅ (Set Goals)

- គោលដៅមានសារសំខាន់ ព្រោះខួរក្បាលពុំអាចផ្តោតលើរឿងអ្វីមួយទាល់តែមានទិសដៅ

ច្បាស់លាស់ (Clear objectives) ។ គោលបំណងនៃគោលដៅ (The purpose of goals) គឺដើម្បីអ្នកផ្តោតការយកចិត្តទុកដាក់ និងផ្តល់ដល់អ្នកនូវទិស (Direction) តែពុំមែនកំណត់អំពីទិសដៅចុងក្រោយឡើយ (Final destination) ។

- ពេលដែលអ្នកគិតអំពីគោលដៅរបស់អ្នក សូមចងចាំថាគោលដៅទាំងនោះត្រូវតែ :
  - ✶ ច្បាស់លាស់គ្រប់គ្រាន់ដើម្បីថែរក្សាការយកចិត្តទុកដាក់
  - ✶ ខិតមកជិតគ្រប់គ្រាន់ដើម្បីសម្រេចបាន
  - ✶ ជួយគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរកែប្រែជីវិត
- ការណែនាំខាងលើនេះធ្វើឱ្យអ្នកធ្វើដំណើរទៅមុខបាន តែត្រូវសរសេរអំពីគោលដៅ
  - ✶ ប្រសិនបើពុំបានសរសេរជាលាយលក្ខណ៍អក្សរ គោលដៅទាំងនោះពិតជាពុំបានយកចិត្តទុកដាក់គ្រប់គ្រាន់ឡើយ
  - ✶ ប្រសិនបើអ្នកមើលទៅក្រោយវិញឃើញថា គោលដៅរបស់អ្នកតូចតាចពេកក៏ដោយ គោលដៅទាំងនោះពិតជាបានបំពេញនូវគោលបំណងរបស់វា យ៉ាងហោចណាស់ផ្តល់នូវទិសសម្រាប់ដំណើរទៅមុខ

## ៥. ចោទសួរអំពីវឌ្ឍនភាពរបស់អ្នក

- ជារឿយៗត្រូវពិនិត្យមើលខ្លួនឯង តើបច្ចុប្បន្នមានភាពរីកចំរើនទៅមុខខ្លះដែរឬអត់ ? នេះជាវិធីដ៏ត្រឹមត្រូវដើម្បីដឹងថា អ្នកប្រើប្រាស់បានល្អនូវការគិតដោយប្រមូលផ្តុំ
- សួរខ្លួនឯង :
  - ✶ តើមើលឃើញអ្វីខ្លះបានមកពីការខិតខំវិនិយោគលើពេលវេលាសម្រាប់គិត ?
  - ✶ តើអ្វីខ្លះកំពុងធ្វើនាំឱ្យអ្នកបានទៅជិតដល់គោលដៅរបស់ខ្លួន ?
  - ✶ តើអ្នកកំពុងធ្វើអ្វីដែលជួយអ្នកឱ្យសម្រេចបាននូវការប្តេជ្ញាចិត្ត ថែរក្សាបាននូវអាទិភាព និងសម្រេចបាននូវសុបិនរបស់អ្នក ?

~**អ្វីដែលអ្នកត្រូវបោះបង់ចោលដើម្បីឡើងបានកាន់តែខ្ពស់ (What Are You Giving Up To Go Up**

- គ្មាននរណាម្នាក់ឡើងទៅកំរិតខ្ពស់បាន ហើយថែរក្សាខ្លួនឲ្យនៅត្រឹមកំរិតជាអ្នកទូទៅបានឡើយ (A generalist)
  - ✶ ត្រូវជ្រើសយករបស់មួយដែលអ្នកធ្វើបានល្អ ហើយកុំធ្វើអ្វីទៀត
  - ✶ បានន័យថា ធ្វើបានល្អលើរបស់តិច ដោយត្រូវបោះបង់របស់ច្រើន :

**អ្នកពុំអាចស្គាល់គ្រប់ៗគ្នាបានឡើយ**

- ទី១ អ្នកត្រូវកំរិតខ្លួនជ្រើសរើសនូវក្រុមមនុស្សស្និទ្ធស្នាលមួយក្រុមដ៏ខ្លាំងពូកែ (A strong inner circle of people) ដែលអាចជួយអ្នកនៅក្នុងមុខវិជ្ជាជីវៈ និងធ្វើឲ្យជីវិតរបស់អ្នកកាន់តែសប្បាយរីករាយ
- ទី២ អ្នកត្រូវកំរិតជ្រើសរើសមិត្តមួយក្រុម ដែលអាចជួយអ្នកឲ្យបានដឹងអំពីមិត្តផ្សេងទៀត
- ធ្វើបែបនេះ វានឹងជួយអ្នកឲ្យមានពេលវេលាចាំបាច់សម្រាប់ការគិតដោយប្រមូលផ្តុំ

**អ្នកពុំអាចធ្វើអ្វីៗគ្រប់បែបយ៉ាងបានឡើយ**

- អ្នកត្រូវខិតខំធ្វើឲ្យខ្លួនល្អប្រសើរលើវិស័យសំខាន់ៗមួយចំនួន ជាជាងខិតខំសម្រេចឲ្យបានល្អលើគ្រប់វិស័យ ÷ នេះជាការចែករំលែកបន្ទុក
- រូបមន្ត ១០-៨០-១០ នៃការធ្វើប្រតិភូកម្ម
  - ✶ អ្នកត្រូវប្រឡូកក្នុង១០% ដំបូង ដោយផ្តល់ចក្ខុវិស័យ, កំណត់សន្ទស្សន៍, ផ្តល់ធនធាន និងលើកទឹកចិត្ត
  - ✶ ៨០% ប្រគល់ឲ្យអ្នកដទៃធ្វើ
  - ✶ កាលណាគេសម្រេចបានជាង ៨០% អ្នកត្រូវប្រឡូកម្តងទៀត (ក្នុងចំណែក១០% ចុងក្រោយរបស់ខ្លួន)ដើម្បីតម្រង់ទិសជាថ្មី ជួយដោះស្រាយបញ្ហា និងលើកទឹកចិត្ត

**<u>អ្នកពុំអាចដើរនៅគ្រប់កន្លែងបានឡើយ</u>**

- នេះជាការពិតដែលអ្នកត្រូវជ្រើសកន្លែង ២០សំខាន់ៗ ក្នុងចំណោមកន្លែងចំនួន ១០០ ដើម្បីជះឥទ្ធិពលដល់គ្រប់កន្លែង

**<u>អ្នកពុំអាចមានព័ត៌មានសព្វគ្រប់បែបយ៉ាងបានឡើយ</u>**

- ៩៩% នៃអ្វីៗនៅក្នុងជីវិត អ្នកពុំចាំបាច់ត្រូវការដឹងសព្វគ្រប់ឡើយ
- សូមសាកល្បងយកចិត្តទុកដាក់ទៅលើព័ត៌មាន១% ដែលនាំឱ្យអ្នកទទួលបាននូវលទ្ធផល ខ្ពស់បំផុត
- ចំពោះព័ត៌មាន ៩៩% ទៀត ទុកឱ្យអ្នកដទៃប្រាប់អ្នក ពេលដែលអ្នកត្រូវការដឹង

×

× ×

- ចង់ជម្រុះចោលនូវរបស់ខ្លះដែលអ្នកស្រឡាញ់ ដើម្បីយកចិត្តទុកដាក់លើអ្វីដែលនាំអ្នកមានឥទ្ធិពលខ្ពស់ គឺជារឿងពុំស្វូវស្រួលប៉ុន្មានឡើយ ។
- អ្នកត្រូវទម្លាប់នឹងរឿងបែបនេះ វានាំឱ្យអ្នកនាំខ្លួនឯងឱ្យទទួលបាននូវសភាពល្អប្រសើរក្នុងពេលដែលអ្នកត្រូវគិតអំពីអ្វីដែលសំខាន់ ។

# ជំពូកទី៣

# ប្រមូលផលពីការគិតដោយច្នៃប្រឌិត

# HARNESS CREATIVE THINKING

- ក្តីរំភើបសប្បាយស្ថិតនៅក្នុងការបង្កើត ពុំមែនស្ថិតនៅក្នុងការថែរក្សាអ្វីដែលមានឲ្យដដែលឡើយ ។
- ការច្នៃប្រឌិតគឺជាមាសសុទ្ធ មិនថាអ្វីជាមុខរបរដែលអ្នកប្រកបដើម្បីចិញ្ចឹមជីវិត ។
- ធនធានដ៏មានតម្លៃបំផុត ដែលអ្នកនាំមកសម្រាប់ការងារ និងក្រុមហ៊ុនរបស់អ្នក នោះគឺការច្នៃប្រឌិតរបស់អ្នក ។

  ◉ សំខាន់ជាងអ្វីដែលត្រូវធ្វើសម្រេចឲ្យបាន

  ◉ សំខាន់ជាងតួនាទីដែលអ្នកត្រូវសម្តែង

  ◉ សំខាន់ជាងឋានៈរបស់អ្នក

  ◉ សំខាន់ជាងលទ្ធផលរបស់អ្នក

  **នេះគឺគំនិតរបស់អ្នក ដែលមានតម្លៃ ។**

- ទោះបីជាសារសំខាន់របស់មនុស្សម្នាក់ៗនោះគឺជាការគិតដោយច្នៃប្រឌិតក្តី មានតែមនុស្សតិចតួចប៉ុណ្ណោះដែលហាក់ដូចជាមានជំនាញនោះដោយបរិបូណ៌ ។
- ប្រសិនបើអ្នកពុំមែនជាអ្នកច្នៃប្រឌិតដូចដែលអ្នកចង់បាន នោះអ្នកអាចកែប្រែរបៀបដែលអ្នកគិត ។

  ◉ *ការគិតដោយច្នៃប្រឌិត ពុំចាំបាច់សុទ្ធតែការគិតដោយមុនគេនោះទេ* (Original thinking)

  ◉ គឺមនុស្សត្រូវរៀបចំវិធីសាស្ត្រនៃគំនិតដំបូង (Original thought)

  ◉ *ជាទូទៅ គំនិតគិតដោយច្នៃប្រឌិត គឺជាការប្រមូលផ្តុំគំនិតដទៃទៀត ដែលរកឃើញនៅតាមដំណើរ (នៃការគិត)*

- សិល្បករដ៏ល្បីៗដែលបពោ្ញញមុនគេនូវស្នាដៃប្លែកៗ តែងតែរៀនអំពីគ្រូរបស់ខ្លួន យកគំរូតាមស្នាដៃរបស់សិល្បករផ្សេងទៀត ហើយទើបផ្គុំគំនិត និងស្ទីលដើម្បីបង្កើតជាស្នាដៃរបស់ខ្លួន ។

## ១-លក្ខណៈវិនិច្ឆ័យរបស់អ្នកគិតដោយច្នៃប្រឌិត

- អ្នកគិតដោយច្នៃប្រឌិតតែងមានលក្ខណៈវិនិច្ឆ័យរួមដូចតទៅ :

### អ្នកគិតដោយច្នៃប្រឌិតតែងផ្តល់តម្លៃដល់គំនិតទាំងឡាយ

- អ្នកគិតដោយច្នៃប្រឌិតជាន់ខ្ពស់ តែងយកចិត្តទុកដាក់ដល់គំនិតទាំងឡាយ
    - ⊙ ពួកគេពុំពឹងផ្អែកតែលើទេពកោសល្យខ្លួនឯងប៉ុណ្ណោះទេ តែពួកគេតែងផ្សារភ្ជាប់ទៅនឹងវិស័យរបស់ខ្លួន
    - ⊙ ការគិតស្រម័យ (Imagination) របស់ពួកគេហាក់ដូចជាស្រទាប់ស្បែកទី២
    - ⊙ ពួកគេដឹងថាត្រូវប្រើប្រាស់ការគិតស្រមៃរបស់ពួកគេឱ្យដល់កំរិតពេញលេញបំផុត
- ការច្នៃប្រឌិតគឺជាការមានគំនិតច្រើន ÷ អ្នកមានគំនិតលុះណាតែអ្នកផ្តល់តម្លៃដល់គំនិតទាំងឡាយ ។

### អ្នកគិតដោយច្នៃប្រឌិតស្វះស្វែងរកជម្រើស

- ស្វះស្វែងរកលទ្ធភាពឱ្យបានច្រើន ជួយជម្រុញឱ្យមានការគិតស្រមៃ ការគិតស្រមៃគឺវាចាំបាច់បំផុតសម្រាប់ការច្នៃប្រឌិត ។
- លោក Albert Einstein : "ការគិតស្រមៃវាសំខាន់ជាងចំណេះដឹង"
- ត្រូវផ្តល់តម្លៃដល់ជម្រើស ពីព្រោះជម្រើសទាំងនេះនាំឱ្យមានចម្លើយដ៏ល្អបំផុត ហើយពុំមែនជាជម្រើសតែមួយឡើយ ។
- អ្នកគិតដ៏ពូកែតែងមានចម្លើយដ៏ល្អប្រសើរបំផុត ពួកគេតែងបង្កើតផែនការបម្រុង (Back up plans) ដែលផ្តល់ជម្រើសដល់ពួកគេ ។ ពួកគេមានសេរីភាពដែលអ្នកដទៃគ្មាន ។

ពួកគេមានឥទ្ធិពលនឹងដឹកនាំអ្នកដទៃ ។

**អ្នកគិតដោយច្នៃប្រឌិតទទួលយកភាពស្រពិចស្រពិល**

- អ្នកនិពន្ធ H.L Mencken "មានតែមនុស្សអត់បានការដែលតែងតែជាក់ច្បាស់ ហើយមនុស្សជាក់ច្បាស់តែងតែជាមនុស្សអត់បានការ"
- អ្នកគិតដោយច្នៃប្រឌិត ពុំមានអារម្មណ៍ចាំបាច់ទាត់ចោលនូវភាពស្រពិចស្រពិលឡើយ
- ពួកគេមើលឃើញនូវភាពមិនជាប់លាប់សព្វប្រភេទ (All kinds of inconsistencies) និងភាពចន្លោះប្រហោង (Gap) នៅក្នុងជីវិត
- ពួកគេចាប់អារម្មណ៍ស្វះស្វែងរកនូវភាពចន្លោះប្រហោងនោះ ឬប្រើប្រាស់នូវក្ដីស្រមៃរបស់ពួកគេ ដើម្បីបំពេញនូវចន្លោះប្រហោងទាំងនោះ

**អ្នកគិតដោយច្នៃប្រឌិត អបអរសាទរនូវភាពប្លែកមិនធម្មតា**

- តាមធាតុពិត ការច្នៃប្រឌិតតែងស្វះស្វែងរកអ្វីថ្មីចេញពីផ្លូវដែលធ្លាប់ដើរ ហើយដើរទៅដល់កន្លែងទុញទ័ល
- វាមានភាពផ្សារភ្ជាប់គ្នារវាងការច្នៃប្រឌិត និងភាពប្លែកមិនធម្មតា
- ដើម្បីជម្រុញការច្នៃប្រឌិតនៅក្នុងខ្លួនអ្នក ឬក្នុងខ្លួនអ្នកដទៃ ត្រូវអត់ឱនចំពោះភាពអាក្រក់ខ្លះៗ

**អ្នកគិតដោយច្នៃប្រឌិតតភ្ជាប់ទៅកន្លែងដែលពុំធ្លាប់តភ្ជាប់**

- ដោយហេតុថា ការច្នៃប្រឌិតប្រើប្រាស់នូវគំនិតរបស់អ្នកដទៃ វាមានតម្លៃបំផុតពេលណាអាចតភ្ជាប់គំនិតមួយទៅគំនិតមួយទៀត ជាពិសេស គំនិតដែលហាក់ដូចមិនពាក់ព័ន្ធគ្នា
- ការច្នៃប្រឌិតសម្ដែងឡើងជាពិសេស តាមសមត្ថភាពចងភ្ជាប់គ្នា (Make connections) ចងផ្គុំគ្នា (Make associations) ដើម្បីប្រែក្លាយជារបស់ថ្មី និងចេញជារូបភាពតាមរបៀបថ្មី

- បង្កើតគំនិតបន្ថែម គឺដូចជាការធ្វើដំណើរតាមរថយន្តរបស់អ្នក : អ្នកដឹងថាអ្នកត្រូវធ្វើដំណើរទៅទីណា ។ តែក្នុងពេលអ្នកធ្វើចលនាទៅកាន់គោលដៅ (Destination) អ្នកអាចមើលឃើញ និងជួបប្រទះរឿងផ្សេងៗ ដែលអ្នកពុំអាចឃើញនៅមុនពេលអ្នកចេញដំណើរ ។ ការគិតដោយច្នៃប្រឌិតកើតឡើងតាមរបៀបដូចខាងក្រោមនេះ :

**គិត → ប្រមូល → បង្កើត → កែតម្រូវ → ផ្សារភ្ជាប់**
**Think → Collect → Create → Correct → Connect**

- ពេលដែលអ្នកចាប់ផ្ដើមគិតអ្នកមានសេរីភាពដើម្បីប្រមែប្រមូល អ្នកសួរខ្លួនឯង : តើមានអ្វីខ្លះដែលពាក់ព័ន្ធនឹងគំនិតនេះ កាលណាអ្នកមាននូវអ្វីនោះហើយ អ្នកសួរ : តើត្រូវមានគំនិតអ្វីខ្លះដែលធ្វើឱ្យការគិតនោះកាន់តែល្អឡើង ? នេះជាការចាប់ផ្ដើមនូវគំនិតទៅកាន់កិរិតបន្ទាប់ ។ ក្រោយពីនោះ អ្នកអាចកែតម្រូវ ឬកែលំអនូវគំនិតនោះដោយសួរថា តើអាចត្រូវកែប្រែឡើងទាំងនេះយ៉ាងដូចម្ដេចដើម្បីឱ្យវាកាន់តែល្អថែមទៀត ។ ជាចុងក្រោយអ្នកផ្សារភ្ជាប់គំនិតទាំងនេះ ដោយដាក់គំនិតទៅក្នុងទីតាំងនៃបរិបទមួយដ៏ត្រឹមត្រូវ ដើម្បីធ្វើឱ្យគំនិតនោះពេញលេញ និងមានឥទ្ធិពល ។

**<u>អ្នកគិតដោយច្នៃប្រឌិតពុំភ័យខ្លាចចំពោះបរាជ័យ</u>**

- ការច្នៃប្រឌិតត្រូវការនូវសមត្ថភាពដែលពុំភ័យខ្លាចចំពោះបរាជ័យ ពីព្រោះការច្នៃប្រឌិតវាស្មើនឹងការបរាជ័យ
- ការប្រួយបារម្ភ គឺជាល័ក្ខខ័ណ្ឌជាសារវ័ន្តនៃការបង្កើតខាងប្រាជ្ញា និងសិល្បៈ
- ការច្នៃប្រឌិតតម្រូវឱ្យមានបំណងប្រាថ្នា ឱ្យគេឃើញថាខ្លួនអន់ថយ រំដោះខ្លួនឱ្យរួចចេញពីមែកឈើ ព្រោះដឹងថាមែកឈើជាញឹកញយតែងតែបាក់ ។
- មនុស្សច្នៃប្រឌិតដឹងពីរឿងរ៉ាវអស់នេះ ហើយតែងតែបន្តខិតខំស្វែងរកគំនិតថ្មី ។ ពួកគេពុំទុកឱ្យគំនិតដែលពុំបានការរារាំងពួកគេពុំឱ្យរកឃើញនូវគំនិតថ្មីដែលបានការឡើយ ។

## ~តើហេតុដូចម្តេចបានជាអ្នកគួរតែរកឱ្យឃើញនូវក្តីសប្បាយរីករាយនៃការគិតដោយច្នៃប្រឌិត
**(Why You Should Discover The Joy Of Creative Thinking)**

ការច្នៃប្រឌិតអាចធ្វើឱ្យគុណភាពនៃជីវិតរបស់មនុស្សកាន់តែល្អប្រសើរ ។

មាន ៥រឿង ដែលការគិតដោយច្នៃប្រឌិតអាចជួយដល់រូបអ្នក :

### ១~ការគិតដោយច្នៃប្រឌិតបង្កើតតម្លៃដល់អ្វីៗទាំងអស់

- តើអ្នកមិនសប្បាយចិត្តទេឬ បើពេលណាមួយខួរក្បាលអ្នកបញ្ចេញនូវគំនិតថ្មីណាមួយឱ្យអ្នក ? នេះហើយគឺជាលទ្ធផលនៃការគិតដោយច្នៃប្រឌិត ។ ចំពោះអ្វីដែលអ្នកកំពុងធ្វើ ការច្នៃប្រឌិតអាចបង្កើនសមត្ថភាពរបស់អ្នក ។
- ការច្នៃប្រឌិតនាំឱ្យមើលឃើញនូវអ្វីដែលអ្នកដទៃបានមើលឃើញ ហើយគិតអំពីបញ្ហាដែលអ្នកដទៃពុំបានគិត ដូច្នេះអ្នកអាចធ្វើអ្វីដែលអ្នកដទៃពុំបានធ្វើ ។
- ពេលខ្លះការច្នៃប្រឌិតជាប់ពាក់ព័ន្ធនឹងការបង្កើតថ្មី (Invention) ជាកន្លែងដែលអ្នករកឃើញថ្មី (New ground) ។
- ពេលខ្លះទៀត ការច្នៃប្រឌិតជាប់ពាក់ព័ន្ធនឹងការកែប្រែថ្មី (Innovation) ដែលជួយអ្នកឱ្យធ្វើកិច្ចការចាស់ តាមរបៀបថ្មី ។
- តាមរបៀបណាក៏ដោយ គឺជាការមើលឃើញពិភពលោកដោយគ្រប់គ្រាន់តាមភ្នែកថ្មី (New eyes) ដូច្នេះដំណោះស្រាយថ្មីកើតឡើង : នោះហើយគឺជាការបង្កើតតម្លៃបន្ថែម។

### ២~ការច្នៃប្រឌិតគួបផ្សំថ្មី

- ការគិតដោយច្នៃប្រឌិតគឺជាការងារដ៏លំបាក ប៉ុន្តែការគិតដោយច្នៃប្រឌិតនេះ រួមគួបផ្សំផ្គុំដោយគ្រប់គ្រាន់នូវពេលវេលា និងការយកចិត្តទុកដាក់ (Time and focus) ។
- លោកកវី Maya Angelou កត់សម្គាល់ថា : "អ្នកពុំអាចប្រើប្រាស់នូវការច្នៃប្រឌិតរបស់ខ្ញុំបានឡើយ ។ កាលណាអ្នកកាន់តែប្រើប្រាស់នូវការច្នៃប្រឌិត នោះអ្នកកាន់តែមាននូវការច្នៃប្រឌិត ។ តែជាញឹកញាប់បំផុត ការច្នៃប្រឌិតកាន់តែរលូន ជាជាងកាន់តែទុំជោរ ។

នោះគឺជាបរិយាកាសដែលក្នុងនោះរបៀបគិតថ្មីៗ យល់ដឹងថ្មីៗ ចោទសួរថ្មីៗត្រូវបានជម្រុញឡើង" ។

- ប្រសិនបើអ្នកបណ្តុះនូវការគិតដោយច្នៃប្រឌិត នៅក្នុងបរិស្ថានមួយដែលធ្វើឱ្យការច្នៃប្រឌិតរុំដារឡើង នោះពុំមានការនិយាយប្រាប់អំពីគំនិតប្រភេទណាដែលអ្នកបញ្ចេញឡើងឡើយ ។

## ៣_ការគិតដោយច្នៃប្រឌិតទាក់ទាញមនុស្សឱ្យមករកអ្នក និងគំនិតរបស់អ្នក

- ការច្នៃប្រឌិតគឺជាប្រាជ្ញាដែលមានក្តីរីករាយ។ មនុស្សឱ្យតម្លៃទៅលើប្រាជ្ញា (Intelligence) ហើយមនុស្សតែងត្រូវទាក់ទាញទៅកាន់ក្តីរីករាយ (Fun) ដូច្នេះការជួបជុំគ្នាគឺអស្ចារ្យណាស់ ។
- ពហុភាពនៃគំនិត និងជំនាញបណ្តុះនូវស្មារតី (Mind) ប្រសិនបើអ្នកបណ្តុះនូវការច្នៃប្រឌិត អ្នកនឹងក្លាយជាអ្នកទាក់ទាញមនុស្សដទៃ ពួកគេនឹងត្រូវបានទាក់ទាញឱ្យទៅរករូបអ្នក ។

## ៤_ការគិតដោយច្នៃប្រឌិតជួយឱ្យអ្នករៀនបានច្រើន

- ការច្នៃប្រឌិតគឺជាក្តីរីករាយ ដោយពុំបានយល់ដឹងអ្វីទាំងអស់ ។ ការរីករាយនៃការពុំយល់ដឹងអ្វីទាំងអស់ គឺយោងទៅលើប្រការដែលថា កម្រណាស់ដែលយើងមានគ្រប់ចម្លើយទាំងអស់ ។ យើងតែងមានសមត្ថភាពជានិច្ចដើម្បីបង្កើតនូវដំណោះស្រាយកាន់តែច្រើនអំពីបញ្ហាណាមួយនោះ ។
- ជាអ្នកច្នៃប្រឌិតគឺមានសមត្ថភាពមើល ឬនឹកស្រមៃអំពីឱកាសដ៏ច្រើនសម្រាប់ជីវិតផ្ទាល់ខ្លួន ។ ការច្នៃប្រឌិត គឺវាមានជម្រើសនានា ។
- ប្រសិនបើអ្នកស្វែងរកគំនិតថ្មីៗ នោះអ្នកនឹងបានរៀនសូត្រ ។ ការច្នៃប្រឌិតអាចរៀនសូត្របាន ។ គឺជាការមើលឃើញនូវដំណោះស្រាយជាជាងមើលឃើញតែបញ្ហា ។ កាលណាគំនិតកាន់តែមានគុណភាពខ្ពស់ នោះសំណាងនៃការរៀនសូត្រអ្វីថ្មីកាន់តែមានច្រើន ។

## ៥_ការគិតដោយច្នៃប្រឌិត ប្រឈមនឹងការរក្សាស្ថានភាពដដែល

- ប្រសិនបើអ្នកចង់លើកតម្កើងពិភពលោករបស់អ្នក ឬក៏ស្ថានភាពរបស់អ្នក នោះការច្នៃ

ប្រឌិតនឹងជួយអ្នក ។

- ការច្នៃប្រឌិត និងការរក្សាស្ថានភាពដដែល (Status quo) គឺវិសមិតភាពគ្នា ។ ការច្នៃប្រឌិត និងការកែប្រែថ្មី (Innovation) តែងដើរទន្ទឹមគ្នា ។

## ~តើរកឃើញគន្លឹះការរាយនៃការគិតដោយច្នៃប្រឌិតយ៉ាងដូចម្ដេច

### ១~ជម្រុះចោលនូវពួកឃាតករនៃការច្នៃប្រឌិត

- អ្នកត្រូវបំបាត់ចោលនូវអាកប្បកិរិយាដែលបន្ទាបតម្លៃនៃការគិតដោយច្នៃប្រឌិត
- ឃ្លាខាងក្រោមនេះ គឺជាអ្នកសម្លាប់នូវការគិតដោយច្នៃប្រឌិត :
  - ✶ ខ្ញុំពុំមែនជាអ្នកគិតដោយច្នៃប្រឌិតឡើយ
  - ✶ ធ្វើតែតាមច្បាប់ទៅ
  - ✶ កុំសាកសួរសំណួរអី
  - ✶ ស្ថិតនៅក្នុងខ្សែបន្ទាត់កំណត់បានហើយ
  - ✶ មានវិធីតែមួយ៉ាងប៉ុណ្ណោះ
  - ✶ កុំឆ្កួតពេក
  - ✶ សូមឲ្យជាក់ស្តែង
  - ✶ សូមឲ្យម៉ឺងម៉ាត់
  - ✶ គិតតែអំពីរូបអ្នកទៅ
  - ✶ វាពុំសមហេតុផល
  - ✶ វាមិនជាក់ស្តែង
  - ✶ វាមិនអាចធ្វើកើតទាល់តែសោះ
  - ✶ វាមិនអាចធ្វើកើតទេ
  - ✶ ពួកយើងធ្លាប់សាកពីមុនហើយ
  - ✶ វាធ្វើឲ្យរវល់ច្រើនណាស់

✶ យើងពុំអាចធ្វើកំហុសបានទេ

✶ វាពិបាកនឹងគ្រប់គ្រងណាស់

✶ យើងពុំមានពេលវេលាទេ

✶ បាទ...... ប៉ុន្តែ

✶ ការលេងសើចអត់បានការ

✶ បរាជ័យគឺទីបញ្ចប់ហើយ

- ប្រសិនបើអ្នកគិតថា អ្នកមានគំនិតធំមួយ សូមកុំឱ្យអ្នកដទៃបញ្ចុះបញ្ចូលអ្នកដកនូវគំនិតនោះចេញបានឱ្យសោះ ទោះបីគំនិតនោះហាក់ដូចជាឆ្កួតៗក្តី ។
- កុំទុកឱ្យអ្នកដទៃនាំខ្លួនអ្នកឱ្យជំពាក់ខ្លួននឹងពួកឃាតករនៃការច្នៃប្រឌិត ។
- អ្នកពុំអាចធ្វើអ្វីថ្មី និងរំភើបចិត្តបានឡើយ ប្រសិនបើអ្នកបេះបង្ខំខ្លួនឯងឱ្យស្ថិតនៅក្នុងរូងចាស់ដដែល ។
- សូមកុំខិតខំធ្វើការខ្លាំងទៅលើរឿងចាស់ៗដដែលៗ សូមធ្វើការផ្លាស់ប្តូរកែប្រែ ។

## ២-គិតដោយច្នៃប្រឌិត ដោយការសាកសួរសំណួរដ៏ត្រឹមត្រូវ

- ការច្នៃប្រឌិត ជាភាគធំគឺជាការសាកសួរដោយសំណួរដ៏ត្រឹមត្រូវ ។
- ស្មារតីមិនច្នៃប្រឌិតអាចដោះរកតែសំណួរខុសៗ គឺមានតែច្នៃប្រឌិតដោះរកតែសំណួរដ៏ត្រឹមត្រូវ ។

✶ សំណួរខុសៗពន្លត់ដំណើរការនៃការគិតដោយច្នៃប្រឌិត

✶ សំណួរខុសៗនាំឱ្យអ្នកគិតធ្លាក់ទៅផ្លូវដដែល ឬជម្រុញឱ្យពួកគេជឿថា ការគិតវាពុំចាំបាច់ឡើយ

- ការគិតដោយច្នៃប្រឌិតជម្រុញឡើងតាមការសួរខ្លួនឯងនូវសំណួរដូចជា :

✶ ហេតុម៉េចបានជាត្រូវធ្វើតាមរបៀបនេះ ?

✶ តើអ្វីជាឫសគល់នៃបញ្ហា ?

✶ តើអ្វីជាបញ្ហានៅខាងក្នុង ?

✶ តើអ្វីនាំឲ្យខ្ញុំរំលឹកពីរឿងនេះ ?

✶ តើអ្វីទៅជួយពីនេះ ?

✶ តើជាកត្តាតំណាង ឬនិមិត្តរូបដែលជួយឲ្យបានយល់អំពីរឿងនេះដែរឬទេ ?

✶ តើហេតុអ្វីបានជារឿងនេះវាសំខាន់ ?

✶ តើរបៀបណាដែលពិបាកបំផុត ឬចុះលុយបំផុតដើម្បីធ្វើរឿងនេះ ?

✶ តើអ្នកណាដែលមានទស្សនៈវិស័យខុសប្លែកពីរឿងនេះ ?

✶ តើអ្វីនឹងកើតឡើង ប្រសិនបើយើងពុំធ្វើអ្វីសោះពីរឿងនេះ ?

- នេះគ្រាន់តែជាគំនិត ដែលអ្នកអាចមានគំនិតសាកសួរខ្លួនឯងនូវសំណួរដ៏ល្អៗ ។
- ប្រសិនបើអ្នកពុំសាកសួរ "ហេតុអ្វី why this" ឲ្យបានញឹកញាប់ទេ អ្នកដទៃនឹងសាកសួរ "ហេតុអ្វីបានជារូបអ្នក why you" ។
- ប្រសិនបើអ្នកចង់គិតដោយច្នៃប្រឌិត អ្នកត្រូវសាកសួរដោយសំណួរល្អៗ..។ អ្នកត្រូវតែប្រឈមនឹងដំណើរការ ។

## ៣-បង្កើតនូវបរិស្ថាននៃការច្នៃប្រឌិត

- គំនិតថ្មីតែងតែងាយដុយស្រួយ វាអាចសម្លាប់ដោយការមើលងាយ(A sneer) ឬការស្ងាប (A yawn) វាអាចត្រូវមួលកសម្លាប់ដោយពាក្យកំប្លែងយ៉ាងមុត (A quip) និងត្រូវព្រួយដល់ស្លាប់ដោយការជ្រួញចិញ្ចើមលើថ្ងាសផ្នែកខាងស្តាំរបស់មនុស្សម្នាក់ ។
- បរិយាកាសប្រកបដោយការច្នៃប្រឌិតដូចជាផ្ទះកញ្ចក់ ដែលគំនិតត្រូវបានបណ្តុះពន្លកឡើង និងរីក ។
- បរិស្ថានដោយច្នៃប្រឌិត :

  ✶ ជម្រុញការច្នៃប្រឌិត

- ការសិក្សាអំពីការច្នៃប្រឌិតបង្ហាញថា កត្តាអស្ចារ្យបញ្ជាក់ថា និយោជិតចេះច្នៃប្រឌិតឬអត់ ស្ថិតនៅត្រង់ពួកនិយោជិតទាំងនោះយល់ថា គេមានសេចក្តីអនុញ្ញាតដែរឬអត់

- កាលណាការបង្កើតថ្មី (Innovation) និងការគិតដោយល្អត្រូវបានលើកទឹកចិត្ត និងផ្តល់រង្វាន់នោះ ពេលនោះមនុស្សនឹងឃើញថា ពួកគេមានសេចក្តីអនុញ្ញាតដើម្បីច្នៃប្រឌិត

  ✶ ផ្តល់តម្លៃខ្ពស់ទៅលើជំនឿទុកចិត្តក្នុងចំណោមសមាជិកក្រុម និងបុគ្គល

- ការច្នៃប្រឌិតតែងមានហានិភ័យនៃការបរាជ័យ ។ ដូច្នេះជំនឿទុកចិត្តមានសារសំខាន់ណាស់ចំពោះមនុស្សច្នៃប្រឌិត ។
- នៅក្នុងដំណើរការច្នៃប្រឌិត ជំនឿទុកចិត្តកើតចេញមកពីមនុស្សដែលធ្វើការរួមគ្នា ពីការដឹងថា មនុស្សនៅក្នុងក្រុមធ្លាប់មានបទពិសោធន៍ផ្តើមគំនិតដោយជោគជ័យ និងដោយច្នៃប្រឌិត ហើយពីការធានាថា គំនិតច្នៃប្រឌិតទាំងឡាយនឹងមិនអសារបង់ ព្រោះគំនិតទាំងនោះនឹងយកទៅដាក់អនុវត្ត ។

✶ **<u>ឧបក្រសោបអ្នកដែលច្នៃប្រឌិត</u>**

- មនុស្សដែលច្នៃប្រឌិតតែងអបអរដល់ភាពប្លែកមិនធម្មតា ។
- តើត្រូវរាប់រកអ្នកគិតដោយច្នៃប្រឌិតយ៉ាងដូចម្តេច ?
- "ដកចេញនូវប្រាក់ដុល្លា ពូនជ្រុំគ្រាប់" ÷ ត្រូវចំណាយពេលជាមួយអ្នកច្នៃប្រឌិត រៀបមនុស្សឲ្យប្រជុំ(Brainstorming session) ព្រោះនាំមកនូវថាមពល គំនិត និងសំណើប ។ ធ្វើបែបនេះវាចាំបាច់សម្រាប់គម្រោងថ្មី សិក្ខាសាលា ឬយុទ្ធសាស្ត្រធុរកិច្ច ។

✶ **<u>យកចិត្តទុកដាក់លើការកែប្រែថ្មី (Innovation) ដោយពុំត្រឹមតែការបង្កើតថ្មី (Invention)</u>**

- គំនិតថ្មីសុទ្ធសាធតែងតែកម្រ (Groundbreaking idea) តែអ្នកពុំត្រូវការត្រឹមតែគំនិតមួយប៉ុណ្ណោះដើម្បីឲ្យអាជីពរបស់អ្នកប្រកបដោយការច្នៃប្រឌិត ។
- ការច្នៃប្រឌិតគឺជាការគួបផ្សំដោយសមហេតុផលដោយអង្គធាតុពីរ ឬច្រើនជាងនេះ ដើម្បីឲ្យមានលទ្ធផលជាទស្សនៈថ្មី ។

- វិធីដ៏ប្រសើរដើម្បីឲ្យជីវិតរបស់អ្នករស់រានជាមួយប្រឌិតញាណ(មនោគតិ) គឺត្រូវពង្រីកការអនុវត្តតាមការកែប្រែថ្មី ដោយពុំត្រឹមតែប្រើប្រាស់ប្រឌិតញាណដើម្បីទស្សនៈថ្មីៗតែមួយមុខនោះ ។
- អ្នកច្នៃប្រឌិតនិយាយថា : សូមផ្តល់ឲ្យខ្ញុំនូវគំនិតល្អរបស់អ្នក ខ្ញុំនឹងផ្តល់ឲ្យអ្នកវិញនូវគំនិតដ៏ប្រសើរ ។

✵ **<u>មានបំណងប្រាថ្នាអនុញ្ញាតឲ្យមនុស្សបើកចេញពីខ្សែបន្ទាត់</u>**

- ជាស្វ័យប្រវត្តិ មនុស្សជាច្រើនតែងស្ថិតនៅក្នុងរង្វង់នៃខ្សែបន្ទាត់ ទោះបីជាខ្សែបន្ទាត់ទាំងនោះគូសដោយទំនើងចិត្ត ឬក៏ហួសសម័យក៏ដោយ ។
- សូមចងចាំថា ការកំណត់ជាច្រើន(Limitations) ដែលយើងប្រឈមមុខ ពុំមែនអ្នកដទៃដាក់មកលើយើងឡើយ គឺយើងតែងដាក់កំរិតខ្លួនឯង ។ ការខ្វះការច្នៃប្រឌិតតែងធ្លាក់ចូលទៅក្នុងប្រភេទនេះ ។
- ប្រសិនបើអ្នកចង់ក្លាយជាអ្នកពូកែច្នៃប្រឌិត សូមប្រចាំងនឹងព្រំដែនកំណត់ ។
- ប្រវត្តិនៃការអភិវឌ្ឍរបស់មនុស្សទាំងអស់ ទោះបីជារូបភាពណាក៏ដោយ ត្រូវតែនៅក្រៅបទបញ្ញត្តិ បើពុំនោះទេយើងនឹងគ្មានអ្វីថ្មីបានទេ ។ បរិស្ថានច្នៃប្រឌិតក៏ត្រូវគិតដល់ប្រការនេះដែរ ។

✵ **<u>វាយតម្លៃដល់អំណាចនៃក្តីស្រម៉ៃ</u>** (A Dream)

- បរិស្ថានច្នៃប្រឌិតជម្រុញដល់សេរីភាពនៃក្តីស្រមៃ ។
- បរិស្ថានច្នៃប្រឌិតជម្រុញដល់ការប្រើប្រាស់ក្រដាសស និងសំណួរថា "ប្រសិនបើយើងចង់គូររូបអំពីអ្វីដែលយើងចង់ឲ្យបានសម្រេចនោះ តើរូបភាពនោះនឹងជារូបអ្វី ?"
- លោក Luther King, Jr និយាយថា I have a dream ពុំមែន I have a goal ឡើយ។ គោលដៅ(Goals) អាចឲ្យមានការយកចិត្តទុកដាក់ តែក្តីស្រម៉ៃផ្តល់នូវអំណាច ។
- អ្នកស្រមៃគឺជាអ្នកសង្គ្រោះពិភពលោក (Dreamers are the saviors of the world)

- កាលណាអ្នកអាចធ្វើឱ្យបរិយាកាសច្នៃប្រឌិតកាន់តែអនុគ្រោះ នោះសក្តានុពលកាន់តែច្រើនសម្រាប់ក្លាយជាការច្នៃប្រឌិត ។

## ✲ ចំណាយពេលវេលាជាមួយមនុស្សច្នៃប្រឌិតឯទៀត

- តើអ្វីនឹងកើតឡើងប្រសិនបើអ្នកធ្វើការនៅក្នុងបរិស្ថានមួយដែលប្រឆាំងទៅនឹងការច្នៃប្រឌិត ហើយអ្នកលទ្ធភាពតិចតួចប៉ុណ្ណោះដើម្បីកែប្រែវា ?
  - ✶ លទ្ធភាពមួយគឺត្រូវផ្លាស់ប្តូរការងារ
  - ✶ តែបើអ្នកចង់ធ្វើការនៅកន្លែងនោះដដែល ទោះបីជាបរិស្ថាននៅទីនោះអវិជ្ជមានក្តី ។ ជម្រើសគឺស្វែងរកបៀបមួយដើម្បីបានចំណាយពេលវេលាជាមួយមនុស្សច្នៃប្រឌិតឯទៀត ។
- ការច្នៃប្រឌិតគឺចម្លងដាក់គ្នា ។ តើអ្នកដែលកត់សម្គាល់ដែរទេថា អ្វីនឹងកើតឡើងនៅក្នុងការប្រជុំ Brainstorming ដ៏ល្អមួយនោះ ? មនុស្សម្នាក់បញ្ចេញនូវគំនិតមួយ ។ មនុស្សម្នាក់ទៀតយកគំនិតនេះធ្វើជាមូលដ្ឋានដើម្បីរកឃើញគំនិតមួយទៀត ។ ម្នាក់ទៀតច្បាមគំនិតនេះដើម្បីរកឃើញគំនិតថ្មីមួយទៀតដែលកាន់តែប្រសើរ ព្រមទាំងមានទិសសម្រាប់ទៅមុខ ។
- ការលេងល្បែងគំនិតបែបនេះ (Interplay of ideas) គឺចង់គ្នាដូចអគ្គិសនីអញ្ចឹង ។
- ត្រូវចំណាយពេលជាទៀងទាត់ជាមួយក្រុមមនុស្សច្នៃប្រឌិតដ៏ពូកែ ដើម្បីមានអារម្មណ៍ខ្លាំងពូកែ មានគំនិត និងមើលឃើញអ្វីៗប្លែកពីគេឯទៀត ÷ នេះជារឿងចាំបាច់សម្រាប់ជីវិតអ្នក ។
- សូមអ្នកគិតមើល តើមនុស្សណាម្នាក់ដែលអ្នកមានពេលវេលាច្រើនជាមួយ ។ កាលណាអ្នកចំណាយពេលវេលាកាន់តែច្រើនជាមួយមនុស្សច្នៃប្រឌិត ដែលធ្វើការពាក់ព័ន្ធនឹងសកម្មភាពច្នៃប្រឌិត អ្នកនឹងកាន់តែច្នៃប្រឌិតឡើង ។

## ៥_ចេញពីប្រអប់របស់អ្នក

- ប្រសិនបើអ្នកគោរពច្បាប់ទាំងអស់ អ្នកនឹងបាត់បង់ការសប្បាយទាំងអស់ ។ ក្នុងពេលដែល

អ្នកគិតថាវាពុំចាំបាច់នឹងបំពានលើច្បាប់ទាំងអស់ឡើយ (ព្រោះច្បាប់ជាច្រើនត្រូវបានបង្កើតឡើងដើម្បីការពារខ្លួនយើង) អ្នកពិតជាមិនឈ្លាសវៃឡើយ ប្រសិនបើគិតតែដាក់កំរិតខ្លួនឯងដើម្បីបំផ្លាញខ្លួនឯង ។ អ្នកគិតដោយច្នៃប្រឌិតដឹងថា ពួកគេតែងតែជារឿយៗទម្លុះ "ប្រអប់"ចេញពីការកំរិតនៃប្រវត្តិផ្ទាល់ខ្លួន ដើម្បីពិសោធន៍ និងការរកឃើញនូវគំនិតច្នៃប្រឌិត ។

- វិធីដ៏មានប្រសិទ្ធភាពដើម្បីជួយអ្នកឱ្យចេញក្រៅ "ប្រអប់" គឺដាក់ខ្លួនអ្នកចំពោះមុខការប្រឈមថ្មីៗ (New paradigms) ។
    - ✶ វិធីមួយ គឺអ្នកអាចធ្វើបានតាមរយៈការធ្វើដំណើរទៅកន្លែងផ្សេងៗ ។
    - ✶ សិក្សាវប្បធម៌ ប្រទេស និងប្រពៃណីផ្សេងៗ ។
    - ✶ ស្វែងយល់ថាតើប្រជាជនដទៃខុសពីអ្នករស់នៅ និងគិតយ៉ាងដូចម្តេច ?
    - ✶ វិធីមួយទៀត គឺអានរឿងថ្មីៗដោយចេះចូល់ ចង់ដឹង និងចូលចិត្តរៀន ជាពិសេសសៀវភៅអំពីការដឹកនាំ ។
    - ✶ ជួនកាល យើងអានសៀវភៅដើម្បីពង្រីកការគិតរបស់យើង ដើម្បីឱ្យជីវិតយើងកាន់តែមានតម្លៃឡើង ។
    - ✶ ប្រសិនបើអ្នកចង់ទម្លុះ "ប្រអប់"របស់អ្នក សូមគិតចំចូលទៅក្នុង "ប្រអប់"អ្នកដទៃដោយត្រូវអានយ៉ាងច្រើន និងដោយទូលំទូលាយ ។
    - ✶ មនុស្សជាច្រើនគិតខុសថា បើបុគ្គលនោះកើតមកដោយពុំបានស្លាយការច្នៃប្រឌិតមកជាមួយ មនុស្សនោះពុំអាចក្លាយជាអ្នកច្នៃប្រឌិតបានឡើយ
        - ο នេះជារឿងពុំពិត ព្រោះមានយុទ្ធសាស្ត្រ និងឧទាហរណ៍ជាច្រើនដែលបញ្ជាក់ថា ការច្នៃប្រឌិតអាចបណ្តុះឡើងបាននៅក្នុងបរិស្ថានគាំទ្រដ៏ត្រឹមត្រូវមួយ (In the right supportive environment) ។

✕

✕ ✕

Plan A
Plan B

# ជំពូកទី៤

# ប្រើប្រាស់ការគិតដោយប្រាកដនិយម

# EMPLOY REALISTIC THINKING

- ការទទួលខុសត្រូវទី១ របស់អ្នកដឹកនាំ គឺការកំណត់អំពីការពិត
- ជាធម្មតា គេតែងតែជៀសវាងការគិតដោយប្រាកដនិយម ព្រោះគេគិតថា ការគិតបែបនេះរំខានដល់ការគិតដោយច្នៃប្រឌិត ។ តាមពិត ការគិតដោយប្រាកដនិយមវាបំពេញបន្ថែមដល់ជីវិតរបស់យើង ។

## ការពិនិត្យមើលអំពីការពិត (Reality Check)

- ការពិត គឺជាភាពខុសគ្នារវាងអ្វីដែលយើងប្រាថ្នាចង់បាន និងអ្វីជាការជាក់ស្តែង (Reality is the difference between what we wish for and what is)
- ការគិតដោយប្រាកដនិយម គឺជាគ្រឹះនៃធុរកិច្ចរបស់យើង ព្រោះយើងត្រូវគិតដល់ភាពច្បាស់លាស់ (Certainty) និងសន្តិសុខ (Security) ។

## ១_ហេតុអ្វីអ្នកត្រូវទទួលស្គាល់សារសំខាន់នៃការគិតដោយប្រាកដនិយម

- ការបណ្តុះនូវសមត្ថភាពដើម្បីឱ្យមានភាពប្រាកដនិយមនៅក្នុងការគិតរបស់អ្នក ពុំមែនបន្ថយនូវការជឿជាក់របស់អ្នកទៅលើមនុស្សឡើយ ហើយវាពុំបន្ថយជំនឿ (Faith) លើសមត្ថភាពរបស់អ្នកដើម្បីមើលឃើញ និងចាប់ឱកាសឡើយ ។

### ១.១_ការគិតដោយប្រាកដនិយមធ្វើឱ្យហានិភ័យតូច_ធំកើតមានជាអប្បបរមា

- អំពើតែងតែមានផលវិបាកជានិច្ច ។ ការគិតដោយប្រាកដនិយមជួយអ្នកឱ្យកំណត់បានអំពីអ្វីដែលជាផលវិបាកដែលអាចកើតមាន ។ រឿងនេះវាសំខាន់ណាស់ ព្រោះតែទទួលស្គាល់និងគិតគូរដល់ផលវិបាកហ្នឹងហើយ ដែលអ្នកអាចលើកផែនការដើម្បីដោះស្រាយបាន ។

- ប្រសិនបើអ្នកលើកផែនការចំពោះសេណារីយ៉ូដែលអាក្រក់បំផុតបាននោះ (The worst-case scenario) អ្នកអាចធ្វើឱ្យហានិភ័យតូចធំមានជាអប្បបរមា ។

**១.២_ការគិតដោយប្រាកដនិយមផ្តល់ឱ្យអ្នកនូវគោលដៅ (Target) និងផែនការនៃល្បែង (Game Plan)**

- អ្នកធ្វើធុរកិច្ចខ្លះពុំចូលចិត្តអ្នកគិតដោយប្រាកដនិយមឡើយ ព្រោះគេគិតថា ពួកគេជាអ្នកវិជ្ជមានបំផុត ថែមទាំងមានក្តីសង្ឃឹមខ្ពស់ចំពោះធុរកិច្ចរបស់ពួកគេថែមទៀត ។ ប៉ុន្តែត្រូវគិតថា ក្តីសង្ឃឹមពុំមែនជាយុទ្ធសាស្ត្រទេ ។
- ការគិតដោយប្រាកដនិយម នាំឱ្យមានភាពល្អប្រសើរនៅក្នុងការដឹកនាំ និងការគ្រប់គ្រង ពីព្រោះវាទាមទារឱ្យមនុស្សត្រូវប្រឈមនឹងការពិត ។ មនុស្សចាប់ផ្តើមដោយកំណត់អំពីគោលដៅ និងអភិវឌ្ឍន៍ផែនការនៃល្បែងដើម្បីសម្រេចគោលដៅ ។ កាលណាមនុស្សចូលគិតដោយប្រាកដនិយម ពួកគេចាប់ផ្តើមធ្វើជាសាមញ្ញនូវការអនុវត្ត និងនីតិវិធី (Practices and procedures) ដែលជាលទ្ធផលគឺប្រសិទ្ធផល (Efficiency)។
- ជាធម្មតា នៅក្នុងធុរកិច្ចមានការសម្រេចខ្លះប៉ុណ្ណោះដែលវាសំខាន់ ។ ការគិតដោយប្រាកដនិយមយល់ដឹងអំពីភាពខុសគ្នារវាងសេចក្តីសម្រេចដ៏សំខាន់ និងសេចក្តីសម្រេចដែលវាចាំបាច់នៅក្នុងដំណើរប្រក្រតីនៃធុរកិច្ច ។ សេចក្តីសម្រេចដែលថាសំខាន់ គឺវាពាក់ព័ន្ធទៅនឹងគោលបំណងរបស់អ្នក ។
- រហូតដល់ពេលដែលគំនិតត្រូវបានផ្សារភ្ជាប់ទៅនឹងគោលបំណងនោះ (Purpose) វានឹងពុំមានសមិទ្ធផលចេញមកពីប្រាជ្ញាឡើយ (Intelligent accomplishment) ។

**១.៣_ការគិតដោយប្រាកដនិយមជាកត្តាលើករនៃការផ្លាស់ប្តូរ**

- មនុស្សដែលពឹងផ្អែកលើក្តីសង្ឃឹមដើម្បីជោគជ័យរបស់ខ្លួន កម្រណាស់នឹងប្រកាន់យកការផ្លាស់ប្តូរធ្វើជាអាទិភាពរបស់ខ្លួន ។
    * ✶ ប្រសិនបើអ្នកមានតែក្តីសង្ឃឹមប៉ុណ្ណោះ អ្នកនឹងធ្វើឱ្យសមិទ្ធផល និងជោគជ័យស្ថិតនៅក្រៅដៃរបស់អ្នក ។ នេះគ្រាន់តែជាព្រេងវាសនា ឬសំណាងប៉ុណ្ណោះ

(A matter of luck or chance) ។

- ការគិតដោយប្រាកដនិយមអាចទាត់ចោលនូវអាកប្បកិរិយាខុសច្គងទាំងឡាយ ។ គ្មានអ្វីក្រៅពីការនាំការពិតទៅដាក់ខាងមុខមនុស្សម្នាក់ដើម្បីឱ្យទទួលស្គាល់ថា ចាំបាច់ត្រូវតែផ្លាស់ប្តូរ (Change) ។
    ✶ ការផ្លាស់ប្តូរតែមួយមុខពុំអាចនាំមកនូវការរីកចំរើនបានឡើយ ប៉ុន្តែអ្នកពុំអាចមានការរីកចំរើនបានឡើយបើគ្មានការផ្លាស់ប្តូរ ។

**១.៤_ការគិតដោយប្រាកដនិយមផ្តល់នូវសន្តិសុខ**

- ពេលណាមួយដែលអ្នកបានគិតដល់ភាពអាក្រក់បំផុតដែលអាចកើតឡើង ហើយអ្នករៀបចំនូវផែនការយថាហេតុ (Contingency plan) ដើម្បីប្រឈមនឹងភាពអាក្រក់នោះ នោះអ្នកនឹងក្លាយទៅជាអ្នកមានទំនុកចិត្ត និងសន្តិសុខ ÷ នេះបានន័យថា អ្នកបានធានាថានឹងគ្មានអ្វីធ្វើឱ្យអ្នកភ្ញាក់ផ្អើលឡើយ ។
- ការខកចិត្ត(Disappointment) គឺជាភាពខុសគ្នារវាងការរំពឹងទុក និងការពិតជាក់ស្តែង។
    ✶ ការគិតដោយប្រាកដនិយម ធ្វើឱ្យភាពខុសគ្នារវាងការរំពឹងទុក និងការពិតជាក់~ស្តែងមានជាអប្បបរមា

**១.៥_ការគិតដោយប្រាកដនិយមផ្តល់ដល់អ្នកនូវភាពគួរជឿជាក់ (Credibility)**

- ការគិតដោយប្រាកដនិយម ជួយឱ្យមនុស្សជឿជាក់ទៅលើអ្នកដឹកនាំ និងចក្ខុវិស័យរបស់អ្នកដឹកនាំ ។
    ✶ អ្នកដឹកនាំដែលតែភ្ញាក់ផ្អើលដោយអ្នកក្រោមឱវាទចាប់បាត់បង់នូវភាពជឿជាក់យ៉ាងរហ័ស ។
    ✶ អ្នកដឹកនាំដោយប្រាកដនិយម និងរៀបចំធ្វើផែនការសមស្រប តែងពង្រឹងជំហររបស់ស្ថាប័នខ្លួនឆ្ពោះទៅកាន់ភាពឈ្នះ ។ ប្រការនេះនាំឱ្យមហាជនមានជំនឿលើពួកគេ ។

- អ្នកដឹកនាំដ៏ពូកែតែងចោទសួរសំណួរដោយប្រាកដនិយម ដើម្បីកំណត់នូវចក្ខុវិស័យ ។ គេសួរខ្លួនគេ ដូចជា :
  - ✶ តើអាចទៅរួចដែរឬទេ ?
  - ✶ តើសុបិននេះរួមបញ្ចូលទាំងអស់គ្នា ឬក៏មួយចំនួនណានោះ ?
  - ✶ តើខ្ញុំបានកំណត់ និងលើកពីវិស័យខ្លះដែលសុបិននេះពិបាកនឹងសម្រេចបានដែរឬទេ ?

## ១.៦_ការគិតដោយប្រាកដនិយមផ្ដល់នូវគ្រឹះដើម្បីកសាងឡើង

- តម្លៃនៃគំនិតល្អណាមួយ គឺនៅត្រង់ប្រើប្រាស់បាននូវគំនិតនោះ ។
  - ✶ ជាមូលដ្ឋាន ការគិតដោយប្រាកដនិយម គឺជួយឱ្យអ្នកបង្កើតគំនិតមួយដើម្បីយកទៅប្រើប្រាស់វាបាន ដោយដកជម្រុះចេញកត្តា "ប្រាថ្នាចង់បាន" (Wish factor)
  - ✶ គំនិត និងការគិតខំជាច្រើនពុំអាចសម្រេចបាននូវលទ្ធផលដែលបានរំពឹងទុក ពីព្រោះគំនិត និងការគិតខំទាំងនោះពឹងផ្អែកជាច្រើនទៅលើអ្វីដែលយើងប្រាថ្នាចង់បាន ជាជាងអ្វីដែលពិតប្រាកដនោះ ។
- អ្នកអាចសាងសង់ផ្ទះហ្វូតដល់ពាក់កណ្ដាលមេឃ (Mid air): វាត្រូវការនូវគ្រឹះដ៏រឹងមាំ ។
  - ✶ គំនិត និងផែនការដូចជាគ្រឹះផ្ទះអញ្ចឹងដែរ ។
  - ✶ វាត្រូវការនូវអ្វីជាក់ស្ដែងដែលគេអាចកសាងឡើងបាន ។
  - ✶ ការគិតដោយប្រាកដនិយមផ្ដល់នូវគ្រឹះដ៏រឹងមាំនោះ ។

## ១.៧_ការគិតដោយប្រាកដនិយមគឺជាមិត្តសម្រាប់អ្នកណាដែលជួបវិបត្តិ (Trouble)

- ការប៉ិនប្រសប់ គឺជាអ្វីដែលអ្នកគួរធ្វើ ប្រសិនបើអ្នកពុំភ័យខ្លាចចំពោះលទ្ធភាពនៃបរាជ័យ (Failure)។ ការពិត គឺជាការដោះស្រាយជាមួយនឹងបរាជ័យប្រសិនបើវាកើតមានឡើង ។
- ការគិតដោយប្រាកដនិយម ផ្ដល់ឱ្យអ្នកនូវអ្វីជាភាពជាក់ស្ដែង ដើម្បីលោតទម្លាក់ខ្លួនមកលើ នៅពេលមានវិបត្តិ ដូច្នេះវានាំឱ្យមានការធានាច្បាស់លាស់ ។
  - ✶ ភាពប្រាកដប្រជា(Certainty) នៅក្នុងភាពមិនប្រាកដប្រជា(Uncertainty) នាំ

មកនូវស្ពេកភាព ។

**១.៨_ការគិតដោយប្រាកដនិយមនាំសុបិនទៅកាន់ផ្លែផ្កា (Fruition)**

- ឧត្តមគតិនិយមបង្កើនដោយភាគចំពោះ (Direct proportion) នូវបម្ខាយរបស់មនុស្សម្នាក់ទៅនឹងបញ្ហា ។
- ប្រសិនបើអ្នកមិនចូលទៅជិតបញ្ហាណាមួយទេ នោះពុំអាចដោះស្រាយបញ្ហានោះបានទេ។
- ប្រសិនបើអ្នកពុំបានមើលដោយប្រាកដនិយមចំពោះសុបិន ហើយនឹងអ្វីដែលត្រូវធ្វើដើម្បីសម្រេចឲ្យបាននោះទេ នោះអ្នកពុំអាចសម្រេចនូវសុបិននោះបានឡើយ ។
- ការគិតដោយប្រាកដនិយមជួយក្រាលផ្លូវដើម្បីនាំសុបិនណាមួយទៅកាន់ផ្លែផ្កា ។

**២_តើទទួលស្គាល់សារសំខាន់នៃការគិតដោយប្រាកដនិយមយ៉ាងដូចម្តេច**

- ប្រសិនបើអ្នកជាអ្នកសុទិដ្ឋិនិយមច្រើនជាងប្រាកដនិយម នោះអ្នកត្រូវបង្កើនការគិតរបស់អ្នកតាមវិធី ៥យ៉ាង ដូចតទៅ :

**២.១_អភិវឌ្ឍការឲ្យតម្លៃទៅលើការពិត**

- អ្នកពុំអាចក្លាយទៅជាអ្នកគិតដោយប្រាកដនិយមបានទេ ប្រសិនបើអ្នកពុំឲ្យតម្លៃទៅលើការគិតដោយប្រាកដនិយម
  - ✶ បានន័យថាត្រូវរៀនមើលការពិត និងរីករាយទទួលយកការពិត
  - ✶ ប្រធានាធិបតី Truman និយាយថា : ខ្ញុំពុំដែលផ្តល់ស្ថាននរកដល់ពួកគេឡើយ ។ ខ្ញុំគ្រាន់តែនិយាយការពិត ហើយពួកគេគិតថា នោះហើយគឺជាស្ថាននរក ។ នោះហើយគឺជាវិធីដែលមនុស្សជាច្រើនប្រតិកម្មទៅនឹងការពិត ។
  - ✶ មនុស្សតែងតែចង់ពន្លើសនូវជោគជ័យរបស់ពួកគេ ហើយធ្វើឲ្យឃើញបរាជ័យ ឬការលំបាករបស់ពួកគេជាអប្បបរមា។ ពួកគេរស់នៅតាមច្បាប់ Ruckert's Law ដោយជឿជាក់ថា គ្មានអ្វីតូចតាចបំផុតដែលពុំអាចបំបែកឲ្យខ្ទេចជាចំរៀកបានឡើយ (សូម្បីតែគ្រាប់ខ្សាច់) ។

* លោក Winston Churchill និយាយថា : "ជួនកាលមនុស្សជំពប់ជើងដួលចំពោះមុខការពិត តែជាទូទៅភាគច្រើនងើបខ្លួនឡើង និងប្រញាប់ដើរចេញ ហាក់ដូចជាគ្មានអ្វីកើតឡើង ។
* សង្គមយើងរកឃើញការពិតខ្លាំងណាស់ សូម្បីតែថ្នាំពេទ្យមួយគ្រាប់អាចរំលាយនូវអ្វីដែលពុំអាចរំលាយបាន (Undiluted) ។
* ក្នុងទម្រង់សុទ្ធសាធបំផុត ការពិតពុំមែនជាការគោះស្មាតិចៗដោយគួរសមឡើយ ។ នោះគឺជាការស្តីបន្ទោសដ៏ខ្លាំងៗ ។ និយាយម្យ៉ាងទៀត ការពិតនឹងធ្វើឱ្យអ្នកមានសេរីភាព តែមុនបង្អស់វានឹងធ្វើឱ្យអ្នកខឹងសម្បា ។
* ប្រសិនបើអ្នកចង់ក្លាយទៅជាអ្នកគិតដោយប្រាកដនិយម អ្នកចាំបាច់សម្របខ្លួនសុខស្រួលប្រឈមនឹងការពិត និងហ៊ានប្រឈមនឹងការពិត ។

## **២.២_ធ្វើកិច្ចការផ្ទះរបស់អ្នក**

~ ដំណើរការនៃការគិតដោយប្រាកដនិយម ចាប់ផ្តើមជាមួយនឹងការធ្វើកិច្ចការផ្ទះរបស់អ្នក ។

* ជាដំបូងអ្នកត្រូវប្រមូលហេតុការណ៍ ។
* កាលណាអ្នកចាប់ចូលដោះស្រាយបញ្ហាអ្វីមួយ អ្នកត្រូវដកហូតនូវមតិគិតឃើញពីមុន (Perceived opinions) និងបុរេវិនិច្ឆ័យ (Prejudice) ប្រមែប្រមូល និងរៀនអំពីហេតុការណ៍នៃស្ថានការណ៍(អង្គហេតុ) ធ្វើសេចក្តីសម្រេចដែលសម្រាប់អ្នកដោយស្មោះត្រង់បំផុត ហើយប្រកាន់ខ្ជាប់នូវសេចក្តីសម្រេចនេះ ។
* វាមិនសំខាន់ថាអ្នកបានគិតហ្មត់ចត់ដូចម្តេចឡើយ ប្រសិនបើការគិតនោះឈរលើមូលដ្ឋាននៃទិន្នន័យខុស (Faulty data) ឬក៏ការសន្និដ្ឋានមុន ។
* អ្នកពុំអាចគិតបានល្អក្នុងពេលដែលមានអវត្តមាននៃហេតុការណ៍(អង្គហេតុ) ឬក៏វត្តមាននៃព័ត៌មានតិចតួច (Poor information)។
* សូមចងចាំគំនិតរបស់អ្នកពុំចាំបាច់ជាការគិតផ្ទាល់(Original)នោះទេ តែវាត្រូវតែរឹងមាំ (Solid) ។

✶ អ្នកអាចរៀនពីអ្នកគិតដ៏ពូកែដែលធ្លាប់ប្រឈមនឹងស្ថានការណ៍ដូចគ្នា។ ជួនកាលការគិតដ៏ល្អប្រសើររបស់អ្នក ត្រូវបានអ្នកដទៃគេគិតរួចហើយ ។

## ២.៣_គិតតាមរយៈការគាំទ្រ និងការប្រឆាំង (The Pros and Cons)

- គ្មានអ្វីដែលដូចជាការប្រើពេលវេលាដើម្បីពិនិត្យដោយដាក់ស្តែងអំពីការគាំទ្រ និងការប្រឆាំងនៃបញ្ហាមួយ(The pros and cons of an issue) ដើម្បីផ្តល់ឱ្យអ្នកដាក់ម្លាំងខ្លាំងនៃការគិត ។
- វាពុំមែនជាការបញ្ចប់ត្រឹមតែការជ្រើសរើសសកម្មភាពទៅតាមចំនួនដ៏ច្រើនលើសលុបនៃការគាំទ្របានឡើយ ពីព្រោះការយល់ព្រម និងការប្រឆាំងពុំមានទម្ងន់ស្មើគ្នា ÷ នេះពុំមែនជាតម្លៃនៃការធ្វើបែបនេះឡើយ ។
- ផ្ទុយពីនេះ ការគិតតាមវិធីខាងលើជួយអ្នកឱ្យជីកជ្រៅទៅដល់អង្គហេតុ (Facts) ពិនិត្យបញ្ហានីមួយៗពីច្រើនជ្រុង(From many angles) ហើយបានគិតគូរអំពីតម្លៃនៃការប្រកាន់សកម្មភាពតាមលទ្ធភាពណាមួយនោះ (The cost of a possible course of action)។

## ២.៤_មើលឃើញសេណារីយ៉ូនៃករណីអាក្រក់បំផុត (Worst-Case Scenario)

- ខ្លឹមសារនៃការគិតដោយប្រាកដនិយម គឺជាការរកឱ្យឃើញ(Discovery) ការមើលឃើញ(Picturing) និងការពិនិត្យ(Examining) សេណារីយ៉ូនៃករណីអាក្រក់បំផុត ។ សំណួរដែលអ្នកអាចសាកសួរបាន ÷

✶ ប្រសិនបើការលក់ដូរធ្លាក់ក្រោមគម្រោងគ្រោងទុក (តើនឹងមានអ្វីកើតឡើង) ?

✶ ប្រសិនបើចំណូលធ្លាក់ដល់បាតដាល ?

✶ ប្រសិនបើពុំបានឈ្នះ ?

✶ ប្រសិនបើអតិថិជនពុំបង់ប្រាក់ឱ្យយើង ?

✶ ប្រសិនបើ បើយើងត្រូវធ្វើការក្នុងមុខការរយៈពេលខ្លី ?

✶ ប្រសិនបើកីឡាករដ៏ឆ្នើមរបស់យើងធ្លាក់ខ្លួនឈឺ ?

✶ ប្រសិនបើសហសេវិកទាំងអស់ទាត់ចោលនូវពាក្យសុំរបស់យើង ?

- ✶ ប្រសិនបើទីផ្សារត្រឡប់ត្រឡិន ?
- ✶ ប្រសិនបើក្រុមស្ម័គ្រចិត្តចាកចេញទៅ ?
- ✶ ប្រសិនបើគ្មាននរណាមក ?

- ជាសំខាន់ អ្នកទទួលបាននូវគំនិត ។ ត្រង់ថាអ្នកត្រូវគិតអំពីលទ្ធភាពនៃករណីអាក្រក់បំផុត ទោះបីអ្នករកស៊ីធុរកិច្ច ដឹកនាំនាយកដ្ឋាន គ្រប់គ្រងវគ្គ បង្ហាត់ក្រុមមួយ ឬក៏រៀបចំហិរញ្ញវត្ថុផ្ទាល់របស់អ្នក ។
- គោលបំណងរបស់អ្នកពុំមែនអវិជ្ជមាន ឬក៏ពឹងទុកនឹងទទួលបាននូវរឿងអាក្រក់បំផុតនោះឡើយ គឺគ្រាន់តែត្រៀមខ្លួនរួចជាស្រេច ប្រសិនបើករណីនោះកើតឡើង ។
- តាមរយៈនេះ អ្នកផ្តល់ជល់ខ្លួនឯងនូវសំណាងដ៏មហាប្រសើរបំផុត ដើម្បីទទួលបាននូវលទ្ធផលជាវិជ្ជមានក្នុងគ្រប់កាលៈទេសៈ (No matter what)។
- ប្រសិនបើអ្នកសម្លឹងមើលនូវករណីអាក្រក់បំផុត ហើយពិនិត្យមើលវាដោយស្មោះត្រង់នោះហើយអ្នកមានបទពិសោធន៏ជាក់ស្តែងអំពីការត្រួតពិនិត្យលើការជាក់ស្តែង(Reality check)។ អ្នកបានត្រៀមខ្លួនគ្រប់បែបយ៉ាង ។
- សូមពិភាក្សាដោយប្រយ័ត្នប្រយែង (Delibraerate with caution) តែត្រូវធ្វើសកម្មភាពដោយច្បាស់លាស់ (Act with decision) ហើយទទួលផលដោយល្អប្រពៃបំផុត(Yield with graciousness) ឬក៏ប្រឆាំងដោយមុតមាំ(Oppose with firmness)។

## **២.៤_តម្រប់ជូរការគិតរបស់អ្នកជាមួយធនធានរបស់អ្នក**

- គន្លឹះមួយដើម្បីអតិបរមាកម្ម ការគិតដោយប្រាកដនិយមរបស់អ្នកនោះ គឺតម្រង់ជួរនូវធនធានរបស់អ្នកជាមួយនឹងទិសដៅ(Objectives)របស់អ្នក ។ ពិនិត្យមើលលើការយល់ព្រមនិងការប្រឆាំង (The pros and cons) ហើយពិនិត្យមើលតាមករណីដែលវាអាក្រក់បំផុតនោះ នឹងនាំឲ្យបានយល់ដឹងអំពីការខ្វះចន្លោះ(Gaps)រវាងអ្វីដែលអ្នកចង់បានជាមួយនឹងការពិត។ កាលណាអ្នកបានដឹងអំពីអ្វីជាការខ្វះចន្លោះនោះ អ្នកអាចប្រើប្រាស់ធនធានរបស់អ្នកដើម្បីបំពេញវា ។ ហ្នឹងហើយទើបធនធានត្រូវដោះស្រាយផ្តល់ ។

## ៣-ប៊ូលមហាធំ កំពូលវិមានមហាធំ មហាសន្តិសុខ

**Super Bowl, Super Dome, Super Security**

- គេពុំអាចជៀសវាង ឬធ្វេសប្រហែសចំពោះការគិតដោយប្រាកដនិយមបានឡើយ ។
  - ✶ មេរៀន ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០១ ដើរហួសសេណារីយ៉ូករណីអាក្រក់បំផុត
  - ✶ នៅសហរដ្ឋអាមេរិកក្រោយព្រឹត្តិការណ៍នោះ នៅពេលមានពិធីធំៗ គេតែងតែត្រៀមលក្ខណៈដោយសិក្សាអំពីសេណារីយ៉ូនៃករណីអាក្រក់បំផុត ។

×

× ×

# ជំពូកទី ៥
# សូមប្រើប្រាស់ការគិតជាយុទ្ធសាស្ត្រ
# UTILIZE STRATEGIC THINKING

- មនុស្សជាច្រើនចំណាយពេលវេលាច្រើនជាង ដើម្បីរៀបចំផែនការសម្រាប់ការសម្រាកនៅរដូវក្តៅ ជាជាងរៀបចំផែនការសម្រាប់ជីវិតរបស់ពួកគេ ។
- យុទ្ធសាស្ត្រពុំសំដៅត្រឹមតែប្រើប្រាស់ខាងយោធា និងធុរកិច្ចប៉ុណ្ណោះទេ ។ ការគិតជាយុទ្ធ-សាស្ត្រអាចនាំឱ្យមានឥទ្ធិពលវិជ្ជមានទៅលើវិស័យណាមួយនៃជីវិត ។

**១-ធ្វើផែនការសម្រាប់ជីវិតអ្នក ធ្វើឱ្យផែនការឱ្យរស់រានសម្រាប់ជីវិតអ្នក (Plan Your Life, Live Your Plan)**

- មនុស្សជាច្រើនខិតខំសាកល្បងធ្វើផែនការសម្រាប់ជីវិតរបស់ពួកគេ ម្តងក្នុងមួយថ្ងៃ ។
  - ✶ ពួកគេភ្ញាក់ឡើងរៀបចំបញ្ជីត្រូវធ្វើ(To-do-list) និងចាប់ធ្វើសកម្មភាព
  - ✶ តែមួយចំនួនណា ពុំដែលទាំងមានយុទ្ធសាស្ត្របែបនេះទេ
  - ✶ បុគ្គលមួយចំនួនធ្វើផែនការសម្រាប់ជីវិតគេម្តងក្នុងមួយអាទិត្យ÷ ពួកគេពិនិត្យមើលឡើងវិញនូវប្រក្រតីទិនប្រចាំសប្តាហ៍ ត្រួតពិនិត្យមើលការណាត់ជួបគ្នា មើលឡើងវិញទៅលើគោលដៅ (Goals) បន្ទាប់មកខិតខំអនុវត្តន៍សម្រេច ។ ជាទូទៅ ពួកគេតែងសម្រេចហួសការរៀបចំផែនការប្រចាំថ្ងៃរបស់សហសេវិកគេ ។
- ទាល់តែមានយុទ្ធសាស្ត្រ នោះទើបអាចសម្រេចបានលទ្ធផលច្រើន ។

**២-ហេតុដូចម្តេចបានជាអ្នកគួរបញ្ចេញអំណាចនៃការគិតជាយុទ្ធសាស្ត្រ (Why You Should Release the Power of Strategic Thinking**

- ការគិតជាយុទ្ធសាស្ត្រជួយអ្នកឱ្យធ្វើផែនការឱ្យកាន់តែមានប្រសិទ្ធផល ឱ្យប្រើប្រាស់កម្លាំងអ្នកបានជាអតិបរមា ហើយឱ្យរកឃើញនូវគន្លងត្រង់ (Direct path) ដើម្បីសម្រេចនូវទិសដៅណាមួយ ។

- ត្រូវយល់ថា ការគិតជាយុទ្ធសាស្ត្រគឺជាឧបករណ៍មួយនៃការគិតរបស់អ្នក ។

**២.១_ការគិតជាយុទ្ធសាស្ត្រធ្វើឱ្យការលំបាកក្លាយជាសាមញ្ញ**

- តាមពិតទៅ ការគិតជាយុទ្ធសាស្ត្រពុំមែនអ្វីក្រៅពីការធ្វើផែនការអំពីកម្លាំងរបស់អ្នកឡើយ (Planning on steroids)។
- មនុស្សដែលបានត្រៀមខ្លួន មានសមរភូមិប្រយុទ្ធបានពាក់កណ្តាលហើយ (The man who is prepared has his battle half fought)។
- ការគិតជាយុទ្ធសាស្ត្រចាប់យកបញ្ហាដ៏ស្មុគ្រស្មាញនានា(Complex issues) និងគោល-ដៅរយៈពេលវែង (Long-term objectives) ដែលពិបាកណាស់នឹងប្រឈមដោះស្រាយ ហើយបំបែកជាចំរៀកដែលអាចគ្រប់គ្រងបាន ។
- ការគិតជាយុទ្ធសាស្ត្រអាចជួយអ្នកដើម្បីធ្វើឱ្យការគ្រប់គ្រងជីវិតប្រចាំថ្ងៃមានភាពសាមញ្ញ
  - ✶ *ភារកិច្ចមួយដ៏លំបាកអាចធ្វើឱ្យសាមញ្ញតាមរយៈការគិតជាយុទ្ធសាស្ត្រ (ឧទាហរណ៍ : ការទុកដាក់ឯកសារ ឬ Files ដែលត្រូវរកដើម្បីប្រើប្រាស់ទៅពេលក្រោយ)* ។

**២.២_ការគិតជាយុទ្ធសាស្ត្រតម្រូវឱ្យអ្នកចោទសួរនូវសំណួរបើត្រឹមត្រូវ**

- តើអ្នកមានបំណងបំបែកបញ្ហាស្មុគ្រស្មាញ ឬពិបាកជាចំរៀកៗដែរឬទេ (Complex or difficult issues) *?*
- ដូច្នេះត្រូវលើកសំណួរសួរ
- ការគិតជាយុទ្ធសាស្ត្របង្ខំឱ្យអ្នកប្រើប្រាស់ដំណើរការមួយដែលមានសំណួរជាច្រើន ÷
  - ✶ **ទិស (Direction)**

    តើយើងត្រូវធ្វើអ្វីបន្តទៀត *?* ហេតុអ្វី *?*
  - ✶ **ការរៀបចំ (Organization)**

    តើអ្នកណាត្រូវទទួលខុសត្រូវរឿងអ្វី *?*

    តើអ្នកណាត្រូវទទួលខុសត្រូវចំពោះអ្នកណា *?*

តើយើងមានមនុស្សបំត្រូវជំនាញ (Right people) នៅត្រូវកន្លែងនោះដែរឬទេ (In right places)

✶ **ប្រាក់កាស (Cash)**

តើអ្វីជាចំណូល ចំណាយសុទ្ធសាធរបស់យើង ?

តើយើងអាចមានប្រាក់សល់គ្រប់គ្រាន់ដើម្បីធ្វើរឿងនេះដែរឬទេ ?

តើយើងត្រូវវិតខំឱ្យមានគ្រប់គ្រាន់យ៉ាងដូចម្ដេច ?

✶ **ការតាមដានមើល (Tracking)**

តើយើងស្ថិតនៅក្នុងដំហានឆ្ពោះទៅគោលដៅដែរឬទេ ?

✶ **ការវាយតម្លៃទាំងមូល (Overall Evaluation)**

តើយើងកំពុងសម្រេចបាននូវគុណភាពដែលយើងរំពឹងទុក និងសេចក្តីត្រូវការរបស់ខ្លួនយើងដែរឬទេ ?

✶ ការធ្វើឱ្យប្រសើរឡើង (Refinement)

តើយើងអាចក្លាយជាមានប្រសិទ្ធភាព និងប្រសិទ្ធផលច្រើនជាងនេះ (ដើម្បីឆ្ពោះទៅកាន់ឧត្តមគតិ(Ideal)យ៉ាងដូចម្ដេច) ?

- សំណួរទាំងនេះពុំមែនសុទ្ធតែជាសំណួរដែលត្រូវការសាកសួរ ដើម្បីចាប់ផ្តើមរៀបចំផែន~ការជាយុទ្ធសាស្ត្រប៉ុណ្ណោះទេ នៅមានសំណួរជាច្រើនទៀត តែសំណួរទាំងនេះជួយឱ្យចាប់ផ្តើមដំណើរការទៅមុខ ។

## ២.៣_ការគិតជាយុទ្ធសាស្ត្របណ្តាលឱ្យត្រូវប្រែប្រួលសេចក្តីត្រូវការ

- ពួកឧត្តមសេនីយ៍ដែលជោគជ័យតែងតែធ្វើផែនការ ដើម្បីសម្របទៅនឹងកាលៈទេសៈ តែពួកឧត្តមសេនីយ៍ទាំងនោះពុំដែលសាកល្បងបង្កើតកាលៈទេសៈ ដើម្បីឱ្យសមស្របទៅនឹងផែនការរបស់ពួកគេឡើយ ។
- អ្នកគិតជាយុទ្ធសាស្ត្រដ៏ពូកែទាំងអស់តែងមានការគិតច្បាស់លាស់ ។

★ ពួកគេតែងបន្ស៊ីយុទ្ធសាស្ត្រទៅនឹងបញ្ហា (Problem) ពីព្រោះយុទ្ធសាស្ត្រនីមួយៗ ពុំមែនជាខ្នាតតែមួយនោះទេ(A one-size-fits-all propositions) ។

★ ការគិតធ្វេសប្រហែស ឬធ្វើជារបៀបទូទៅ(Sloppy or generalized thinkings) គឺជាសត្រូវនៃសមិទ្ធផល ។

★ បំណងនៃការធ្វើឱ្យប្រែប្រួលនៅក្នុងការគិតជាយុទ្ធសាស្ត្រ តម្រូវឱ្យមនុស្សម្នាក់ដើរហួសគំនិតស្រពិចស្រពិល (Vague ideas) និងចាប់ចូលធ្វើតាមវិធីដោយឡែក (Specific way)ស្របទៅនឹងភារកិច្ច ឬបញ្ហានោះ។ នេះនាំឱ្យស្មារតីឡើងស្រួច ។

**២.៤_ការគិតជាយុទ្ធសាស្ត្ររៀបចំខ្លួនអ្នកនាថ្ងៃនេះ ដើម្បីភាពមិនច្បាស់លាស់នាថ្ងៃស្អែក**

- ការគិតជាយុទ្ធសាស្ត្រ គឺជាស្ពានដែលតភ្ជាប់កន្លែងដែលកំពុងឈរទៅកាន់កន្លែងដែលអ្នកចង់ទៅដល់

★ វាផ្តល់ទិស(Direction) និងភាពជឿជាក់(Credibility)ដល់អ្នកក្នុងថ្ងៃនេះ ហើយបង្កើនសក្តានុពលរបស់អ្នកដើម្បីជោគជ័យនៅថ្ងៃស្អែក ។

★ វាហាក់ដូចលើកដាក់កែបសុបិនរបស់អ្នកលើខ្នងសេះមុននឹងជិះសេះចេញទៅ ។

**២.៥_ការគិតជាយុទ្ធសាស្ត្រកាត់បន្ថយខ្នងនៃការភ័ន្តច្រឡំ (The Margin of error)**

- ពេលណាមួយ អ្នកបាញ់កាំភ្លើងចេញពីត្រគៀក (The hip) ឬក៏អ្នករង់ចាំតែប្រតិកម្មវិញទាំងស្រុងនោះ ពេលនោះអ្នកបង្កើនខ្នងនៃការភ័ន្តច្រឡំរបស់អ្នក ។

★ អ្នកវាយ Golf ដែលប្រញាប់ចាប់វាយគ្រាប់ Golf ដោយពុំបានតម្រង់ ត្រឹមតែប៉ុន្មានអង្សា គ្រាប់Golf ធ្លាក់ច្រើនសិបម៉ែត្រពីរន្ធ *(ជាគោលដៅ)* ។

★ ការគិតជាយុទ្ធសាស្ត្រពិតជាកាត់បន្ថយទូវខ្នងនៃការភ័ន្តច្រឡំ ព្រោះវាបានតម្រង់អំពើរបស់អ្នកជាមួយនឹងគោលដៅ (Actions and objectifies) ដូចជាគ្រាប់ Golf ដែលបានតម្រង់ដើម្បីធ្លាក់ជិតរន្ធជាគោលដៅ ។

★ កាលការអ្នកតម្រង់កាន់តែល្អប្រសើរ អ្នកនឹងមានសំណាងកាន់តែច្រើនបានទៅដល់គោលដៅរបស់អ្នក (Target) កាន់តែជឿជាក់នោះអ្នកកាន់តែដើរឆ្ពោះទៅ

កាន់ទិសដ៏ត្រឹមត្រូវរបស់អ្នក ។

**២.៦_ការគិតជាយុទ្ធសាស្ត្រផ្តល់ឱ្យអ្នកនូវឥទ្ធិពលទៅលើអ្នកដទៃ**

- ប្រសិនបើអ្នកអនុវត្តនូវការគិតជាយុទ្ធសាស្ត្រ អ្នកដទៃនឹងស្តាប់រូបអ្នក ហើយពួកគេចង់ដើរតាមរូបអ្នក ។

  ✶ សម្រាប់អ្នកកាន់មុខតំណែងនៅក្នុងស្ថាប័ន ការគិតជាយុទ្ធសាស្ត្រគឺជាសារវ័ន្ត ។

## ៣_តើត្រូវបញ្ចេញអំណាចនៃការគិតជាយុទ្ធសាស្ត្រយ៉ាងដូចម្តេច ?

- ដើម្បីក្លាយទៅជាអ្នកគិតជាយុទ្ធសាស្ត្រ ដែលមានសមត្ថភាពលើកផែនការ និងអនុវត្តន៏ផែនការ ដែលនាំឱ្យសម្រេចនូវគោលដៅដែលចង់បាននោះ សូមអនុវត្តន៏តាមការណែនាំដូចខាងក្រោម ÷

**៣.១_បំបែកបញ្ហា(Issue) ជាចំរៀក**

- ជំហានទី១ នៅក្នុងការគិតជាយុទ្ធសាស្ត្រ គឺបំបែកបញ្ហាមួយទៅជាចំរៀកតូចៗដែលអាចគ្រប់គ្រងបាន ដែលអ្នកយកចិត្តទុកដាក់លើចំរៀកទាំងនោះប្រកបដោយប្រសិទ្ធភាព ។
- តើអ្នកធ្វើយ៉ាងម៉េចបើបញ្ហានោះវាមិនសូវសំខាន់ មិនសមនឹងធ្វើវា ?

  ✶ អ្នកអាចបំបែកបញ្ហានោះទៅតាមមុខងារ (By function)

  ✶ លោក Henry Ford ធ្វើបែបនេះ ពេលគាត់ត្រូវបង្កើតប្រព័ន្ធខ្សែផ្គុំ (Assembly line) : គ្មានអ្វីសំខាន់ត្រូវប្រឡូកដៃឡើយ ប្រសិនបើអ្នកបំបែកវាទៅជាមុខការតូចៗ ។

  ✶ តើអ្នកត្រូវបំបែកបញ្ហានីមួយៗយ៉ាងដូចម្តេច ? នោះគឺស្រេចលើអ្នក អាចតាមមុខងារ (Function) កាលបរិច្ឆេទ(Timetable) ការទទួលខុសត្រូវ គោលបំណង (Purpose) ឬក៏វិធីដទៃទៀត ÷ សំខាន់គឺអ្នកចាំបាច់ត្រូវបំបែកវាជាចំរៀក ។

  ✶ មានតែមនុស្សម្នាក់ក្នុងមួយលាន ដែលក្បាលគាត់អាចមើលឃើញរូបភាពបញ្ហាទាំងមូល ហើយអាចគិតជាយុទ្ធសាស្ត្រដើម្បីបង្កើតជាផែនការមួយរឹងមាំ និងយក

ជាការចាំបាច់ ។

**៣.២_សួរសំណួរ Why មុន How**

- កាលណាមនុស្សស្ទើរទាំងអស់ចាប់ផ្តើមប្រើប្រាស់ការគិតជាវិជ្ជមាន ដើម្បីដោះស្រាយបញ្ហាណាមួយ ឬរៀបចំផែនការដើម្បីសម្រេចគោលដៅណាមួយ ពួកគេជាញឹកញាប់ច្រើនប្រព្រឹត្តខុស លោតទៅចាប់កាំភ្លើងហើយចិតខ្ចាំភ្លាមៗគិតគូរថាតើត្រូវសម្រេចវាយ៉ាងដូចម្តេច ។

✶ ជំនួសឱ្យការសាកសួរ How ពួកគេត្រូវសួរជាដំបូង Why ។

✶ ប្រសិនបើលោតភ្លាមៗទៅកាន់របៀបដោះស្រាយបញ្ហា (Problem solving mode) តើអ្នកនឹងយល់ដឹងបញ្ហាទាំងមូលយ៉ាងដូចម្តេច ?

✶ វិស្វកររាប់ពាន់នាក់អាចគូសប្លង់ស្ពាន បាន់ស្មានទម្ងន់បន្ថែម និងទម្ងន់បន្ទុកហើយបញ្ហាក់បង្ហាញអំពីលក្ខណៈវិនិច្ឆ័យនៃម៉ាស៊ីន ។

✶ តែវិស្វករដ៏ល្បី គឺជាមនុស្សដែលអាចនិយាយប្រាប់ឱ្យដឹងថាស្ពាន ឬក៏ម៉ាស៊ីនត្រូវកសាងដែរឬអត់ គួរកសាងនៅកន្លែងណា ហើយពេលណា ។

✶ ពេលលើកសំណួរ Why វានឹងជួយឱ្យអ្នកចាប់គិតអំពីមូលហេតុនៃការសម្រេចចិត្ត ។ វាជួយឱ្យអ្នកបើកស្មារតីឆ្ពោះទៅកលទ្ធភាព និងឱកាស (Possibility and opportunities)។

✶ ទំហំនៃឱកាសណាមួយ (The size of opportunities) ជាញឹកញាប់កំណត់អំពីកំរិតនៃធនធាន (The level of resources) និងការចិតខំដែលត្រូវធ្វើវិនិយោគ ។

✶ ឱកាសធំនាំឱ្យមានការសម្រេចចិត្តធំ ។

✶ ប្រសិនបើអ្នកលោតទៅកាន់ How ភ្លាមៗ អ្នកនឹងបាត់បង់ឱកាសទាំងនោះ ។

**៣.៣_សូមកំណត់បញ្ហាជាក់ស្តែង និងគោលដៅ (The real issue and objectives)**

- មុននឹងបញ្ហាមួយអាចត្រូវបានដោះស្រាយ ត្រូវតែកំណត់បញ្ហានោះឱ្យច្បាស់ ។
- មនុស្សជាច្រើនណាស់តែងតែប្រញាប់ប្រញាល់ដោះស្រាយជាលទ្ធផល ពួកគេបញ្ចប់ដោយដោះស្រាយបញ្ហាខុស ។
- ដើម្បីជៀសវាងករណីនេះ សូមសួរសំណួរបញ្ជាក់ដើម្បីរកឱ្យឃើញនូវបញ្ហាជាក់ស្តែង ។
- សូមប្រឈមនឹងបុរេវិនិច្ឆ័យរបស់អ្នក (Assumptions) ។
- សូមប្រមូលព័ត៌មានទោះបីអ្នកគិតថាបានកំណត់បញ្ហារួចហើយក្តី ។
- សូមចាប់ផ្តើមដោយសាកសួរសំណួរថា តើអ្វីខ្លះទៀតដែលអាចជាបញ្ហាជាក់ស្តែង ?
- អ្នកត្រូវដកចេញនូវរបៀបវារៈផ្ទាល់ខ្លួន (Personal agenda) និងអ្វីផ្សេងទៀតដែលអាចបិទបាំងនូវការវិនិច្ឆ័យរបស់អ្នក ។
- ការរកឱ្យឃើញនូវស្ថានការណ៍ពិតប្រាកដ (Real situation) និងគោលដៅ គឺជាភាគមួយដ៏សំខាន់នៃសមរភូមិ។
- កាលណាបញ្ហាជាក់ស្តែងត្រូវបានកំណត់ ការដោះស្រាយជាញឹកញាប់វាសាមញ្ញ ។

**៣.៤_ត្រួតពិនិត្យមើលធនធានរបស់អ្នក**

- វាសំខាន់ណាស់ដែលត្រូវដឹងអំពីធនធានរបស់អ្នក ។
- យុទ្ធសាស្ត្រណាមួយដែលពុំគិតគូរដល់ធនធាន គឺឆ្ពៀងទៅរកបរាជ័យ ។ សូមធ្វើសារពើភ័ណ្ឌ ÷
    - ✶ តើអ្នកមានពេលវេលាប៉ុន្មាន ?
    - ✶ តើអ្នកមានប្រាក់ប៉ុន្មាន ?
    - ✶ តើសម្ភារៈ ការផ្គត់ផ្គង់ ឬសារពើភ័ណ្ឌប៉ុន្មានដែលអ្នកមាន ?
    - ✶ តើអ្វីខ្លះជាទ្រព្យសម្បត្តិដទៃទៀតរបស់អ្នក ?
    - ✶ តើមានបំណុល និងកាតព្វកិច្ចអ្វីខ្លះដែលចូលពាក់ព័ន្ធ ?

✶ តើមនុស្ស ឬក្រុមណាខ្លះដែលអាចធ្វើឱ្យមានឥទ្ធិពល ?

✶ អ្នកដឹងអំពីស្ថាប័នរបស់អ្នកផ្ទាល់ និងវិជ្ជាជីវៈ ?

✶ សូមគិតមើលតើអ្នកមានធនធានអ្វីខ្លះសម្រាប់ប្រើប្រាស់ ?

**៣.៥_អភិវឌ្ឍន៍ផែនការរបស់អ្នក**

- តើអ្នកត្រូវចូលទៅដំណើរការធ្វើផែនការរបៀបណា គឺពឹងផ្អែកជាសំខាន់ទៅលើវិជ្ជាជីវៈរបស់អ្នក និងទំហំនៃការប្រឈមដែលអ្នកមានផែនការនឹងដោះស្រាយ

✶ វាពិបាកនឹងផ្តល់អនុសាសន៍ឱ្យជាក់លាក់ ។

✶ តែទោះបីជាអ្នកធ្វើផែនការបែបណាក្តី សូមយកចិត្តទុកដាក់ :

◈ សូមចាប់ផ្តើមដោយភាពមិនច្បាស់លាស់

◈ កាលណាអ្នកប្រទះដោះស្រាយបញ្ហាណាមួយ ឬធ្វើផែនការដោះស្រាយ វាតែងនាំមកនូវភាពឯកច្ឆ័ន្ទ និងកុងសង់ស៊ីសដល់ក្រុម ពីព្រោះមនុស្សទាំងអស់បានមើលឃើញអំពីរឿងនេះ

✶ អង្គធាតុមិនច្បាស់លាស់កសាងកម្លាំងប្រាជ្ញា (Mental momentum) ហើយផ្តួចផ្តើមនូវការច្នៃប្រឌិត និងពលានុភាព (Intensity) ។

✶ វិធីដ៏ប្រសើរដើម្បីបង្កើតផ្លូវមួយទៅកាន់ភាពស្មុគស្មាញ នោះគឺកសាងនៅលើមូលដ្ឋានគ្រឹះ (The fundamentals) ។

**៣.៦_ដាក់មនុស្សឱ្យត្រូវនៅចំកន្លែងត្រូវ**

- វាសំខាន់ណាស់ដែលអ្នកបញ្ចូលក្រុមរបស់អ្នកជាផ្នែកនៃការគិតជាយុទ្ធសាស្ត្រ ។
- មុននឹងអ្នកអាចអនុវត្តនូវផែនការរបស់អ្នក អ្នកត្រូវធានាឱ្យច្បាស់ថា អ្នកមានមនុស្សត្រូវនៅចំកន្លែងត្រូវ

✶ ទោះបីជាមានការគិតជាយុទ្ធសាស្ត្រល្អបំផុតក្តី ប្រការនេះពុំបានជួយអ្នកឡើយ ប្រសិនបើអ្នកពុំគិតគូរដល់មនុស្ស ដែលផ្នែកនៃសមីការ (Equation)

✶ តើអ្វីនឹងកើតឡើង ប្រសិនបើអ្នកគិតពុំត្រឹមត្រូវ :

◈ មនុស្សខុស (Wrong person) : មានបញ្ហាជំនួសសក្តានុពល

◈ កន្លែងខុស (Wrong place) : ការរំសាយចិត្ត ((Frustration) ជំនួសការពេញចិត្ត (Fulfillment)

◈ ផែនការខុស : ក្តីអន្តរាយ (Grief) ជំនួសការរីកចំរើន (Growth)

✶ អ្វីៗនឹងបានមកពីអង្គធាតុទាំងបី :

◈ មនុស្សត្រូវ (Right person)

◈ កន្លែងត្រូវ (Right place)

◈ ផែនការត្រូវ (Right plan)

**៣.៧_<u>សូមថែរក្សាធ្វើដំណើរការដដែល</u> (Keep repeating the process)**

- ការគិតជាយុទ្ធសាស្ត្រគឺដូចផ្ងូតទឹក អ្នកត្រូវតែរក្សាការផ្ងូតទឹកដដែល ។

✶ ប្រសិនអ្នករំពឹងទុកថាដោះស្រាយបញ្ហាសំខាន់ណាមួយបានភ្លាមៗនោះ អ្នកនឹងត្រូវខកចិត្ត ។

✶ រឿងតូចតាចអាចត្រូវបានដោះស្រាយដោយងាយ តាមរយៈប្រព័ន្ធ និងវិន័យផ្ទាល់ខ្លួន (Systems and personal discipline) ។

✶ តែចំពោះបញ្ហាសំខាន់ៗចាំបាច់ពេលវេលានៃការគិតជាយុទ្ធសាស្ត្រ (Strategic thinking time) ។

✶ ជន្ទះដើម្បីឈ្នះនឹងគ្មានតម្លៃ ប្រសិនបើអ្នកគ្មានជន្ទះនឹងត្រៀមរៀបចំ ។

✶ ប្រសិនអ្នកចង់ក្លាយជាអ្នកគិតជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាព នោះអ្នកជាចាំបាច់ជាបន្តបន្ទាប់ខិតខំប្រែក្លាយខ្លួនជាអ្នកគិតជាយុទ្ធសាស្ត្រ ÷ ចាំបាច់ត្រូវមានការខិតខំពីមួយជំហានទៅមួយជំហានទៀត ។

✕

✕ ✕

# ជំពូកទី៦
# ស្វែងរកការគិតអំពីលទ្ធភាព
# EXPLORE POSSIBILITY THINKING

- គ្មានអ្វីទើសទាល់ជាងសម្លឹងមើលនរណាម្នាក់ធ្វើអ្វីមួយ ដែលអ្នកបាននិយាយថាពុំអាចធ្វើបាន ។
- មនុស្សដែលឱបក្រសោបយកការគិតអំពីលទ្ធភាព មានសមត្ថភាពសម្រេចភារកិច្ចដែលហាក់ដូចជាពុំអាចធ្វើបាន ពីព្រោះគេជឿជាក់ទៅលើដំណោះស្រាយ ។
- មូលហេតុដែលគួរអ្នកប្រែក្លាយខ្លួនជាអ្នកគិតអំពីលទ្ធភាព :

## ១-ការគិតដល់លទ្ធភាព បង្កើនលទ្ធភាពរបស់អ្នក

- ប្រសិនបើអ្នកជឿជាក់ថា អ្នកអាចធ្វើអ្វីដែលពិបាកៗហើយទទួលបានជោគជ័យនោះ ទ្វារជាច្រើននឹងបើកចំហសម្រាប់អ្នក ។
  - ✶ ប្រសិនបើអ្នកបើកខ្លួនឯងឱ្យមានការគិតដល់លទ្ធភាព នោះអ្នកនឹងបើកចំហខ្លួនឯងទៅកាន់លទ្ធភាពថ្មីៗទៀត ។

## ២-ការគិតអំពីលទ្ធភាពទាក់ទាញឱកាស និងមនុស្សឱ្យមករកអ្នក

- មនុស្សដែលគិតធំអាចបង្កើតនូវឱកាស និងទាក់ទាញមនុស្ស ។
  - ✶ ប្រសិនបើអ្នកចង់សម្រេចបានរឿងធំៗ អ្នកចាំបាច់ប្រែក្លាយខ្លួនជាអ្នកគិតអំពីលទ្ធភាព ។

## ៣-ការគិតអំពីលទ្ធភាពបង្កើនលទ្ធភាពដទៃទៀត

- អ្នកគិតធំៗដែលបានសម្រេចលទ្ធផលឱ្យកើតឡើង បង្កើតផងដែរនូវលទ្ធភាពដល់អ្នកដទៃ
  - ✶ មួយផ្នែក រឿងនេះកើតឡើងព្រោះវាបានចម្លងគ្នា
  - ✶ អ្នកពុំអាចជួយប៉ុន្តែកាន់តែជឿទុកចិត្ត ហើយគិតកាន់តែធំទៅៗកាលណាអ្នកនៅ

ក្បែរអ្នកគិតអំពីលទ្ធភាព ។

## ៤_ការគិតអំពីលទ្ធភាពអនុគ្រោះឱ្យអ្នកសុបិនឃើញសុបិនកាន់តែធំទៅៗ

- មិនថាអ្វីជាវិជ្ជាជីវៈរបស់អ្នក ការគិតអំពីលទ្ធភាពអាចជួយអ្នកឱ្យបើកទូលាយជើងមេឃ ហើយសុបិនឃើញសុបិនកាន់តែធំទៅៗ ។
- អ្នកគិតធំគឺជាអ្នកឯកទេសក្នុងការបង្កើតការមើលទៅមុខដោយវិជ្ជមាន (Positive forward-looking) រូបភាពសុទិដ្ឋិនិយមនៅក្នុងស្មារតីផ្ទាល់របស់គេ និងក្នុងស្មារតីរបស់អ្នកដទៃ ។
- ប្រសិនបើអ្នកឱបក្រសោបនូវការគិតអំពីលទ្ធភាព សុបិនរបស់អ្នកនឹងដើរពីដំបូក (Molehill) ទៅទំហំភ្នំ ពីព្រោះអ្នកជឿជាក់លើលទ្ធភាព អ្នកដាក់ខ្លួនឯងនៅក្នុងជំហរដើម្បីសម្រេចឱ្យបាននូវសុបិននោះ ។

## ៥_ការគិតអំពីលទ្ធភាពធ្វើឱ្យមានលទ្ធភាពដើម្បីខ្ពស់ឡើងជាងធម្មតា

- កាលណាអ្នកជឿថា ដោះស្រាយបញ្ហាអាចធ្វើទៅបានដោយដកចោលនូវផ្លាក "ធ្វើមិនបាន" ពីភារកិច្ចណាមួយនោះ អ្នកបង្កើននូវសក្តានុពលរបស់អ្នកខុសពីធម្មតា ។

## ៦_ការគិតអំពីលទ្ធភាពផ្តល់ឱ្យអ្នកនូវថាមពល

- មានទំនាក់ទំនងដោយផ្ទាល់រវាងការគិតអំពីលទ្ធភាព និងកម្រិតនៃថាមពលរបស់បុគ្គលណាម្នាក់ ។
- តើនរណាម្នាក់នឹងមានកម្លាំង ដោយគិតថាខ្លួននឹងចាញ់នោះ ?
    - ✶ ប្រសិនបើអ្នកដឹងថារឿងអ្វីពុំអាចជោគជ័យ តើមានបំណងប្រាថ្នានឹងចំណាយពេលវេលា និងថាមពលប៉ុន្មានដើម្បីរឿងនោះ ?
- គ្មាននរណាម្នាក់នឹងដើរតាមបុព្វហេតុដែលចាញ់ទេ (For a lost cause) ។
    - ✶ អ្នកវិនិយោគទុនតែលើអ្វីដែលអ្នកជឿថា អ្នកអាចទទួលបានជោគជ័យប៉ុណ្ណោះ ។
- កាលណាអ្នកឱបក្រសោបនូវការគិតអំពីលទ្ធភាព នោះអ្នកនឹងមានជំនឿលើអ្វីដែលអ្នកកំពុងធ្វើ ប្រការនោះហើយផ្តល់ថាមពលឱ្យរូបអ្នក ។

## ៧_ការគិតអំពីលទ្ធភាពថែរក្សាអ្នកមិនឱ្យចុះចាញ់

- មុនអ្វីៗទាំងអស់ អ្នកគិតអំពីលទ្ធភាពជឿជាក់ថា ពួកគេនឹងមានជោគជ័យ ។
- ពួកអ្នកទទួលជោគជ័យក្នុងជីវិតគិតជានិច្ចតាមរបៀប "ខ្ញុំអាច (I can) ខ្ញុំនឹង (I will) ខ្ញុំគិតថាខ្ញុំ(I am)"
- ម្យ៉ាងទៀត ពួកអ្នកចាញ់ប្រមូលផ្តុំដំណើរការគិត (Walking thoughts) ទៅលើអ្វីដែលពួកគេគួរតែបានធ្វើ (On what they should have done) ឬក៏ទៅលើអ្វីដែលពួកគេពុំធ្វើ (What they don't do)។
- ប្រសិនបើអ្នកជឿថា អ្នកពុំអាចធ្វើរឿងអ្វីមួយទេនោះ ដូច្នេះវាមិនសំខាន់ថាអ្នកខិតខំប៉ុណ្ណាទេ ពីព្រោះអ្នកបានចាញ់រួចជាស្រេចទៅហើយ ។
- ប្រសិនបើអ្នកជឿថា អ្នកអាចធ្វើរឿងអ្វីមួយនោះ អ្នកបានឈ្នះក្នុងសមរភូមិជាច្រើនរួចហើយ ។

### តើត្រូវមានអារម្មណ៍ទទួលបានថាមពលពីការគិតអំពីលទ្ធភាពយ៉ាងដូចម្តេច

- ប្រសិនបើជាធម្មជាតិ អ្នកជាមនុស្សវិជ្ជមានដែលឱបក្រសោបយកការគិតអំពីលទ្ធភាពនោះអ្នកកំពុងស្ថិតនៅលើផ្លូវត្រូវហើយ ។
- ប៉ុន្តែមនុស្សខ្លះពុំមែនជាមនុស្សវិជ្ជមានឡើយ ជាធម្មជាតិពួកគេអវិជ្ជមាន ឬក៏ក្រអឺតក្រទម
  - ✶ ពួកគេគិតថា អ្នកគិតអំពីលទ្ធភាពជាពួកស្រែ (Naïve) ឬពួកឆ្កួត (Foolish)
  - ✶ តើមានមនុស្សដែលបានជោគជ័យបំផុតប៉ុន្មាននាក់ដែលជាមនុស្សអវិជ្ជមាន? គ្មាន !
  - ✶ តើមានអ្នកគិតអំពីអលទ្ធភាព (Impossibility thinker) ប៉ុន្មាននាក់ដែលអ្នក

បានដឹងថាសម្រេចបានសមិទ្ធផលធំដុំនោះ ? គ្មាន !

- មនុស្សដែលមានខួរក្បាល "ពុំអាចធ្វើបាន it-can't-be done" មាន ២ ជម្រើស :
  - ✶ ពួកគេអាចរំពឹងទុករឿងអាក្រក់បំផុត ហើយបន្តថ្លង់កាត់រឿងអាក្រក់នោះ
  - ✶ ឬមួយពួកគេផ្លាស់ប្តូរការគិតរបស់ពួកគេ
- ប្រសិនបើអ្នកចង់ឱ្យការគិតអំពីលទ្ធភាពផ្តល់ផលឱ្យអ្នក អ្នកត្រូវចាប់ផ្តើមដូចតទៅ :

**១. ឈប់ផ្តោតលើអលទ្ធភាព**

- ជំហានទី១ នៅក្នុងការក្លាយខ្លួនជាអ្នកគិតអំពីលទ្ធភាព គឺត្រូវបញ្ឈប់ខ្លួនអ្នកឱ្យឈប់ស្វែងរក និងសំអាងទៅលើអ្វីៗដែលខុសក្នុងស្ថានភាពណាមួយនោះ
  - ✶ ប្រសិនបើការគិតអំពីលទ្ធភាពជារឿងថ្មីសម្រាប់អ្នក អ្នកត្រូវខិតខំហ្វឹកហាត់ខ្លួនឯងដើម្បីកំចាត់ចោលនូវការនិយាយអំពីខ្លួនឯងដោយអវិជ្ជមាន ដែលកប់នៅក្នុងខួរក្បាលរបស់អ្នក ។
  - ✶ ប្រសិនបើជាស្វ័យប្រវត្តិ ចាប់ផ្តើមចុះបញ្ជីនូវរឿងទាំងអស់ដែលអាចដើរខុសផ្លូវ ឬក៏មូលហេតុទាំងអស់ ដែលថាសព្វយ៉ាងពុំអាចធ្វើបានទេនោះ សូមបញ្ឈប់ខ្លួនឯងនិងនិយាយថា "កុំទៅទៀត" ហើយសួរថា "តើធ្វើយ៉ាងម៉េចត្រូវបំពោះរឿងនេះ" ។ ធ្វើបែបនេះទើបជួយឱ្យអ្នកបានចាប់ផ្តើម ។
  - ✶ ប្រសិនបើភាពអវិជ្ជមានជាបញ្ហាធំសម្រាប់អ្នកពិតប្រាកដនោះ ហើយរឿងទុទិដ្ឋិនិយមតែងតែរត់ចេញពីមាត់អ្នក ដោយអ្នកថែមទាំងពុំបានគិតផងនោះ អ្នកត្រូវស្នើសុំការជួយពីមិត្តភ័ក្ត ឬសមាជិកគ្រួសារដើម្បីពញ្ញាក់រូបអ្នកនៅពេលដែលអ្នកមានគំនិតអវិជ្ជមាន ។

**២. ស្ថិតនៅឱ្យឆ្ងាយពីអ្នកឯកទេស (Expert)**

- អ្នកដែលហៅថាអ្នកឯកទេស តែងតែធ្វើច្រើនដើម្បីបាញ់ទម្លាក់ចោលនូវសុបិនរបស់មនុស្សជាងអ្នកណាៗទាំងអស់ ។
  - ✶ អ្នកគិតអំពីលទ្ធភាពតែងតែស្ទាក់ស្ទើរដើម្បីបោះបង់ចោលនូវអ្វីមួយ ដោយចាត់ទុក

ថាអលទ្ធភាព ។

✶ ស្តេច Napoleon Bonarpate និយាយថា : "ពាក្យថាអលទ្ធភាព ពុំមែនរបែង នៅក្នុងវចនានុក្រមរបស់ខ្ញុំទេ" ។

✶ ប្រសិនបើអ្នកចង់សម្រេចអ្វីមួយ សូមអនុញ្ញាតឲ្យខ្លួនអ្នកជឿជាក់ថាវាមានលទ្ធភាព ទោះបីជាអ្នកឯកទេសអាចនិយាយថាយ៉ាងនេះយ៉ាងនោះក៏ដោយ ។

## ៣_សម្លឹងមើលលទ្ធភាពនៅក្នុងគ្រប់ស្ថានភាពណ៍ទាំងអស់

- ក្លាយជាអ្នកគិតអំពីលទ្ធភាព វាច្រើនជាងប្រកែកពុំឲ្យខ្លួនឯងក្លាយជាអវិជ្ជមាន វាមានអ្វីច្រើនជាងនេះទៀត ។

✶ ត្រូវសម្លឹងមើលរកលទ្ធភាពជាវិជ្ជមាននានា ទោះបីជាកាលៈទេសៈយ៉ាងណាក្តី ។

✶ ក្នុងស្ថានការណ៍អាក្រក់ ត្រូវសម្លឹងមើលអ្វីដែលល្អ សម្លឹងមើលថា ត្រូវកែប្រែយ៉ាងដូចម្តេច ទិតខំឲ្យវាប្រសើរឡើង ។

◈ វាងាយស្រួលត្រង់ដើរទៅសម្លឹងមើលលើអ្វីដែលមនុស្សដទៃធ្វើបានដោយអាក្រក់ ។

◈ ឬសម្លឹងមើលរកអ្វីដែលល្អ ដែលមនុស្សដទៃកំពុងអនុវត្ត ហើយយកវាមកអនុវត្ត ។

## ៤_មានសុបិនកាន់តែធំឡើង

- វិធីដែលល្អ គឺបណ្តុះគំនិតអំពីលទ្ធភាព (A possibility mind-set) គឺតម្រូវឲ្យខ្លួនអ្នកមានសុបិនកាន់តែធំឡើង ជាងសុបិនដែលជាធម្មតាធ្លាប់មាន ។

✶ មនុស្សស្ទើរតែទាំងអស់តែងតែមានសុបិនតូចពេក ពួកគេពុំបានគិតធំឲ្យបានគ្រប់គ្រាន់ ។

✶ សូមធ្វើផែនការឲ្យបានអស្ចារ្យដូចអ្នកចង់បាន ពីព្រោះ ២៥ឆ្នាំទៀតផែនការនោះនឹងហាក់ដូចជាអន់ណាស់ ។

✶ សូមធ្វើផែនការឲ្យបាន ១០ដងអស្ចារ្យជាងពេលណាត្រូវរៀបផែនការជាដំបូង ។

២៥ឆ្នាំចាប់ពីឥឡូវនេះទៅ អ្នកនឹងចូលថាហេតុដូចម្ដេចបានជាពេលមុននោះអ្នកពុំបានលើកផែនការឱ្យអស្ចារ្យ ៥០ដងច្រើនជាងនេះ ។

- ប្រសិនបើអ្នកព្រួញប្រាជ្ញខ្លួនឯងឱ្យមានសុបិនរីកធំឡើង ដើម្បីស្រមៃឃើញថា ស្ថាប័នរបស់អ្នកនឹងមានទំហំធំជាងបច្ចុប្បន្ន ដើម្បីធ្វើឱ្យគោលដៅ (Goals) របស់អ្នកយ៉ាងហោចណាស់បានឈានមួយជំហានទៅមុខ ហួសអ្វីដែលធ្វើឱ្យអ្នកកំពុងសុខស្រួល ។
    - ✶ អ្នកត្រូវចាប់បង្ខំឱ្យរីកធំធាត់ឡើង វានឹងផ្ដល់ឱ្យអ្នកដើម្បីជឿលើលទ្ធភាពនានាដែលកាន់តែអស្ចារ្យទៅ ។

## ៥_ចោទសួរសំណួរអំពីស្ថានភាពដដែល

- មនុស្សស្ទើរតែទាំងអស់សុទ្ធតែចង់ឱ្យជីវិតរបស់ពួកគេកាន់តែល្អប្រសើរឡើង បានន័យថាពួកគេឱ្យតម្លៃទៅលើសន្តិភាព និងស្ថេរភាពក្នុងពេលជាមួយគ្នានេះដែរ ។
    - ✶ មនុស្សជាញឹកញាប់តែងភ្លេចថា អ្នកពុំអាចកាន់តែល្អប្រសើរឡើង ហើយស្ថិតក្នុងស្ថានភាពដដែលនោះទេ ។
    - ✶ ការរីកធំធាត់ (Growth) មានន័យថាការផ្លាស់ប្ដូរ (Change)។
    - ✶ ការផ្លាស់ប្ដូរតម្រូវឱ្យប្រឈមទល់នឹងស្ថានភាពដដែល (The status quo)។
- ប្រសិនបើអ្នកចង់បានលទ្ធភាពកាន់តែពិសេស អ្នកពុំអាចទទួលយកនូវអ្វីដែលអ្នកមានបច្ចុប្បន្នបានឡើយ ។
- កាលណាអ្នកក្លាយជាអ្នកគិតអំពីលទ្ធភាព អ្នកនឹងប្រឈមនឹងមនុស្សជាច្រើនដែលចង់ឱ្យអ្នកបោះបង់ចោលនូវសុបិនរបស់អ្នក ហើយទទួលយកនូវស្ថានភាពដដែល ។
    - ✶ សមិទ្ធករ (Achievers) តែងតែប្រកែកមិនទទួលយកនូវស្ថានភាពដដែល ។
- ប្រសិនបើអ្នកស្វែងរកលទ្ធភាពកាន់តែអស្ចារ្យសម្រាប់ខ្លួនឯង ស្ថាប័ន ឬក៏គ្រួសាររបស់អ្នក ហើយអ្នកដទៃនឹងប្រឈមជាមួយអ្នកអំពីរឿងនេះ សូមអ្នកសុខស្រួលក្នុងចិត្តដោយដឹងថា ក្នុងពេលឥឡូវនេះអ្នកគិតអំពីលទ្ធភាពក្នុងប្រទេស និងលើពិភពលោកកំពុងគិតអំពី

ការព្យាបាលជម្ងឺមហារីក អភិវឌ្ឍន៍ប្រភពថាមពលថ្មី ចិញ្ចឹមមនុស្សស្រេកឃ្លាន និងធ្វើឲ្យជីវិតប្រសើរឡើង ។ ពួកគេប្រចាំងនឹងស្ថានភាពដដែលដែលអាក្រក់ ហើយអ្នកគួរធ្វើយ៉ាងដូចម្តេចដែរ ?

## ៦_ការរៀនសូត្រពីសមិទ្ធករដ៏ពូកែៗ

- អ្នកអាចអានបានច្រើនអំពីការគិតអំពីលទ្ធភាព ដោយសិក្សាអំពីសមិទ្ធករល្បីៗ ។
- ត្រូវមានបំណងប្រាថ្នាដើម្បីជោគជ័យ ជំនឿលើខ្លួនឯង ការជឿជាក់លើសមត្ថភាព ។
  - ✶ មនុស្សដែលជឿថាខ្លួនឯងពុំអាចនឹងពុំអាចសម្រេចអ្វីបានឡើយ ។
  - ✶ តែបើអ្នកជឿលើខ្លួនឯងថាអាចនោះ អ្នកនឹងអាច : នេះហើយគឺជាការគិតអំពីលទ្ធភាព ។

✖

✖ ✖

# ជំពូកទី៧

# សូមរៀនអំពីការគិតដោយត្រិះរិះ (សញ្ជឹងគិត)

# LEARN FROM REFLECTIVE THINKING

- ដើម្បីសង្ស័យទៅលើអ្វីៗទាំងអស់ ឬក៏ដើម្បីជឿលើអ្វីៗទាំងអស់ គឺមានដំណោះស្រាយសមស្របពីរស្មើគ្នា : ទាំងពីរនោះគឺពុំចាំបាច់មានការត្រិះរិះឡើយ (Reflection)។
- សង្វាក់នៃសង្គមរបស់យើងពុំបានលើកទឹកចិត្តដល់ការគិតដោយត្រិះរិះឡើយ :
  - ✶ មនុស្សជាច្រើនតែងតែធ្វើសិន បន្ទាប់មកបានគិត ។
- ការគិតដោយត្រិះរិះជម្រុញឲ្យគំនិតរបស់អ្នករំងាស់ (Simmer) ដូចកម្តៅសម្ល លុះត្រាតែគំនិតនោះពុះឡើង ។
  - ✶ តាមរយៈដំណើរការនេះ គោលបំណងរបស់អ្នកដើម្បីត្រិះរិះ ថាបានរៀនសូត្រអ្វីខ្លះដើម្បីជោគជ័យ និងការខ្វះខាតរបស់អ្នក រកឲ្យឃើញថាអ្វីដែលគួរធ្វើដដែលឡើងវិញហើយកំណត់ថា អ្វីខ្លះដែលអ្នកត្រូវផ្លាស់ប្តូរ ។
  - ✶ នេះជាលំហាត់ដ៏មានតម្លៃ ។
  - ✶ តាមរយៈការពិនិត្យមើលអំពីស្ថានការណ៍ពីអតីតកាល អ្នកអាចគិតយល់បានច្រើនបំផុត ។

## ១-ការគិតដោយត្រិះរិះផ្តល់ឱ្យអ្នកនូវទស្សនវិស័យពិតប្រាកដ

- កាលណាអ្នកត្រិះរិះ អ្នកអាចដាក់បទពិសោធន៍ណាមួយទៅក្នុងទស្សនវិស័យ ÷ អ្នកអាចវាយតម្លៃអំពីពេលវេលារបស់វា អ្នកអាចទទួលនូវការវាយតម្លៃថ្មីសម្រាប់រឿងអ្វីៗដែលពីមុននោះពុំបានកត់សម្គាល់, មនុស្សជាច្រើនអាចទទួលស្គាល់ពលីកម្មរបស់ឪពុកម្តាយគេ ឬមនុស្សដទៃទៀត លុះណាតែពួកគេបានក្លាយធ្វើជាឪពុកម្តាយដោយខ្លួនឯង ។

- នេះជាប្រភេទនៃទស្សនវិស័យដែលចេញមកអំពីការត្រិះរិះ ។

**២-ការគិតដោយត្រិះរិះផ្តល់ភាពសុចរិតខាងអារម្មណ៍ដល់ជីវិតនៃគំនិតរបស់អ្នក**

- មនុស្សមួយចំនួនមានទស្សនវិស័យល្អនៅពេលគេប្រទះនឹងពេលវេលារំភើបចិត្តមួយ (An emotional moment)។
- បុគ្គលជាច្រើនដែលពេញចិត្តចំពោះការរំភើបចិត្តទៅលើបទពិសោធន៍ណាមួយ តែងសម្លឹងមើលទៅក្រោយដើម្បីចាប់យកបទពិសោធន៍នោះ ដោយពុំបានវាយតម្លៃបទពិសោធន៍នោះជាដំបូងសិន ។ *(បែបនេះហើយជាមូលហេតុមួយដែលវប្បធម៌របស់យើងផលិតនូវអ្នកស្វែងរកការរំភើបចិត្តជាច្រើន)*។
- ដូចគ្នានេះដែរ មនុស្សខ្លះដែលរួចផុតពីបទពិសោធន៍ភ័យរន្ធត់ ជាធម្មតាតែងជៀសវាងនូវស្ថានភាពដូចគ្នានោះជាទីបំផុត ដែលពេលខ្លះចងពួកគេទៅនឹងចំណងខាងអារម្មណ៍ (Emotional knots)។
- ការគិតដោយត្រិះរិះជួយអ្នកឱ្យឃ្លាតឆ្ងាយអំពីអារម្មណ៍តឹងតែងនៃបទពិសោធន៍ល្អ ឬបទ-ពិសោធន៍អាក្រក់ ហើយមើលឃើញបទពិសោធន៍ទាំងនោះដោយភ្នែកភ្លឺស្រឡះ ។
  - ✶ អ្នកអាចមើលឃើញការរំភើបចិត្តពីអតីតកាល ក្រោមពន្លឺនៃភាពចាស់ទុំខាងអារម្មណ៍ (Emotional maturity) ហើយពិនិត្យមើលសោកនាដកម្មក្រោមពន្លឺនៃការពិត និងឡូហ្សិក (Thruth and logic)។
  - ✶ ដំណើរការបែបនេះជួយឱ្យមនុស្សម្នាក់បញ្ឈប់ស្ពាយជាប់ខ្លួននូវសម្ពាយអារម្មណ៍អវិជ្ជមាន (Negative emotional bagage)។
- ប្រធានាធិបតី George Washington កត់សម្គាល់ថា : "យើងពុំគួរមើលទៅក្រោយឡើយ លុះណាតែការមើលទៅក្រោយនោះផ្តល់នូវមេរៀនមានប្រយោជន៍អំពីកំហុសពីអតីតកាល ហើយដើម្បីគោលបំណងឆ្លៀតឱកាសអំពីបទពិសោធន៍ល្អ" ។

✶ អារម្មណ៍ណាមួយដែលអាចងើបឈរឡើងក្រោមពន្លឺនៃការពិត ហើយស្ថិតស្ថេរ នៅជាមួយពេលវេលា តែងមានសុចរិតខាងអារម្មណ៍ (Emotional integrity) ហេតុដូច្នេះហើយវាតែងមានតម្លៃសម្រាប់ស្មារតី និងបេះដូងរបស់អ្នក ។

## ៣_ការគិតដោយត្រិះរិះបង្កើនការជឿទុកចិត្តរបស់អ្នកនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត

- តើមានពេលណាមួយដែលអ្នកធ្វើការវិនិច្ឆ័យភ្លាមៗ ហើយបន្ទាប់មកអ្នកសង្ស័យថាបានធ្វើដោយត្រឹមត្រូវដែរឬទេ ?

✶ ម្នាក់ៗជាទូទៅតែងធ្វើយ៉ាងដូច្នេះ ។

✶ ការគិតដោយត្រិះរិះអាចជួយឱ្យរំសាយការសង្ស័យនោះ ។

✶ វាផ្តល់ដល់អ្នកផងដែរនូវជំនឿទុកចិត្តទៅលើសេចក្តីសម្រេចចិត្តក្រោយៗទៀត ។

✶ កាលណាអ្នកធ្លាប់បានគិតទៅលើបញ្ហាណាមួយ អ្នកពុំចាំបាច់ធ្វើឡើងវិញនូវជំហានដដែលៗក្នុងដំណើរការគិត កាលណាអ្នកជួបប្រទះនឹងរឿងបែបនេះម្តងទៀត ។

✶ អ្នកបានទទួលរួចហើយនូវសញ្ញាសម្គាល់ផ្លូវខាងស្មារតី (Mental road markers) ដោយធ្លាប់បានទៅដល់ ទីនោះរួចហើយ :

◈ ប្រការនេះបង្រួញ និងបង្កើនល្បឿនដល់ពេលវេលានៃការគិត (Thinking time) ហើយផ្តល់ដល់អ្នកនូវជំនឿទុកចិត្ត ។

◈ ក្នុងរយៈពេលយូរវាអាចពង្រឹងនូវអភន្តរញាណ (Intuition)។

## ៤_ការគិតដោយត្រិះរិះបំភ្លឺដល់រូបភាពធំ

- កាលណាអ្នកចាប់យកការគិតដោយត្រិះរិះ អ្នកអាចដាក់គំនិត និងបទពិសោធន៍ទៅក្នុងបរិបទមួយជាក់លាក់ជាង (A more accurate context)។
- ការគិតដោយត្រិះរិះលើកទឹកចិត្តយើងឱ្យដើរត្រឡប់ថយក្រោយ និងចំណាយពេលវេលាសញ្ជឹងគិតអំពីអ្វីដែលយើងធ្លាប់បានធ្វើ និងអំពីអ្វីដែលយើងធ្លាប់បានឃើញ ។

✶ មនុស្សដែលបាត់បង់ការងារ ត្រិះរិះអំពីអ្វីដែលបានកើតឡើង មនុស្សនោះអាច

មើលឃើញនូវគំរូនៃព្រឹត្តិការណ៍ (A pattern of events) ដែលនាំឱ្យបញ្ឈប់ការងារដល់រូបគេ ។

* ប្រសិនបើគេមើលដងដែរទៅលើឧបទ្ទវហេតុ (Incidents) ដែលកើតឡើងក្រោយនោះ (In the larger scheme of things) គេប្រហែលជាដឹងថា នៅក្នុងរូបភាពធំ គេមានលក្ខណៈប្រសើរជាងនៅក្នុងមុខតំណែងថ្មីរបស់គេ ពីព្រោះមុខតំណែងនោះសមស្របទៅនឹងជំនាញ និងបំណងប្រាថ្នារបស់គេ ។
* គ្មានការត្រិះរិះ វាជាការលំបាកណាស់ដើម្បីមើលឃើញអំពីរូបភាពធំ ។

## ៥_ការគិតដោយត្រិះរិះចាប់យកនូវបទពិសោធន៍ល្អ ហើយធ្វើឱ្យបទពិសោធន៍នោះក្លាយជាបទពិសោធន៍មានតម្លៃ

- ប្រសិនបើអ្នកទើបតែចាប់ផ្តើមក្នុងអាជីពរបស់អ្នក វាហាក់ដូចជាមានមនុស្សតិចតួចប៉ុណ្ណោះដែលមានបំណងផ្តល់ឱកាសដល់អ្នកដែលគ្មានបទពិសោធន៍ ។
- ជាមួយគ្នានោះ អ្នកប្រហែលជាបានឃើញមនុស្សដែលបានធ្វើការងារក្នុងរយៈពេល ២០ឆ្នាំ ដែលបន្តធ្វើការងាររបស់ពួកគេដោយទន់ខ្សោយដដែល ។

* ប្រសិនបើបែបនេះ អ្នកប្រហែលនឹងរសាយចិត្ត ។
* អ្នកនិពន្ធ William Sakerspeare សរសេរថា : "បទពិសោធន៍គឺជាគ្រឿងអលង្ការ ហើយវាត្រូវតែអញ្ជឹង ដើម្បីជាញឹកញាប់គេត្រូវជាវវាដោយតម្លៃគ្មានកំណត់ ។
* អញ្ជឹងបទពិសោធន៍តែឯងពុំបានបង្កើនតម្លៃដល់ជីវិតឡើយ ។
* ពុំមែនជាបទពិសោធន៍ដែលចាំបាច់ត្រូវតែមានតម្លៃនោះ ។
* គឺជាលទ្ធផលរបស់មនុស្សដែលចេញពីខាងក្នុងខ្លួនគេ ព្រោះមនុស្សនោះមានបទពិសោធន៍ ។
* ការគិតដោយត្រិះរិះ ប្រែក្លាយបទពិសោធន៍ទៅជាការគិតទម្លុះជ្រាលជ្រៅ (Insight) ។

- យើងគួរតែប្រយ័ត្ន ដើម្បីដកចេញពីបទពិសោធន៍ណាមួយនូវគតិបណ្ឌិត(Wisdom) ទាំងមូលដែលមាននៅក្នុងបទពិសោធន៍នោះ ពុំមែនដូចសត្វឆ្មាដែលអង្គុយលើថ្មក្តៅឡើយ ឆ្មានោះនឹងពុំអង្គុយលើថ្មក្តៅនោះទៀតទេ បែបនេះគឺជារឿងល្អ តែឆ្មានោះក៏ពុំអង្គុយផងដែរលើថ្មដែលត្រជាក់តទៅទៀត ។
- បទពិសោធន៍មួយនឹងមានតម្លៃ កាលណាវាផ្តល់ព័ត៌មាន ឬបំពាក់ឲ្យយើងឲ្យប្រទះនឹងបទពិសោធន៍ថ្មី ។ ការគិតដោយត្រិះរិះជួយយើងឲ្យធ្វើយ៉ាងនោះ ។

## តើត្រូវឱបក្រសោបមេរៀននៃការគិតដោយត្រិះរិះយ៉ាងដូចម្តេច ?

- ប្រសិនបើអ្នកដូចមនុស្សស្ទើរតែទាំងអស់នៅក្នុងសង្គមយើងសព្វថ្ងៃអញ្ចឹងដែរ អ្នកប្រហែលជាធ្វើការគិតដោយត្រិះរិះយ៉ាងតិចបំផុត ។
    - ✶ បើអញ្ចឹងមែន អ្នកប្រហែលជាត្រូវត្រឡប់មកក្រោយច្រើនជាងអ្នកត្រូវគិត ។
- សូមចងចាំនូវអនុសាសន៍ដូចខាងក្រោម ដើម្បីបង្កើនសមត្ថភាពរបស់អ្នកឲ្យគិតដោយត្រិះរិះ ។
- ទស្សនវិទូក្រិច Socrates បានកត់សម្គាល់ថា : "ជីវិតដែលពុំបានត្រួតពិនិត្យមើល ពុំមានតម្លៃសមនឹងរស់នៅឡើយ (The unexamined life is not worth living)។
- ប៉ុន្តែសម្រាប់មនុស្សជាច្រើន ការត្រិះរិះ និងការពិនិត្យមើលលើខ្លួនឯង (Self-examination) ពុំមែនចេញមកដោយឯកឯងឡើយ ។
    - ✶ វាអាចជាសកម្មភាពមិនសមស្រប (A fairly uncomfortable activity) ដោយមានមូលហេតុប្លែកៗ :

◈ ពួកគេមានពេលវេលាដ៏ពិបាក ដើម្បីយកចិត្តទុកដាក់ប្រមូលផ្តុំ ។

◈ ពួកគេមើលឃើញថាដំណើរការនោះអត់ប្រយោជន៍ ។

◈ ឬក៏ពួកគេពុំចង់ចំណាយពេលវេលាច្រើន ដើម្បីគិតអំពីបញ្ហាអារម្មណ៍ស្មុគ្រស្មាញ (Emotional difficult issues) ។

◈ ប៉ុន្តែប្រសិនបើអ្នកមិនចំណាយពេលវេលាដើម្បីរឿងនេះទេ អ្នកប្រហែលជាពុំបានធ្វើការគិតដោយត្រិះរិះឡើយ ។

**១-ធ្វើឱ្យខ្លួនអ្នកមានស្មារតីមូល (កុំបែកកម្មដ្ឋាន)**

- ក៏ដូចជាការគិតប្រភេទផ្សេងទៀត ការត្រិះរិះតម្រូវឱ្យនៅឯកោម្នាក់ឯង (Solitude)។
- ការមិនមូលអារម្មណ៍ (Distraction) និងការត្រិះរិះពុំអាចឲ្យកខ្ញុំគ្នាបានឡើយ ។

  ✶ វាមិនដូចរឿងដែលអ្នកអាចធ្វើបានល្អនៅជិតទូរទស្សន៍នៅក្នុងបន្ទប់មួយ ក្នុងពេលដែលទូរស័ព្ទរោទិ៍ ឬក៏មានកូនក្មេងនៅក្នុងបន្ទប់ជាមួយគ្នានេះឡើយ ។

  ✶ ត្រូវកំណត់ពេលវេលាដោយឡែកដើម្បីត្រិះរិះដោយប្រមូលផ្តុំអារម្មណ៍ឱ្យមូលនៅក្នុងពេលវេលាកំណត់ទុកនោះ ។

  ✶ ទីកន្លែងពុំសំខាន់ទេ ឱ្យតែអ្នកអាចកុំបែកកម្មដ្ឋាន និងមានការរំខានផ្សេងៗ ។

**២-ពិនិត្យមើលឡើងវិញជារឿយៗនូវកម្មវិធី ឬកំណត់ត្រារបស់អ្នក**

- មនុស្សជាច្រើនប្រើប្រាស់នូវប្រក្រតីទិនរបស់គេធ្វើជាឧបករណ៍នៃការធ្វើផែនការដែលត្រូវធ្វើ ។

  ✶ តែមានមនុស្សមួយចំនួនតូចប្រើប្រាស់ប្រក្រតីទិននោះធ្វើជាឧបករណ៍នៃការគិតដោយត្រិះរិះ ។

- ប៉ុន្តែតើអ្វីដែលអាចល្អប្រសើរជាង សម្រាប់ជួយអ្នកឱ្យពិនិត្យមើលឡើងវិញនូវកន្លែងដែលអ្នកធ្លាប់តាំងនៅ និងអ្វីដែលអ្នកបានធ្វើ (Journal) លើកលែងតែកំណត់ត្រានោះ ។

* ✶ អ្នកត្រូវប្រើប្រាស់កំណត់ត្រា ដើម្បីសរសេរកត់ត្រានូវចំណុចសំខាន់ៗនៃគំនិត និងសកម្មភាពដើម្បីអាចប្រើប្រាស់នៅពេលក្រោយដោយចាប់របាស់ ។
* ✶ អ្នកអាចប្រតិកម្មនូវចំណុចនៃសកម្មភាព (Action points) ឬក៏ប្រតិភូសកម្មភាពនោះឱ្យអ្នកណាផ្សេងទៀត ។

- ប្រក្រតីទិន ឬក៏កំណត់ត្រា រំលឹកអ្នកថាតើអ្នកបានប្រើប្រាស់ពេលវេលាយ៉ាងដូចម្ដេច បង្ហាញអ្នកថាតើសកម្មភាពរបស់អ្នកសមស្របបានទៅនឹងអាទិភាពហើយឬនៅ ហើយជួយអ្នកឱ្យមើលឃើញថា តើអ្នកមានការរីកចំរើនដែរឬទេ ។
- ប្រតិទិន និងកំណត់ត្រាក៏ជួយផ្ដល់ឱកាសដល់អ្នកផងដែរ ដើម្បីរំលឹកអំពីសកម្មភាពដែលអ្នកពុំមានពេលដើម្បីត្រិះរិះពីមុនមក ។
- គំនិតដ៏មានតម្លៃខ្លះដែលអ្នកធ្លាប់មាន ប្រហែលជាត្រូវបាត់បង់ ពីព្រោះអ្នកបានផ្ដល់ពេលវេលាដល់ខ្លួនឯងដើម្បីត្រិះរិះស្របទៅតាមការចាំបាច់ ។

## ៣-សួមសាកសួរនូវសំណួរដ៏ត្រឹមត្រូវ

- តម្លៃដែលអ្នកទទួលបានពីការត្រិះរិះ និងចំណុះលើប្រភេទសំណួរដែលអ្នកចោទសួរខ្លួនឯង
  * ✶ បើសំណួរទាំងនោះល្អប្រសើរអ្នកនឹងបានមាសច្រើន ដែលអ្នកជីកវែយកអំពីការគិតដោយត្រិះរិះ ។
- កាលណាអ្នកត្រិះរិះ អ្នកគួរគិតពាក់ព័ន្ធដល់តម្លៃទំនាក់ទំនង និងបទពិសោធន៍របស់អ្នកដូចជាឧទាហរណ៍ខាងក្រោមនេះ ÷
  * ✶ ការរីកចំរើនផ្ទាល់ខ្លួន (Personal Growth)

    តើអ្វីខ្លះដែលខ្ញុំបានរៀនសូត្រថ្ងៃនេះ ដែលជួយឱ្យខ្ញុំរីកចំរើនឡើង ? តើខ្ញុំអាចយកបទពិសោធន៍នេះទៅអនុវត្តក្នុងជីវិតអ្នកដូចម្ដេច ? ពេលណាខ្ញុំគួរយកទៅអនុវត្ត ?
  * ✶ តម្លៃបន្ថែម (Adding Value)

តើថ្ងៃនេះខ្ញុំផ្តល់តម្លៃបន្ថែមដល់អ្នកណា ? តើហេតុម្តេចខ្ញុំដឹងថា ខ្ញុំបានផ្តល់តម្លៃបន្ថែមដល់ជននោះ ? តើខ្ញុំអាចតាមដានមើល និងប្រមូលផ្តុំបាននូវផលប្រយោជន៍ជាវិជ្ជមានដែលជននោះបានទទួលដែរឬទេ ?

✶ ការដឹកនាំ (Leadership)

តើខ្ញុំបានដឹកនាំជាគំរូដែរឬទេ ? តើខ្ញុំបានលើកតម្កើងមនុស្ស និងស្ថាប័នទៅកាន់កំរិតខ្ពស់ដែរឬទេ ? តើខ្ញុំបានធ្វើអ្វីខ្លះ ហើយតើខ្ញុំបានធ្វើយ៉ាងដូចម្តេច ?

✶ ការរៀបការ និងគ្រួសារ

តើខ្ញុំបានប្រាស្រ័យទាក់ទងដោយក្តីស្រឡាញ់ចំពោះគ្រួសារខ្ញុំដែរឬទេ ? តើខ្ញុំបានបង្ហាញពីក្តីស្រឡាញ់នោះយ៉ាងដូចម្តេច ? តើពួកគេទទួលអារម្មណ៍ដែរឬទេ ? តើពួកគេបានត្រឡប់នូវក្តីស្រឡាញ់នោះមកវិញដែរឬទេ ?

✶ ក្រុមស្និទ្ធស្នាល (Inner Circle)

តើខ្ញុំបានចំណាយពេលវេលាគ្រប់គ្រាន់ជាមួយតួអង្គសំខាន់ៗរបស់ខ្ញុំដែរឬទេ ? តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បីជួយពួកគេឲ្យកាន់តែមានជោគជ័យឡើង? តើក្នុងវិស័យណាខ្លះដែលខ្ញុំអាចបង្ហាត់ពួកគេបាន?

✶ ការរកឃើញ (Discoveries)

តើអ្វីខ្លះដែលខ្ញុំពេីបប្រទះក្នុងថ្ងៃនេះ ដែលខ្ញុំត្រូវការផ្តល់ពេលវេលាគិតច្រើន ? តើមេរៀនទាំងនេះខ្ញុំត្រូវរៀនសូត្រដែរឬទេ ? តើមានអ្វីខ្លះដែលខ្ញុំត្រូវសម្រេចឲ្យបានដែរឬទេ ?

✶ តើអ្នករៀបចំពេលវេលានៃការត្រិះរិះយ៉ាងណា គឺអាស្រ័យលើរូបអ្នក

◈ អ្នកអាចប្រកាន់យកគំរូណាមួយដែលសមស្របទៅនឹងតម្លៃរបស់អ្នក

◈ ឬក៏អ្នកសាកល្បងនូវប្រព័ន្ធមួយដូចជា :

| ឆ្នាំ | ចំណុចបត់ | ឥទ្ធិពល |
|---|---|---|
| Year | Turning Point | Impact |

◈ ប្រព័ន្ធនេះល្អសម្រាប់ការត្រិះរិះមើលលើរូបភាពធំទូលាយ :

| ព្រឹត្តិការណ៍ | សារសំខាន់ | ចំណុចសកម្មភាព |
|---|---|---|
| Event | Significance | Action Point |

✶ ការធ្វើរបៀបខាងលើនេះ ដើម្បីជួយអ្នកឱ្យទទួលផលប្រយោជន៍អំពីការគិតដោយត្រិះរិះ ។

✶ បញ្ហាសំខាន់ គឺបង្កើតសំណួរដែលធ្វើឱ្យអ្នកបានទទួលផល ហើយអ្នកត្រូវកត់ត្រានូវគំនិតសំខាន់ៗដែលចេញមកអ្នកនៅក្នុងរយៈពេលនៃការត្រិះរិះ ។

## ៤.ផ្សារភ្ជាប់ការរៀនរបស់អ្នកតាមរយៈអំពើ

- ការកត់ត្រានូវគំនិតល្អៗ ដែលបានចេញមកពីការគិតដោយត្រិះរិះរបស់អ្នកមានតម្លៃ ប៉ុន្តែគ្មានអ្វីដែលជួយអ្នកឱ្យបានរីកចំរើនក្រៅអំពីការគិតរបស់អ្នកនោះទៅអនុវត្តជាសកម្មភាពឡើយ ។

✶ ដើម្បីធ្វើអញ្ចឹងកើតអ្នកត្រូវមានឆន្ទៈ ជាពិសេសបំផុត ការគិតដោយត្រិះរិះមានតម្លៃ ៣ គឺ :

◈ វាផ្តល់ឱ្យអ្នកនូវទស្សនវិស័យនៅក្នុងបរិបទ (Perspective within context)

◈ វាអនុគ្រោះឱ្យអ្នកតភ្ជាប់ជាបន្តបន្ទាប់ជាមួយនឹងដំណើរជីវិតរបស់អ្នក (Journey)

◈ វាផ្តល់ដំបូន្មាន (Counsel) និងទិស (Direction) ពាក់ព័ន្ធនឹងអនាគតរបស់អ្នក ។

នេះជាឧបករណ៍មានតម្លៃឥតឧបមាសម្រាប់ការរីកចំរើនផ្ទាល់ខ្លួនរបស់អ្នក ។

មានរបស់តិចតួចប៉ុណ្ណោះនៅក្នុងជីវិត ដែលអាចជួយអ្នកឱ្យបានរៀន និងធ្វើខ្លួនអ្នកឱ្យប្រសើរឡើង ដូចការគិតដោយត្រិះរិះនោះ ។

×

× ×

# ជំពូកទី៨
# សាកសួរសំណួរអំពីការគិតរបស់មហាជន
# QUESTION POPULAR THINKING

- ខ្ញុំពុំមែនជាម៉ាស៊ីនដែលចាំឆ្លើយតបឡើយ (An answering machine) ខ្ញុំជាម៉ាស៊ីនដែលចាំសួរសំណួរ (A questioning machine)។ ប្រសិនបើយើងមានចម្លើយទាំងអស់នោះ តើហេតុដូចម្តេចបានជាយើងអាចធ្លាក់បានទៅក្នុងភាពប្របូកប្របល់ (A mess)។
- អ្នកសេដ្ឋកិច្ចវិទូ John Maynard អះអាងថា : "ការពិបាកពុំមែនស្ថិតនៅត្រង់ការពង្រីកគំនិតថ្មីនោះទេ គឺនៅត្រង់រំដោះខ្លួនឲ្យចេញពីគំនិតចាស់"
    - ✶ ដើរទៅមុខដោយប្រឆាំងនឹងគំនិតរបស់មហាជនអាចជាការពិបាក មិនថាអ្នកជាធុរជន អាចារ្យ.មាតាបិតា ឬក៏ជាកម្លោះដែលពុំយល់ដឹងអំពីស្ទីលបច្ចុប្បន្នរបស់មហាជន ។
    - ✶ ប្រសិនបើអ្នកឲ្យតម្លៃទៅលើមហាជនជាជាងការគិតដោយល្អ អ្នកនឹងត្រូវកំរិតនូវសក្តានុពលរបស់អ្នកដើម្បីរៀនអំពីប្រភេទទាំងឡាយនៃការគិត ។
- ការគិតរបស់មហាជន គឺជា :
    - ✶ សាមញ្ញពេកដើម្បីយល់ដឹងអំពីតម្លៃនៃការគិតដោយល្អ (Good thinking)
    - ✶ រឹងត្អឹងពេកដើម្បីចាប់បានឥទ្ធិពលនៃការគិតដែលផ្លាស់ប្តូរ (Changed thinking)
    - ✶ គម្រក់ពេកដើម្បីធ្វើម្ចាស់លើដំណើរការគិតដោយមានចេតនា (Intentional thinking)
    - ✶ តូចពេកដើម្បីមើលឃើញឧត្តមគតិនៃការគិតដល់រូបភាពធំ (Big picture thinking)
    - ✶ ពេញចិត្តពេកដើម្បីដោះចំណងចេញពីសក្តានុពលនៃការគិតដោយប្រមូលផ្តុំ (Focused thinking)

- ✶ ប្រពៃណីជ្រុលពេកដើម្បីមើលឃើញក្តីរីករាយនៃការគិតដោយច្នៃប្រឌិត (Creative thinking)
- ✶ ល្ងង់ខ្លៅពេកដើម្បីទទួលស្គាល់សារសំខាន់នៃការគិតដោយប្រាកដនិយម (Realistic thinking)
- ✶ អត់វិន័យជ្រុលពេកដើម្បីបញ្ចេញអំណាចនៃការគិតជាយុទ្ធសាស្ត្រ (Strategic thinking)
- ✶ មានកំណត់ជ្រុលពេកដើម្បីចាប់អារម្មណ៍ដល់ថាមពលនៃការគិតអំពីលទ្ធភាព (Possibility thinking)
- ✶ ប្រកាន់និន្នាការជ្រុលពេកដើម្បីឱបក្រសោបយកមេរៀននៃការគិតដោយត្រិះរិះ (Reflective thinking)
- ✶ រាក់ពេកដើម្បីចោទសួរដើម្បីទទួលយកការគិតរបស់មហាជន (Popular thinking)
- ✶ មោទនៈជ្រុលពេកដើម្បីលើកទឹកចិត្តការចូលរួមនៃការគិតដោយចែករំលែក (Shared thinking)
- ✶ ស្រូបចូលក្នុងខ្លួនឯងពេកដើម្បីដកពិសោធន៍អំពីការពេញចិត្តនៃការគិតដោយមិនអាត្មានិយម
- ✶ មិនប្តេជ្ញាចិត្តជ្រុលពេកដើម្បីរីករាយនឹងផលប្រយោជន៍នៃការគិតដល់មូលដ្ឋានគ្រឹះ (Bottom-line thinking)

~ ប្រសិនបើអ្នកចង់ក្លាយទៅជាអ្នកគិតដ៏ពូកែ សូមចាប់ផ្តើមខ្លួនអ្នកឲ្យមានលទ្ធភាពក្លាយជាអ្នកមិនប្រជាប្រិយ (Unpopular) ។

# ហេតុអ្វីបានជាអ្នកគួរចោទសួរ អំពីការទទួលយកនូវការគិតរបស់មហាជន

## ១-ការគិតរបស់មហាជនពេលខ្លះមានន័យថាពុំមែនគិតឡើយ

- បញ្ហាជាមួយការគិតរបស់មហាជន គឺថាវាពុំចាំបាច់ឲ្យអ្នកត្រូវគិតអ្វីទាំងអស់ ។
- ការគិតដោយល្អគឺជាការងារដ៏ពិបាក
  - ✶ ប្រសិនបើងាយស្រួល ម្នាក់ៗសុទ្ធតែក្លាយជាអ្នកគិតដ៏ពូកែទៅហើយ
  - ✶ ជាអកុសល មនុស្សជាច្រើនរិតរំរស់នៅតាមរបៀបងាយស្រួល
  - ✶ ពួកគេពុំចង់ធ្វើការងារដ៏ពិបាកសម្រាប់ការគិត ឬក៏បង់ថ្លៃសម្រាប់ជោគជ័យឡើយ
  - ✶ វាងាយស្រួលដើម្បីធ្វើនូវអ្វីដែលមនុស្សដទៃទៀតធ្វើ ហើយសង្ឃឹមថាមនុស្សទាំងនោះបានគិតរួចហើយ
  - ✶ កាលណាមនុស្សដើរដោយងងឹតងងល់តាមនិន្នាការណាមួយនោះ ពួកគេពុំបានធ្វើការគិតដោយខ្លួនឯងឡើយ ។

## ២-ការគិតរបស់មហាជនផ្តល់នូវសេចក្តីសន្និមខុស

- មនុស្សជាច្រើនស្វែងរកសុវត្ថិភាព និងសន្តិសុខនៅក្នុងការគិតរបស់មហាជន
  - ✶ ពួកគេយល់ថា ប្រសិនបើមនុស្សជាច្រើនធ្វើអ្វីមួយនោះ កិច្ចការនោះមុខតែត្រឹមត្រូវហើយ ។ នោះហើយគឺជាគំនិតល្អ ។
  - ✶ ប្រសិនបើមនុស្សជាច្រើនបានទទួលយកវានោះ វាប្រហែលជាតំណាងឲ្យភាពត្រឹមត្រូវ (Fairness) សមភាព (Equality) មេត្តាធម៌ (Compassion) និងសុភវិនិច្ឆ័យ (Sensibility) ហើយមែនទេ ? ពុំមែនសុទ្ធតែត្រឹមត្រូវទេ ។
- ការគិតរបស់មហាជននិយាយថា ផែនដីស្ថិតនៅកណ្តាលពិភពលោក
  - ✶ តែ Copernicus បានសិក្សាអំពីផ្កាយ និងពិភពនានា ហើយបានបញ្ជាក់តាម

គណិតវិទ្យាថា ពិភពលោក និងពិភពនានានៅក្នុងប្រព័ន្ធរបស់ព្រះអាទិត្យ ហើយវិលជុំវិញព្រះអាទិត្យ ។

- ការគិតរបស់មហាជននិយាយថា ការវះកាត់ពុំចាំបាច់មានឧបករណ៍ដ៏ស្អាតនោះទេ
  - ✶ លោក Zoseph Lister បានសិក្សាអំពីសន្ទុស្សន៍មរណភាពខ្ពស់នៅក្នុងមន្ទីរ-ពេទ្យ ហើយបានណែនាំអំពីការអនុវត្តសម្លាប់មេរោគ (Antiseptic practices) ដែលភ្លាមៗបានសង្គ្រោះជីវិតជាច្រើន ។
- ការគិតរបស់មហាជននិយាយថា នារីពុំគួរមានសិទ្ធិបោះឆ្នោតឡើយ
  - ✶ តែមនុស្សដូច Emmeline Pankurst និង Susan B. Anthony បានប្រយុទ្ធ ហើយបានទទួលជោគជ័យអំពីសិទ្ធិនោះ ។
- ការគិតរបស់មហាជនបានដល់ពួក Nazis ទៅកាន់អំណាចនៅប្រទេសអាល្លឺម៉ង់ ហើយរបបហ៊ីត្លែរបានកាប់សម្លាប់មនុស្សរាប់លាននាក់ និងបំផ្លាញទ្វីបអឺរ៉ុបជិតខាង ។
- យើងត្រូវចងចាំជានិច្ចថា មានភាពខុសគ្នាដ៏សន្ធឹកសន្ធាប់រវាងការយល់ព្រមទទួលយក (Acceptance) និងប្រាជ្ញា (Intelligence)
  - ✶ មនុស្សប្រហែលនិយាយថា កាលណាមានចំនួនច្រើនមានសុវត្ថិភាពហើយ តែនេះពុំមែនជាការពិតជានិច្ចឡើយ ។
- ពេលខ្លះ ការគិតរបស់មហាជនពុំបានល្អ និងត្រឹមត្រូវឡើយ ។ ពេលខ្លះទៀត វាពុំសូវមានភាពជាក់ស្តែង ។
  - ✶ ឧទាហរណ៍ ប្រជាជននៅសហរដ្ឋអាមេរិកដែលមានបំណុលនៅក្នុងការប្រើប្រាស់ Credit Card របស់ខ្លួន ។ អ្នកដែលមានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរតែងនិយាយថា នោះគឺជាគំនិតដ៏អាក្រក់មួយ ។
  - ✶ មនុស្សជាច្រើននៅតែដើរតាមគំនិតរបស់មហាជនដែលគិតថា ទិញឥឡូវ សងពេលក្រោយ ។ ដូច្នេះគេមានតែបង់ប្រាក់ហើយបង់ប្រាក់ទៀត ។ គំនិតរបស់

មហាជនពេលខ្លះអន់ថយ កុំទុកឲ្យគំនិតទាំងនោះធ្វើឲ្យអ្នកក្លាយវង្វេងឡើយ ។

## ៣. ការគិតរបស់មហាជនគឺយឺតយ៉ាវ ដើម្បីឱបក្រសោបយកការផ្លាស់ប្តូរ

- ការគិតរបស់មហាជនស្រឡាញ់ស្ថានភាពដដែល ។
    - ✶ វាផ្តល់ជំនឿទៅលើគំនិតបច្ចុប្បន្ន ហើយរក្សាគំនិតនោះរហូតដល់ទីបញ្ចប់ ។
    - ✶ ជាលទ្ធផល វារាំងទប់ដល់ការផ្លាស់ប្តូរ ហើយគរកាការកែប្រែថ្មី (Innovation) ចោល ។
    - ✶ យើងត្រូវដកខ្លួនចេញពីគំនិតដែលថា របត់ពីអតីតកាល (Past routine) វិធីធ្វើការពីអតីតកាល នោះគឺជាវិធីដ៏ល្អបំផុតនោះ ។
- ផ្ទុយទៅវិញ យើងត្រូវអះអាងថាវាប្រហែលជាមានវិធីដ៏ល្អប្រសើរដែលអាចធ្វើអ្វីៗបានទាំងអស់ ។
    - ✶ ជាចាំបាច់យើងត្រូវបញ្ឈប់អះអាងថា អ្វីដែលយើងពុំធ្លាប់បានធ្វើពីមុននោះ សុទ្ធតែពុំអាចធ្វើបានទាំងអស់ ។

## ៤. ការគិតដោយមហាជននាំមកតែលទ្ធផលធម្មតា

- ជាមូលដ្ឋានគ្រឹះ ការគិតរបស់មហាជនតែងនាំមកនូវលទ្ធផលអន់ថយ ÷

  មហាជន = ធម្មតា = មធ្យម

    - ✶ នេះគឺលទ្ធផលអន់បំផុតនៃលទ្ធផលដ៏ល្អប្រសើរបំផុត (The least of the best) និងលទ្ធផលដ៏ប្រសើរបំផុតនៃលទ្ធផលអន់បំផុត (The best of the least)។
    - ✶ យើងកំរិតជោគជ័យរបស់យើង កាលណាយើងអនុម័តយកតាមការគិតរបស់មហាជន ។
    - ✶ យើងត្រូវទាត់ចោលនូវការគិតទូទៅ (Common thinking) ប្រសិនបើអ្នកចង់សម្រេចបាននូវលទ្ធផលល្អប្លែក (Uncommon results)។

# តើត្រូវលើកសំណួរសួរអំពីការយល់ព្រមទទួលយក នូវការគិតរបស់មហាជនយ៉ាងដូចម្តេច?

- ការគិតរបស់មហាជនជាភាគច្រើនបង្ហាញឱ្យឃើញថា ខុស និងមានកំហុស ។
- លើកសំណួរសួរអំពីគំនិតរបស់មហាជនពុំមែនជាការពិបាកនោះទេ ប្រសិនបើអ្នកបណ្តុះនូវទម្លាប់ធ្វើរឿងបែបនេះ ។ ការលំបាកស្ថិតនៅត្រង់ការចាប់ផ្តើម ។ សូមចាប់ផ្តើមធ្វើដូចតទៅ ÷

**១.គិតមុននឹងអ្នកដើរតាម**

- បុគ្គលជាច្រើនដើរតាមអ្នកដទៃស្ទើរតែជាស្វ័យប្រវត្តិ
  - ✶ ជួនកាលពួកគេដើរតាមបែបនេះ ពីព្រោះពួកគេចង់ដើរតាមគន្លងដែលមានការប្រឆាំងតិចបំផុត (Least resistance)។
  - ✶ ពេលខ្លះទៀត ពួកគេភ័យខ្លាចការទាត់ចោល (Rejection)។
  - ✶ ឬក៏ពួកគេជឿលើឧត្តមគតិដែលថាធ្វើអ្វីៗតាមអ្នកដទៃទៀតធ្វើ ។
  - ✶ ប៉ុន្តែប្រសិនបើអ្នកចង់បានទទួលជោគជ័យ អ្នកចាំបាច់ត្រូវគិតអំពីអ្វីដែលល្អប្រសើរពុំមែនអ្វីជារបស់មហាជនទូទៅទេ ។
- ប្រឈមនឹងការគិតរបស់មហាជន តម្រូវឱ្យមានឆន្ទៈក្លាយជាអ្នកមិនប្រជាប្រិយ ហើយដើរនៅក្រៅបទដ្ឋាន (ដែលមាន) ។
- នៅពេលដែលអ្នកចាប់គិតប្រឆាំងនឹងការមិនពិតនៃការគិតរបស់មហាជន (The grain of popular thinking) សូមចង់ចាំថា :
  - ✶ ការគិតរបៀបមិនប្រជាប្រិយ (Unpopular thinking) ទោះបីបានទទួលជោគ-ជ័យក្តី ជាទូទៅតែងតែត្រូវបានវាយតម្លៃទាប(Underrated) ពុំបានគេទទួលស្គាល់

(Unrecognized) ហើយអាចត្រូវយល់ច្រឡំ (Misunderstood) ។

✶ ការគិតរបៀបមិនប្រជាប្រិយផ្ទុកនូវគ្រាប់ពូជនៃចក្ខុវិស័យ និងឱកាស (The seeds of vision and opportunity)។

✶ ការគិតរបៀបមិនប្រជាប្រិយ ត្រូវការចាំបាច់សម្រាប់គ្រប់ការរីកចំរើន (Progress)។

- ពេលណាមួយដែលអ្នកមានអារម្មណ៍ស្រេចបាច់ថា សម្របខ្លួនទៅតាមការគិតរបស់មហាជន សូមឈប់ និងគិតសិន (Stop and think) ។

✶ អ្នកប្រហែលជាពុំចង់បង្កើតការផ្លាស់ប្តូរដើម្បីផលប្រយោជន៍ខ្លួនឯងឡើយ តែអ្នកប្រាកដជាពុំចង់ដើរតាមដោយងងឹតងងល់ ពីព្រោះតែអ្នកពុំគិតអំពីអ្វីដែលល្អប្រសើរបំផុតនោះ ។

## **២_ទាយតម្លៃដល់ការគិតដោយខុសប្លែកពីការគិតរបស់អ្នកផ្ទាល់**

- វិធីមួយដើម្បីឱបក្រសោបយកការកែប្រែថ្មី (Innovation) និងការផ្លាស់ប្តូរ (Change) គឺត្រូវរៀនវាយតម្លៃ តើអ្នកដទៃគិតយ៉ាងដូចម្តេច ។

✶ ដើម្បីធ្វើកិច្ចការនេះ អ្នកអាចដាក់ខ្លួនឯងជាបន្តបន្ទាប់នៅក្នុងចំណោមមនុស្សដែលខុសប្លែកពីអ្នកផ្ទាល់ ។

- នៅពេលដែលអ្នកត្រូវប្រឈមជាមួយនឹងការគិតរបស់មហាជន សូមចំណាយពេលវេលាជាមួយមនុស្សដែលខុសប្លែកខាងប្រវត្តិរូប (Backgrounds) កំរិតសិក្សា (Education levels) បទពិសោធន៍វិជ្ជាជីវៈ (Professional experiences) ផលប្រយោជន៍ផ្ទាល់ខ្លួន (Personal interests)..។ល។

✶ អ្នកនឹងគិតដូចមនុស្សទាំងឡាយដែលអ្នកចំណាយពេលវេលាច្រើនបំផុតជាមួយ ។

- ប្រសិនបើអ្នកចំណាយពេលវេលាជាមួយអ្នកដែលគិតក្រៅប្រអប់ (Out of box) អ្នកប្រហែលជាចង់ប្រឈមនឹងការគិតរបស់មហាជន ហើយបំបែកដែនដីថ្មី (Break new

ground)។

**៣-សូមលើកសំណួរជាបន្តបន្ទាប់អំពីការគិតរបស់ខ្លួនអ្នកផ្ទាល់**

- សូមធ្វើការប្រឈមចំពោះមុខ ÷ ពេលណាមួយដែលយើងរកឃើញរបៀបនៃការគិតដែលដំណើរការបាន ពេលនោះយើងតែងមានចំណង់បំផុត (Greatest temptations) ដើម្បីវិលមករករបៀបនៃការគិតនោះដាដដែល។ ទោះបីជារបៀបគិតនោះពុំអាចដំណើរការបានល្អតទៅទៀតក្តី ។
  - ✶ សត្រូវធំបំផុតនៃជោគជ័យថ្ងៃស្អែក ដួនកាលគឺជាជោគជ័យនៃថ្ងៃនេះ ។
- ដំណើរការប្រឈម (Challenging process)
  - ✶ តើវឌ្ឍនភាពទាំងឡាយត្រូវសម្រេចបានតាមរយៈការផ្លាស់ប្តូរជាមុនយ៉ាងដូចម្តេច។ សក្តានុពលពាក់ព័ន្ធ (The dynamics involved) ត្រូវលើកជាសំណួរចំពោះការគិតរបស់មហាជន ។
- នៅក្នុងស្ថាប័ននីមួយៗ ប្រពៃណីពីដំបូងគឺជាគំនិតដើមដ៏ល្អ អាចថាជាបដិវត្តបានថែមទៀត ។ ប៉ុន្តែប្រពៃណីនីមួយៗប្រហែលជាពុំមែនជាគំនិតល្អសម្រាប់អនាគតឡើយ ។
  - ✶ នៅក្នុងស្ថាប័នរបស់អ្នក ប្រសិនបើអ្នកបានពាក់ព័ន្ធនឹងការរៀបចំនូវអ្វីៗដែលកំពុងមានបច្ចុប្បន្ន ដូច្នេះប្រហែលជាអ្នកនឹងតទប់ចំពោះការផ្លាស់ប្តូរ ទោះបីការផ្លាស់ប្តូរនោះសម្រាប់ភាពគាប់ប្រសើរឡើងថែមទៀតក៏ដោយ ។ ដូច្នេះវាសំខាន់ណាស់ដើម្បីប្រឈមនឹងការគិតរបស់ខ្លួន ។ ប្រសិនបើអ្នកផ្សារភ្ជាប់នឹងការគិតរបស់ខ្លួនឯងច្រើនពេក ហើយផ្សារភ្ជាប់ទៅនឹងតើអ្វីៗកំពុងមានយ៉ាងដូចម្តេចឥឡូវនេះ ដូច្នេះនឹងពុំមានអ្វីផ្លាស់ប្តូរដើម្បីភាពកាន់តែគាប់ប្រសើរឡើងឡើយ ។

**៤-សាកល្បងរឿងថ្មីតាមរបៀបថ្មី (Try New Things In New Ways)**

- តើក្នុងពេលចុងក្រោយនេះអ្នកបានធ្វើអ្វីមួយជាលើកដំបូង? តើអ្នកបានជៀសវាងហានិភ័យ ឬសាកល្បងរឿងថ្មីយ៉ាងដូចម្តេច?
  - ✶ វិធីដ៏ល្អប្រសើរដើម្បីចេញផុតពីទម្លាប់ចាស់ (To get out of the rut) នៃការ

គិតរបស់អ្នកផ្ទាល់ គឺត្រូវកែប្រែថ្មី (Innovation)។

✶ អ្នកអាចធ្វើបន្តិចម្តងៗតាមវិធីរៀងរាល់ថ្ងៃ : ខិតខំធ្វើការងារតាមរបៀបប្លែកពីរបៀបធម្មតា ។

✶ បញ្ជាម្ហូបប្លែក (Unfamiliar dish) នៅភោជនីយដ្ឋានដែលអ្នកចូលចិត្ត ។

✶ សាកសួរសហសេវិកផ្សេងដើម្បីជួយអ្នកក្នុងគម្រោងណាមួយរបស់គ្រួសារ ។

✶ ដកខ្លួនអ្នកចេញពីអ្នកបើកបរយានយន្ត ដែលជិះតែតាមផ្លូវដដែល ។

- ការគិតមិនប្រជាប្រិយលើកសំណួរ និងស្វែងរកជម្រើសផ្សេងៗ ។

✶ មនុស្សច្រើនណាស់ពុំដែលសាកល្បងរឿងថ្មីតាមរបៀបថ្មី (New things in new ways)។

✶ ជាការពិត មនុស្សជាច្រើនច្រើនតែពេញចិត្តជាមួយបញ្ហាចាស់ជាជាងស្វែងរកដំណោះស្រាយថ្មីៗ ។

- តើអ្នកនឹងធ្វើរឿងថ្មីតាមរបៀបថ្មី ថាមិនសំខាន់ដូចអ្នកកំពុងធ្វើវាដោយប្រាកដប្រជាយ៉ាងដូចម្តេច ?

✶ ប្រសិនបើអ្នកធ្វើរឿងថ្មីតាមរបៀបដដែលដែលអ្នកដទៃកំពុងធ្វើ តើពិតប្រាកដដែរឬទេដែលថា អ្នកដើរទៅមុខប្រចាំងនឹងការគិតរបស់មហាជន ?

- សូមចាកចេញពីគន្លងនេះ ហើយអ្នកធ្វើអ្វីប្លែកថ្ងៃនេះ ។

## <u>៥-សូមទម្លាប់ដើម្បីមិនសុខស្រួល (Get Used to Being Uncomfortable)</u>

- ជាធម្មតា ការធ្វើតាមការគិតរបស់មហាជនគឺវាសុខស្រួល (Comfortable)។

✶ ប្រសិនបើអ្នកចង់ទាត់ចោលនូវការគិតរបស់មហាជនដើម្បីឱបក្រសោបយកនូវសមិទ្ធផល អ្នកត្រូវតែទម្លាប់ទទួលយកនូវភាពមិនសុខស្រួល ។

- ប្រសិនបើអ្នកឱបក្រសោបយកការគិតមិនប្រជាប្រិយ ហើយធ្វើសេចក្តីសម្រេចចិត្តទៅតាមអ្វីដែលវាអាចទៅរួចដោយល្អប្រសើរ ហើយអ្វីដែលត្រឹមត្រូវជាជាងអ្វីដែលជាទូទៅគេ

ទទួលយកហើយនោះ សូមដឹងរឿងនេះ ÷ នៅក្នុងឆ្នាំដំបូងរបស់អ្នក អ្នកពុំមែនជាអ្នកខុសដូចមហាជនគិតថាអ្នកខុសនោះទេ ។ នៅឆ្នាំបន្ទាប់មកទៀត អ្នកពុំមែនជាអ្នកត្រូវដូចមហាជនគិតថាអ្នកត្រូវនោះទេ ។ គិតគ្រប់ឆ្នាំទៅ អ្នកនឹងក្លាយជាអ្នកល្អប្រសើរជាងអ្វីដែលអ្នកបានគិតថាបានល្អប្រសើរនោះ ។

×

× ×

# ជំពូកទី៩
# ទទួលផលប្រយោជន៍ពីការគិតដោយចែករំលែក
# BENEFIT FROM SHARED THINKING

- លោក Ken Blanchard និយាយថា : "គ្មាននរណាម្នាក់ក្នុងចំណោមយើងដែលឈ្លាសវៃដូចយើងទាំងអស់គ្នាឡើយ None of us is as smart as all of us" ។
- អ្នកគិតដ៏ពូកែ ជាពិសេសអ្នកដែលជាអ្នកដឹកនាំដ៏ពូកែ តែងយល់ដឹងអំពីអំណាចនៃការគិតដោយចែករំលែក (ការគិតរួមគ្នា) ។
  - ✶ ពួកគេដឹងថា កាលណាពួកគេឱ្យតម្លៃទៅលើគំនិត និងយោបល់របស់អ្នកដទៃ ពួកគេទទួលបាននូវលទ្ធផលផ្សំគ្នានៃការគិតដោយចែករំលែក ហើយសម្រេចបានច្រើនអ្វីដែលពួកគេអាចធ្វើដោយខ្លួនពួកគេផ្ទាល់ ។

## ១. ការគិតដោយចែករំលែកលឿនជាងការគិតតែម្នាក់ឯង

- យើងរស់នៅក្នុងពិភពលោកដែលពិតប្រាកដមានសន្ទុះល្បឿនលឿន (A truly fast-paced world) ។ ដើម្បីធ្វើការងារតាមកិរិតនៃល្បឿនបច្ចុប្បន្ន យើងពុំអាចដើរទៅមុខតែឯងបានឡើយ ។
  - ✶ យុវជន និងយុវនារីជំនាន់នេះដែលទើបតែចូលធ្វើការងារ ទទួលបានអារម្មណ៍អំពីរឿងនេះច្បាស់លាស់ណាស់ ។
  - ✶ អញ្ចឹងហើយបានជាពួកគេឱ្យតម្លៃខ្ពស់ទៅលើសហគមន៍ ហើយខិតខំធ្វើការនៅក្រុមហ៊ុនណាមួយដែលគេចូលចិត្ត ជាជាងក្រុមហ៊ុនមួយទៀតដែលផ្តល់ប្រាក់បៀវត្សឱ្យពួកគេបានច្រើន ។
- ធ្វើការជាមួយអ្នកដទៃ គឺផ្តល់ឱ្យអ្នកនូវផ្លូវកាត់ (A shortcut) ។

- ប្រសិនបើអ្នកចង់រៀនជំនាញថ្មីយ៉ាងឆាប់រហ័សតើអ្នកនឹងធ្វើយ៉ាងដូចម្តេច ? តើអ្នកខិតខំដោយខ្លួនឯង និងរកវាឱ្យបាន ឬក៏អ្នករកអ្នកដទៃឱ្យបង្ហាញអ្នកថាដូចម្តេចនោះ ?
- អ្នកអាចរៀនបានឆាប់រហ័សជាងពីនរណាម្នាក់ដែលមានបទពិសោធន៍ ។
  - ✶ មិនថាអ្នកសាកល្បងរៀន Software Package ថ្មី, រៀនវាយGolf ឬរៀនធ្វើម្ហូបក្តី ។

## ២_ការគិតដោយចែករំលែកគឺមានលក្ខណៈកែប្រែថ្មី (More Innovative) ច្រើនជាងការគិតតែម្នាក់ឯង

- យើងតែងគិតថាអ្នកពូកែគិត និងអ្នកកែប្រែថ្មី(Innovators) គឺជនឯកោ(Soloists) ប៉ុន្តែតាមការពិត ការគិតកែប្រែថ្មីដ៏ធំ (The greatest innovative thinking) ពុំមែនកើតឡើងនៅក្នុងលំហទទេនោះឡើយ (In a vacuum) ។ ការកែប្រែថ្មី គឺជាលទ្ធផលនៃការសហការ (Collaboration) ។
  - ✶ លោក Albert Einstein កត់សម្គាល់ថា : "ជាច្រើនដងក្នុងមួយថ្ងៃ ខ្ញុំតែងយល់ថាជីវិតនៃអារម្មណ៍ខាងក្នុងនិងខាងក្រៅរបស់ខ្ញុំ គឺត្រូវបានកសាងឡើងតាមការងាររបស់មនុស្សផ្សេងទៀត ខ្លះនៅរស់ ខ្លះបានធ្វើមរណកាលទៅហើយ ។ ខ្ញុំត្រូវខិតខំខ្លួនឯងលើគំនរនៃភោគផលពីមុនដើម្បីឱ្យបានផលច្រើន ដូចជាភោគ-ផលដែលខ្ញុំបានទទួល" ។
- ការគិតដោយចែករំលែកនាំឱ្យមានការកែប្រែថ្មីខ្ពស់ (Innovation) មិនថាការងារស្រាវ-ជ្រាវ ការនិពន្ធ ការតែងចម្រៀង....។
  - ✶ ប្រសិនបើអ្នកគួបផ្សំគំនិតរបស់អ្នកជាមួយនឹងគំនិតរបស់អ្នកដទៃ នោះអ្នកនឹងទទួលបានគំនិតថ្មីដែលអ្នកពុំធ្លាប់មាន ។

## ៣_ការគិតដោយចែករំលែកនាំមកនូវភាពចាស់ទុំ (Maturity) ជាងការគិតតែម្នាក់ឯង

- យើងទាំងអស់គ្នាតែងគិតថាយើងដឹងអ្វីៗទាំងអស់រួចហើយ ដូច្នេះយើងម្នាក់ៗប្រហែលជាពុំ

បានដឹងអំពីចំណុចងងឹត (Blind spots) និងវិស័យនៃការគ្មានបទពិសោធន៍ (Areas of inexperience) របស់ខ្លួនឡើយ ។

- ប្រសិនបើអ្នកគ្មានបទពិសោធន៍ដែលអ្នកត្រូវការ សូមទាក់ទងពិគ្រោះ និងរៀនសូត្រពីនរណាម្នាក់ដែលមានបទពិសោធន៍ ។

## ៤. ការគិតដោយចែករំលែកខ្លាំងជាងការគិតតែម្នាក់ឯង

- លោក Goathe និយាយថា : "ដោយទទួលបាននូវការណែនាំដ៏ល្អ នោះគឺដើម្បីបង្កើនសមត្ថភាពផ្ទាល់ខ្លួន" ។
- ក្បាលពីរប្រសើរជាងក្បាលមួយ កាលណាក្បាលទាំងពីរនោះគិតទៅក្នុងទិសតែមួយ ដូចជាសេះពីរអូសរទេះតែមួយអញ្ចឹងដែរ ។ សេះទាំងពីរអូសរទេះបានខ្លាំងជាងសេះតែមួយ ។
  - ✶ ប៉ុន្តែតើអ្នកដឹងទេ កាលណាសេះទាំងពីរទាញរទេះដោយរួមគ្នា វាអាចទាញរទេះមានទម្ងន់ច្រើនជាងទម្ងន់ដែលទាញបានដោយសេះនីមួយៗ ?
  - ✶ វាកម្លាំងពិសេសបន្ថែម (Synergy) ដែលចេញមកពីការធ្វើការរួមគ្នា ។
  - ✶ ប្រហែលនៃថាមពលប្រភេទនេះដើរតួផងដែរ កាលណាមនុស្សរួមគ្នាគិត ។

## ៥. ការគិតដោយចែករំលែកផ្តល់ត្រឡប់មកវិញនូវតម្លៃធំជាងការគិតតែឯង

- ពីព្រោះការគិតដោយចែករំលែកខ្លាំងជាងការគិតតែឯង នោះវាពិតជាផ្តល់ផលត្រឡប់មកវិញជាង (A higher return) ។
  - ✶ ផលប្រយោជន៍ផ្ទាល់ខ្លួន និងបទពិសោធន៍បានទទួលបានធំជាងការគិតតែឯង ។
  - ✶ បញ្ហាដែលអ្នកនឹងមាន មិនថាក្នុងគ្រួសារ ក្នុងកន្លែងធ្វើការ ក្នុងប្រទេស និងក្នុងពិភពលោក ជាសារវ័ន្តគឺជាបញ្ហានៃទំនាក់ទំនង និងការពឹងពាក់គ្នាទៅវិញទៅមក (A matter of relationships and of interdependence) ។

## ៦. ការគិតដោយចែករំលែកគឺជាវិធីតែមួយគត់ដើម្បីទទួលបានការគិតដ៏ល្អប្រសើរ (Great Thinking)

- គំនិតដ៏ល្អប្រសើរណាមួយចាប់ផ្តើមតាមរយៈគំនិតល្អបី ឬបួន (Three or four good ideas) ។

✶ គំនិតល្អស្ទើរតែភាគច្រើនបំផុតចេញមកពីការគិតដោយចែករំលែក ។

✶ អ្នកដែលបង្រៀនតែខ្លួនឯងសុទ្ធសាធគឺជាគ្រូដ៏ចំកួតម្នាក់ (A fool of master) ។

✶ ចម្លើយទាំងឡាយនឹងល្អប្រសើរ កាលណាចម្លើយទាំងនោះត្រូវបានប្រើប្រាស់ដោយល្អនូវការគិតរបស់ម្នាក់ៗនៃតួអង្គចូលរួមទាំងអស់ ។

✶ កាលណាអ្នកមានគំនិតមួយ ហើយរួមគ្នាមានគំនិតពីរនោះ ដូច្នេះយើងតែងមាននូវសក្តានុពលដើម្បីមានគំនិតដ៏ល្អប្រសើរ ។

## តើត្រូវលើកទឹកចិត្តដល់ការចូលរួមនៃការគិតដោយចែករំលែកយ៉ាងដូចម្តេច?

- មនុស្សមួយចំនួនជាចរិតធម្មជាតិ តែងចូលរួមនៅក្នុងការគិតដោយចែករំលែក ។

✶ កាលណាពួកគេមើលឃើញបញ្ហាណាមួយ ពួកគេតែងគិតថា តើខ្ញុំដឹងថានរណាអាចជួយខ្ញុំពីរឿងនេះ ?

✶ អ្នកដឹកនាំតែងមាននិន្នាការរបៀបនេះ ថែមទាំងពួកអ្នកបើកចំហ ។

- ប៉ុន្តែតាមរបៀបនេះក្តី អ្នកនៅតែពុំទាន់ជាអ្នកទទួលផលប្រយោជន៍ពីការគិតដោយចែករំលែកនៅឡើយទេ ។

- សូមប្រើនូវជំហានដូចខាងក្រោមដើម្បីជួយអ្នកបង្កើននូវសមត្ថភាពរបស់អ្នកឱ្យទទួលបានផលពីការគិតដោយចែករំលែក :

### ១-ផ្តល់តម្លៃដល់ការគិតរបស់អ្នកដទៃ

- ជំហានទី១ សូមជឿជាក់ថាគំនិតរបស់អ្នកដទៃមានតម្លៃ

✶ ប្រសិនបើអ្នកពុំជឿជាក់ទេនោះ ដៃរបស់អ្នកនឹងត្រូវចង

✶ តើអ្នកដឹងថាអ្នកពិតជាចង់បានគំនិតបន្ថែម (Input) ពីអ្នកដទៃយ៉ាងដូចម្តេច ?

សូមសាកសួរសំណួរដូចតទៅនេះ :

**+** <u>តើខាងផ្លូវអារម្មណ៍ខ្ញុំមានសន្តិសុខដែរឬទេ ?</u>

អ្នកដែលខ្វះជំនឿ និងព្រួយបារម្ភអំពីលក្ខន្តិកៈ មុខតំណែង ឬអំណាច ចង់តែទាត់ចោលនូវគំនិតរបស់អ្នកដទៃ ការពារជំហរខ្លួនឯង ហើយរក្សាមហាជនឲ្យនៅឆ្ងាយពីខ្លួន ។

មានតែមនុស្សដែលមានសន្តិសុខប៉ុណ្ណោះ ដែលយកចិត្តទុកដាក់ចំពោះគំនិតរបស់អ្នកដទៃ ។

**+** <u>តើខ្ញុំផ្តល់តម្លៃដល់មហាជនដែរឬទេ ?</u>

អ្នកពុំផ្តល់តម្លៃដល់គំនិតរបស់មនុស្សណាម្នាក់ឡើយ ប្រសិនបើអ្នកពុំចង់ផ្តល់តម្លៃ ឬគោរពដល់ជននោះ ។ តើអ្នកធ្លាប់បានយកចិត្តទុកដាក់អំពីសីលធម៌របស់អ្នក (Conduct) ចំពោះជនដែលអ្នកផ្តល់តម្លៃ ឬក៏ពុំផ្តល់តម្លៃដែរឬទេ ? សូមពិនិត្យមើលភាពខុសគ្នា :

| <u>ប្រសិនបើខ្ញុំផ្តល់តម្លៃដល់មនុស្ស</u> | <u>ប្រសិនបើខ្ញុំពុំផ្តល់តម្លៃដល់មនុស្ស</u> |
|---|---|
| - ខ្ញុំចង់ចំណាយពេលវេលាជាមួយមនុស្សទាំងនោះ | - ខ្ញុំពុំចង់នៅជិតពួកជនទាំងនោះ |
| - ខ្ញុំស្តាប់ពួកគេ | - ខ្ញុំពុំយកចិត្តទុកដាក់ស្តាប់ឡើយ |
| - ខ្ញុំចង់ជួយពួកគេ | - ខ្ញុំពុំផ្តល់ការជួយដល់ពួកគេឡើយ |
| - ខ្ញុំបានទទួលឥទ្ធិពលពីពួកគេ | - ខ្ញុំពុំទទួលស្គាល់ឥទ្ធិពលរបស់ពួកគេ |
| - ខ្ញុំគោរពពួកគេ | - ខ្ញុំមិនខ្វល់ទេ (Indifferent) |

**+** <u>**តើខ្ញុំផ្តល់តម្លៃដល់ដំណើរការទាក់ទងគ្នាដោយសកម្មដែរឬទេ (The interactive process)**</u>

កម្លាំងបន្ថែមពិសេស (A wonderful synergy) តែងកើតឡើងជាលទ្ធផលនៃការគិតដោយចែករំលែក ។ វាអាចនាំអ្នកទៅដល់កន្លែងដែលអ្នកពុំធ្លាប់ទៅដល់ ។ អ្នកត្រូវបើកទូលាយខ្លួនឯងឡើងដើម្បីទទួលយកគំនិតនៃការគិតដោយចែករំលែក មុននឹងអ្នកចូលទៅក្នុងដំណើរការនៃការគិតដោយចែករំលែក ។

## ២-ដកថយចេញពីការប្រកួតប្រជែង (Competition) ទៅកាន់សហប្រតិបត្តិការ (Cooperation)

- ជានិច្ចកាល សូមតាំងចិត្តស្វែងរកគំនិត ។ សូមកុំរើសអើងប្រភព ។ សូមទទួលយកគំនិតពីអតិថិជន កុមារ អ្នកប្រកួតប្រជែង ខាងវិស័យឧស្សាហកម្ម ឬក៏ពួកអ្នកបើកបររថយន្តតាក់ស៊ី ។ មិនសំខាន់ថាអ្នកណាមានគំនិតនោះឡើយ ។
- ជនម្នាក់ដែលឱ្យតម្លៃទៅលើសហប្រតិបត្តិការ តែងមានបំណងដើម្បីប្រកួតប្រជែងខាងគំនិតជាមួយអ្នកដទៃ ប៉ុន្តែពុំមែនប្រកួតប្រជែងជាមួយពួកគេទេ ។
    - ✶ ប្រសិនបើមាននរណាម្នាក់ស្នើសុំអ្នកឱ្យចែករំលែកគំនិត សូមយកចិត្តទុកដាក់លើក្រុម សូមកុំយកចិត្តទុកដាក់លើអ្វីដែលជាផ្ទាល់ខ្លួន ។
    - ✶ ប្រសិនបើអ្នកគឺជាអ្នកប្រមូលមនុស្សឱ្យជុំគ្នាដើម្បីចែករំលែកការគិត សូមលើកសរសើរដល់គំនិតច្រើនជាងប្រភពនៃគំនិត ។
    - ✶ ប្រសិនបើគំនិតល្អបំផុតតែងតែមានជោគជ័យជានិច្ចនោះ (ជាជាងមនុស្សដែលផ្តល់គំនិតនោះ) ពួកគេទាំងអស់នឹងចែករំលែកគំនិតរបស់ពួកគេដោយក្តីសប្បាយរីករាយបំផុត ។

## ៣-សូមមានរបៀបវារៈមួយកាលណាអ្នកជួប

- នៅក្នុងទំនាក់ទំនងវាតែងមានការផ្តល់ និងការទទួល (The give and take) ÷
    - ✶ មិនថាត្រូវជួបអ្នកណា អ្នកត្រូវមានមូលហេតុដើម្បីជួបគ្នា និងមានការរំពឹងទុកថា តើអ្វីត្រូវផ្តល់ និងអ្វីខ្លះត្រូវទទួលពីការជួបនេះ ។
    - ✶ នេះជាការពិត មិនថាក្នុងការងារ ធុរកិច្ច ឬការកំសាន្ត (Pleasure) ។

## ៤-ស្វែងរកមនុស្សត្រឹមត្រូវនៅជុំវិញ

- ដើម្បីទទួលបាននូវអ្វីដែលមានតម្លៃចេញពីការគិតដោយចែករំលែក អ្នកត្រូវការមានជុំវិញខ្លួននូវមនុស្សដែលនាំអ្វីខ្លះៗមកកាន់តុ ។
    - ✶ នៅពេលអ្នកស្នើសុំមនុស្សឱ្យចូលរួមនៅក្នុងការគិតដោយចែករំលែក អ្នកត្រូវប្រើ

ប្រាស់នូវលក្ខណៈវិនិច្ឆ័យ(Criteria) ដើម្បីដំណើរការជ្រើសរើស(Selection) ÷

+ ជ្រើសរើសយកមនុស្សដែលមានបំណងខ្លាំងក្លា គឺជាជោគជ័យនៃគំនិត
+ ជ្រើសរើសយកមនុស្សដែលអាចបង្កើនតម្លៃចំពោះគំនិតដទៃទៀត
+ ជ្រើសរើសយកមនុស្សដែលមានអារម្មណ៍អាចដោះស្រាយការផ្លាស់ប្តូរយ៉ាងចាប់រហ័សនៅក្នុងការសន្ទនា
+ ជ្រើសរើសយកមនុស្សដែលផ្តល់តម្លៃដល់កម្លាំងរបស់អ្នកដទៃ នៅក្នុងវិស័យដែលពួកគេទន់ខ្សោយ
+ ជ្រើសរើសយកមនុស្សដែលយល់ដឹងអំពីទីកន្លែងនៃតម្លៃនៅក្នុងគុ
+ ជ្រើសរើសយកមនុស្សដែលផ្តល់នូវអ្វីដែលល្អប្រសើរបំផុតសម្រាប់ក្រុម មុននឹងអ្វីសម្រាប់ពួកគេផ្ទាល់
+ ជ្រើសរើសយកមនុស្សដែលអាចនាំឱ្យបញ្ចេញការគិតដ៏ល្អប្រសើរពីមនុស្សនៅជុំវិញពួកគេ
+ ជ្រើសរើសយកមនុស្សដែលមានភាពចាស់ទុំខាងបទពិសោធន៍ និងជោគជ័យនៅលើបញ្ហាដែលកំពុងពិភាក្សា
+ ជ្រើសរើសយកមនុស្សដែលនឹងមានភាពម្ចាស់ការ (Ownership) និងការទទួលខុសត្រូវដើម្បីសម្រេចចិត្ត
+ ជ្រើសរើសយកមនុស្សដែលចាកចេញពីតុប្រជុំដោយជំហរ ឥរិយាបថ "យើង" ពុំមែនជំហរ "ខ្ញុំ" ឡើយ ។

- ជាទូទៅ យើងជ្រើសរើសដៃគូពិភាក្សា (Brainstorming partners) លើមូលដ្ឋាននៃអារម្មណ៍មិត្តភាព ឬកាលៈទេសៈ ឬភាពសមស្រប ។

✶ ប៉ុន្តែធ្វើបែបនេះពុំបានជួយយើងឱ្យរកឃើញ និងបង្កើតនូវគំនិតដែលមានកំរិតខ្ពស់បានឡើយ ។ តើនរណាត្រូវអញ្ជើញឱ្យចូលតុប្រជុំ បង្កើតឡើងនូវភាពខុសប្លែក ។

## ៥_ខួនាត់ឱ្យបានល្អរវាងអ្នកគិតដ៏ពូកែ និងសហការី

- ស្ថាប័នដែលជោគជ័យអនុវត្តនូវការគិតដោយចែករំលែក ។

\+ ប្រសិនបើអ្នកដឹកនាំស្ថាប័ន នាយកដ្ឋាន ឬក្រុមណាមួយនោះ នោះអ្នកមិនអាចខកខានពុំមានសហការីដែលពូកែនៅក្នុងការគិតដោយចែករំលែកបានឡើយ ។

\+ នៅពេលដែលអ្នកជ្រើសរើស និងបញ្ចូលឱ្យធ្វើការ សូមខិតខំស្វែងរកអ្នកដែលពូកែគិតដែលបេះឱ្យតម្លៃទៅអ្នកដទៃ មានបទពិសោធន៍ជាមួយនឹងដំណើរការសហការគ្នា (The collaborative process) ហើយមានអារម្មណ៍សន្តិសុខ (Emotionally secure) ។ សូមផ្ដល់ឱ្យបៀវត្សរ៍ល្អ និងប្រឈមជាមួយពួកគេដើម្បីប្រើប្រាស់គំនិតរបស់ពួកគេ ហើយប្រើប្រាស់ការគិតដោយចែករំលែករបស់ពួកគេ ។ គ្មានអ្វីបង្កើតតម្លៃបន្ថែមដូចអ្នកគិតដ៏ពូកែដែលផ្ដុំគំនិតរួមគ្នាឡើយ ។

- មិនថាអ្វីដែលអ្នកកំពុងសម្រេចឡើយ អ្នកអាចធ្វើវាបានល្អតាមរយៈការគិតដោយចែករំលែក ។ ការដឹកនាំល្អជួយឱ្យមនុស្សល្អរួមគ្នា ដោយមានមនុស្សត្រឹមត្រូវ ចំពេលវេលាត្រឹមត្រូវ ដើម្បីបុព្វហេតុត្រឹមត្រូវ កម្ដៅធ្វើឱ្យម្នាក់ៗក្លាយជាអ្នកឈ្នះ ។ អ្វីដែលសំខាន់នោះ គឺមនុស្សត្រឹមត្រូវ និងបំណងប្រាថ្នាដើម្បីចូលរួមក្នុងការគិតដោយចែករំលែក ។

×

× ×

# ជំពូកទី១០

# អនុវត្តនូវការគិតដោយមិនអាត្មានិយម

# PRACTICE UNSELFISH THINKING

- យើងពុំអាចកាន់ចន្លុះបំភ្លឺផ្លូវអ្នកដទៃ ដោយពុំបានបំភ្លឺផ្លូវខ្លួនឯងឡើយ (Ben Sweetland)។
- របៀបនៃការគិតជាច្រើនប្រភេទអាចជួយអ្នកឱ្យសម្រេចបានលទ្ធផលច្រើន ។
  - ✶ ប្រភេទនីមួយៗមានសក្តានុពលធ្វើឱ្យអ្នកកាន់តែទទួលជោគជ័យ ។
  - ✶ ការគិតដោយមិនអាត្មានិយម នាំមកនូវសក្តានុពលដើម្បីកែប្រែជីវិតអ្នកទៅតាមរបៀបម្យ៉ាងទៀត ។ វាអាចជួយឱ្យអ្នកកំណត់បានជាថ្មី ថាតើអ្នកមើលឃើញជោគជ័យថាដូចម្តេច ។
  - ✶ ការគិតដោយមិនអាត្មានិយមអាចផ្តល់លទ្ធផលឱ្យអ្នកច្រើនជាងការគិតប្រភេទផ្សេងទៀត ព្រោះមានផលប្រយោជន៍ដូចតទៅ ÷

## ១-ការគិតដោយមិនអាត្មានិយមនាំឱ្យសម្រេចការបំពេញចិត្តផ្ទាល់ខ្លួន

- មានរឿងតិចតួចប៉ុណ្ណោះក្នុងជីវិតដែលអាចផ្តល់រង្វាន់ធំជាងការជួយអ្នកដទៃ ។
  - ✶ អ្នកទទួល (Getter) ជាទូទៅពុំបានទទួលសុភមង្គលទេ, អ្នកផ្តល់ (Giver) ទទួលបានសុភមង្គល (Charles H. Burr) ។
- ជួយមនុស្សនាំឱ្យមានការពេញចិត្តដ៏ខ្ពស់ (Great satisfaction) ។
  - ✶ កាលណាអ្នកចំណាយថ្ងៃរបស់អ្នកដោយមិនអាត្មានិយមដើម្បីបំរើអ្នកដទៃនោះពេលយប់អ្នកអាចដាក់ខ្លួនដេកដោយគ្មានវិប្បដិសារី ហើយដេកលក់ដោយស្កប់ស្កល់ ។
  - ✶ គ្មានមុខរបរណានៅក្នុងពិភពលោកដែលថ្លៃថ្នូរជាងការជួយមនុស្សដទៃទៀតឡើយ

គឺជួយអ្នកដទៃឲ្យជោគជ័យ (Alan Loy Mc Ginnis)។

✶ ទោះបីអ្នកចំណាយពេលវេលាច្រើននៃជីវិតរបស់អ្នកដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនក្តី វាពុំមានអ្វីត្រូវយឺតពេលពេកឡើយដើម្បីធ្វើឲ្យបេះដូងមានការកែប្រែ ។

✶ ដូចលោក Alfred Nobel ដែលជាអ្នកផ្តើមរកឃើញនូវអាវុធបរមាណូដើម្បីបំផ្លាញអាយុជីវិតរបស់មនុស្ស ក៏អាចងាកមករួមចំណែកដើម្បីសន្តិភាព និងធ្វើវិភាគទានដល់មនុស្សជាតិ : ពានរង្វាន់ណូបែល ។

## ២_ការគិតដោយមិនអាត្មានិយមផ្តល់តម្លៃដល់អ្នកដទៃ

- កាលណាអ្នកចេញទៅខាងក្រៅខ្លួនឯងហើយ រួមវិភាគទានដល់អ្នកដទៃ នោះហើយទើបអ្នកចាប់ផ្តើមរស់នៅពិតប្រាកដ ។
- លោក Bessie Anderson បានសរសេរក្នុងឆ្នាំ១៩០៤ អំពីអត្ថន័យនៃពាក្យថាជោគជ័យដូចតទៅ ÷

✶ អ្នកសម្រេចបានជោគជ័យ គឺអ្នករស់នៅបានល្អ សើចញឹកញាប់ ។

✶ គឺជាជនដែលមានក្តីសប្បាយរីករាយ ដោយទទួលបានជំនឿទុកចិត្តពីនារីបរិសុទ្ធម្នាក់ ទទួលបានការគោរពក្នុងឋានៈជាមនុស្សមានប្រាជ្ញា ហើយទទួលបានក្តីស្រឡាញ់ពីកូនចៅតូចៗ ។

✶ គឺជាជនដែលបានបំពេញគ្រប់សព្វនូវមុខការ និងសម្រេចបាននូវភារកិច្ចរបស់ខ្លួន ។

✶ គឺជាជនដែលចាកចេញពីពិភពលោកដោយល្អប្រសើរជាងពេលដែលខ្លួនបានឃើញពិភពលោក ទោះបីជាបានធ្វើឲ្យចំការអាកៀនល្អប្រសើរជាងមុន កំណាព្យដ៏ល្អឥតខ្ចោះ ឬក៏សង្គ្រោះព្រលឹងក្តី ...។

✶ គឺជាជនដែលពុំដែលខ្វះការផ្តល់តម្លៃដល់សម្រស់របស់ផែនដី ឬក៏ជាជនដែលមិនបានសម្តែងបែបនេះ ។

✶ គឺជាជនដែលជានិច្ចកាលខិតខំស្វែងរកអ្វីដែលគាប់ប្រសើរបំផុតនៅក្នុងខ្លួនអ្នក

ដទៃ ហើយផ្ដល់ដល់អ្នកដទៃនូវអ្វីដែលខ្លួនឯងមានដែលអ្វីជាគាប់ប្រសើរបំផុត នោះ ។

✶ គឺជាជនដែលជីវិតខ្លួនគឺជាគំរូរៀនសូត្រមួយ (An inspiration) ។

✶ គឺជាជនដែលមានអនុស្សាវរីយ៍ គឺជាការប្រសិទ្ធពរ (A benediction) ។

## ៣_ការគិតដោយមិនអាត្មានិយមលើកទឹកចិត្តដល់គុណធម៌ដទៃទៀត

- កាលណាអ្នកឃើញក្មេងអាយុ៤ឆ្នាំ អ្នកពាំងទុកមើលឃើញភាពអាត្មានិយម (Selfishness) ។ ប៉ុន្តែកាលណាអ្នកមើលវាក្នុងអាយុ ៤០ឆ្នាំ វាពុំមែនគួរឲ្យចាប់អារម្មណ៍, មិនថាអញ្ចឹង ?
- អំពីគុណសម្បត្តិទាំងអស់ដែលមនុស្សអាចមាន ការគិតដោយមិនអាត្មានិយមហាក់ដូចជាធ្វើឲ្យមានភាពខុសគ្នាយ៉ាងសម្បើមបំផុតក្នុងដំណើរគ្រោះទៅបណ្ដុះនូវគុណធម៌ផ្សេងទៀត :

✶ ពីព្រោះសមត្ថភាពផ្ដល់ដោយមិនអាត្មានិយមគឺពិបាកណាស់ វាដើរប្រឆាំងទៅនឹងចរិតរបស់មនុស្ស ។

✶ ប៉ុន្តែអ្នកអាចរៀនគិតដោយមិនអាត្មានិយម ហើយក្លាយទៅជាអ្នកផ្ដល់ ដូច្នេះវាងាយស្រួលដើម្បីពង្រីកគុណធម៌ជាច្រើនទៀត : ការដឹងគុណ សេចក្ដីស្រឡាញ់ ការគោរព ភាពអំណត់ វិន័យ.....។ល។

## ៤_ការគិតដោយមិនអាត្មានិយមបង្កើនគុណភាពនៃជីវិត

- ស្មារតីនៃសប្បុរសធម៌ (Spirit of Generosity) បង្កើតឡើងដោយការគិតមិនអាត្មានិយមផ្ដល់ដល់មនុស្សនូវការវាយតម្លៃអំពីជីវិត និងការយល់ដឹងអំពីតម្លៃខ្ពស់ជាង ។

✶ មើលឃើញមនុស្សដែលកំពុងត្រូវការ ហើយផ្ដល់ឲ្យដើម្បីបំពេញសេចក្ដីត្រូវការ និងដាក់ភ្លើងជាច្រើននៅក្នុងទស្សនវិស័យ ។ វាបង្កើននូវគុណភាពនៃជីវិតរបស់អ្នកផ្ដល់ និងអ្នកទទួល ។

✶ ប្រសិនបើអ្នកចង់ឲ្យពិភពលោករបស់អ្នកល្អប្រសើរ សូមយកចិត្តទុកដាក់ជួយអ្នក

ដទៃ ។

**៥_ការគិតដោយមិនអាត្មានិយមធ្វើឱ្យផ្នែកអ្វីមួយរបស់អ្នកធំជាងខ្លួនអ្នក**

- យើងខិតខំដោយមិនបំភ្លេចថា ឱសថគឺសម្រាប់មនុស្ស ។ ឱសថមិនមែនសម្រាប់ការចំណេញទេ ។ ការចំណេញនឹងមកតាមក្រោយ ហើយប្រសិនបើយើងចងចាំពីរឿងនេះ ការចំណេញប្រាកដជាមិនខកខាននឹងកើតឡើង ។
  - ✶ នេះគឺជាមេរៀនមួយ ÷ ជាជាងខិតខំឲ្យបានល្បីល្បាញ សូមតាំងខ្លួនជាផ្នែកអ្វីមួយដែលធំជាងខ្លួនអ្នក ។

**៦_ការគិតដោយមិនអាត្មានិយមបន្ថែននូវកេរ្តិ៍ដំណែលជាមរតក (Logacy)**

- "រៀន, ទទួលផល, ត្រឡប់វិញ" គឺជាដំណាក់កាលទាំង៣ នៃជីវិត ÷
  - ✶ ១ភាគ៣ ដំបូងនៃជីវិតគួរឧទ្ទិសចំពោះការសិក្សា ។
  - ✶ ១ភាគ៣ បន្ទាប់ទៀតនៃជីវិតឧទ្ទិសចំពោះការកសាងអាជីព និងការចិញ្ចឹមជីវិត ។
  - ✶ ១ភាគ៣ ចុងក្រោយនៃជីវិត គឺឧទ្ទិសចំពោះការផ្តល់ដល់អ្នកដទៃ ដោយបង្វិលត្រឡប់វិញនូវអ្វីជាការដឹងគុណ ។
  - ✶ ស្ថានភាពនីមួយៗហាក់ដូចជាការរៀបចំមួយសម្រាប់ស្ថានភាពមួយទៀត ។
- ប្រសិនបើអ្នកមានជោគជ័យ វាអាចមានលទ្ធភាពសម្រាប់អ្នកបន្សល់ទុកនូវមរតក (An inheritance) សម្រាប់អ្នកដទៃ ។
  - ✶ ប៉ុន្តែបើអ្នកចង់ធ្វើឲ្យបានច្រើនទៀតដើម្បីបង្កើតជាកេរ្តិ៍ដំណែល (Legacy) ដូច្នេះអ្នកចាំបាច់បន្សល់នូវរឿងនោះនៅក្នុងខ្លួនអ្នកដទៃ ។
  - ✶ កាលណាអ្នកគិតដោយមិនអាត្មានិយម ហើយវិនិយោគនៅក្នុងខ្លួនអ្នកដទៃ អ្នកទទួលបានឱកាសដើម្បីបង្កើតនូវកេរ្តិ៍ដំណែលដែលនឹងធ្វើឲ្យជីវិតអ្នករស់រវើក ។

# តើត្រូវពិសោធន៍អំពីការពេញចិត្តចំពោះការគិតដោយមិនអាត្មានិយមយ៉ាងដូចម្តេច?

- មនុស្សជាច្រើនវង្វេងកាលណានិយាយអំពីការផ្លាស់ប្តូរនូវការគិតរបស់ពួកគេ ។
  - ✶ ដើម្បីបណ្តុះនូវការគិតដោយមិនអាត្មានិយម ត្រូវធ្វើតាមជំហានដូចតទៅ ÷

## ១_ដាក់អ្នកដទៃជាទី១

- ដំណើរការចាប់ផ្តើមជាមួយការទទួលយល់ដឹងថា អ្វីៗទាំងអស់ពុំមែនសម្រាប់ខ្លួនអ្នកទេ ។ ប្រការនេះទាមទារនូវការដាក់ខ្លួន (Humility) និងការផ្ទេរការយកចិត្តទុកដាក់ (A shift in focus)។
  - ✶ លោក Ken Blanchard និង Norman Vincent សរសេរថា : "មនុស្សដែលដាក់ខ្លួនពុំមែនគិតតិចចំពោះខ្លួនឯងទេ ។ ពួកគេគ្រឹមតែគិតអំពីខ្លួនឯងតិច" ។
  - ✶ ប្រសិនបើអ្នកចង់ក្លាយជាអ្នកមិនសូវអាត្មានិយមនៅក្នុងការគិតរបស់អ្នក អ្នកចាំបាច់ត្រូវបញ្ឈប់ការគិតចំពោះបំណងរបស់ខ្លួនឯង ហើយចាប់ផ្តើមយកចិត្តទុកដាក់អំពីសេចក្តីត្រូវការរបស់អ្នកដទៃ ។
  - ✶ សូមកុំធ្វើអ្វីចេញពីមហិច្ឆិតាអាត្មានិយម (Selfish ambition) ឬក៏មោទនភាពអត់បានការ (Vain conceit) ប៉ុន្តែក្នុងនាមជាមនុស្សជាតិ (Humanity) សូមគិតគូរអ្នកដទៃឲ្យបានល្អប្រសើរជាងខ្លួនឯងផ្ទាល់ ។
  - ✶ ខ្លួនយើងម្នាក់ៗកុំមើលឃើញតែផលប្រយោជន៍ផ្ទាល់ខ្លួន សូមមើលឃើញផលប្រយោជន៍អ្នកដទៃផងដែរ ។
  - ✶ សូមតាំងប្រាជ្ញាស្មារតី ដើម្បីគិតគូរអំពីផលប្រយោជន៍របស់អ្នកដទៃ (ផលប្រយោជន៍ខ្លួនឯងជាលោហធាតុមុខ ឯផលប្រយោជន៍អ្នកដទៃជាលោហធាតុក្រោយ ។

## ២_ដាក់ខ្លួនឯងនៅក្នុងស្ថានការណ៍ដែលមនុស្សមានតម្រូវការ

- មានរឿងមួយដែលអ្នកមានជំនឿថា អ្នកចង់ផ្តល់ដោយមិនអាត្មានិយម ។
- មានរឿងមួយទៀត តើធ្វើយ៉ាងដូចម្តេច ។
- ដើម្បីធ្វើដំណើរការអន្តរកាល អ្នកចាំបាច់ត្រូវដាក់ខ្លួនឯងទៅក្នុងស្ថានការណ៍ណាមួយដែលអ្នកអាចមើលឃើញនូវសេចក្តីត្រូវការរបស់មនុស្ស ហើយអ្នកធ្វើអ្វីមួយចំពោះរឿងនេះ ។

✶ ប្រភេទនៃការផ្តល់ដែលអ្នកធ្វើពុំមែនសំខាន់ជាទី១ឡើយ ។ អ្នកអាចបរិច្ចាគវត្ថុ ធ្វើទានជាចំណីអាហារ ស្ម័គ្រចិត្តធ្វើសេវាវិជ្ជាជីវៈ ឬក៏ផ្តល់វិភាគទានដល់អង្គការសប្បុរសធម៌ ។

✶ ចំណុចដែលសំខាន់គឺរៀនថា តើត្រូវផ្តល់ និងបណ្តុះនូវទម្លាប់នៃការគិតជារបៀបអ្នកផ្តល់យ៉ាងដូចម្តេច ។

## ៣_ផ្តល់ដោយស្ងប់ស្ងាត់ ឬជាអនាមិក

- ពេលអ្នកបានរៀនចេះអំពីការផ្តល់ដោយខ្លួនឯងរួចហើយ នោះជំហានបន្ទាប់គឺត្រូវរៀនផ្តល់ កាលណាអ្នកពុំអាចទទួលអ្វីទាំងអស់ជាត្រឡប់វិញ ។

✶ ជានិច្ចកាល វាមានភាពងាយស្រួលជាងក្នុងការផ្តល់ កាលណាអ្នកទទួលបាននូវការទទួលស្គាល់សម្រាប់រឿងនេះ ជាងកាលណាគ្មាននរណាម្នាក់បានដឹងអំពីរឿងនេះ ។

✶ មនុស្សដែលផ្តល់ដើម្បីបានទទួលនូវភ្លេងសារទរ (Fanfare) បានទទួលរួចហើយនូវរង្វាន់ដែលពួកគេនឹងទទួល ។

✶ គឺមានជាផលប្រយោជន៍ខាងស្មារតី(Spiritual) ប្រាជ្ញា(Mental) និងអារម្មណ៍ (Emotional benefits) ដែលមានចំពោះតែមនុស្សដែលផ្តល់ដោយអនាមិក ។

✶ បើអ្នកដែលបានសាកល្បង សូមសាកល្បងមើល ។

## ៤-វិនិយោគដោយមានឆន្ទៈទៅក្នុងមនុស្ស

- កំរិតដ៏ខ្ពស់បំផុតនៃការគិតដោយមិនអាត្មានិយមបេញមក កាលណាអ្នកខិតខំដោយខ្លួនឯងដើម្បីមនុស្សម្នាក់ទៀត ដើម្បីការអភិវឌ្ឍផ្ទាល់ខ្លួន (Personal development) ឬសុខុមាលភាព (Well-being) ។

    ✶ ប្រសិនបើអ្នកបានរៀបការ ឬក៏ជាឪពុក អ្នកនឹងដឹងរឿងនេះដោយបទពិសោធន៍ផ្ទាល់ខ្លួន ។

    ✶ តើមានអ្វីខ្លះដែលប្រពន្ធអ្នកវាយតម្លៃខ្ពស់បំផុតនោះ? លុយនៅក្នុងធនាគារ ឬពេលវេលាទំនេរដែលត្រូវផ្តល់? តើកូនតូចៗរបស់អ្នកចង់បានបំផុតពីអ្នកជាអ្វី? តុក្កតា? ឬក៏ការយកចិត្តទុកដាក់អត់បែងចែករបស់អ្នក?

    ✶ មនុស្សដែលស្រឡាញ់អ្នកចង់បានអ្នកច្រើនជាងអ្វីដែលអ្នកអាចផ្តល់ឲ្យពួកគេ ។

- ប្រសិនបើអ្នកចង់ក្លាយទៅជាប្រភេទមនុស្សដែលវិនិយោគទៅក្នុងមនុស្ស នោះសូមយកចិត្តទុកដាក់លើអ្នកដទៃ និងដំណើររបស់ពួកគេ (Journey) ដើម្បីអ្នកអាចសហការជាមួយពួកគេ ។

    ✶ រាល់ទំនាក់ទំនង វាហាក់ដូចជាភាពជាដៃគូដែលបង្កើតឡើងសម្រាប់ផលប្រយោជន៍ទៅវិញទៅមក ។

    ✶ កាលណាអ្នកដើរចូលទៅកាន់ទំនាក់ទំនងណាមួយ សូមគិតថាតើអ្នកអាចវិនិយោគទៅក្នុងមនុស្សដទៃទៀត ដើម្បីប្រែក្លាយទៅជាស្ថានការណ៍ឈ្នះ-ឈ្នះ ។

    ✶ ខាងក្រោមនេះបង្ហាញថា តើទំនាក់ទំនងជាភាគច្រើនញឹកញាប់កើតឡើងយ៉ាងដូចម្តេចនោះ :

ខ្ញុំឈ្នះ អ្នកចាញ់ → ខ្ញុំឈ្នះតែម្តងគត់

អ្នកឈ្នះ ខ្ញុំចាញ់ → អ្នកឈ្នះតែម្តងគត់

យើងទាំងពីរនាក់ឈ្នះ → យើងឈ្នះច្រើនដង

យើងទាំងពីរនាក់ចាញ់ → សូមលាចប់ភាពជាដៃគូ

- ទំនាក់ទំនងដែលល្អប្រសើរបំផុតគឺ ឈ្នះ-ឈ្នះ ។ តើហេតុដូចម្ដេចបានជាមនុស្សជាច្រើនពុំបានចូលទៅកាន់ទំនាក់ទំនងដោយប្រើគំរិយាបថនេះ ?
    - ✶ មនុស្សជាភាគច្រើនចង់បានច្បាស់លាស់ថា ពួកគេជាអ្នកឈ្នះមុនគេបង្អស់ ។
    - ✶ អ្នកគិតដោយមិនអាត្មានិយម ផ្ទុយទៅវិញចូលទៅកាន់ទំនាក់ទំនងណាមួយដោយច្បាស់ថា មនុស្សម្នាក់ទៀតជាអ្នកឈ្នះមុនគេ ។ នេះហើយដែលធ្វើឲ្យមានភាពខុសគ្នា ។

## ៥-សូមត្រួតពិនិត្យមើលនូវហេតុផលរបស់អ្នក (Motives)

- តើអ្វីខ្លះដែលមើលឃើញទៅហាក់ដូចជាភាពសប្បុរសធម៌ (Generosity) ភាគច្រើនគ្មានអ្វីក្រៅពីមហិច្ឆិតាក្លែងក្លាយ ដែលមើលឃើញផលប្រយោជន៍តូចតាចធ្វើជារឿងធំ ដើម្បីការពារនូវផលប្រយោជន៍ដ៏ធំមួយ ?
    - ✶ រឿងដែលពិបាកសម្រាប់មនុស្សជាច្រើន គឺការប្រយុទ្ធទៅនឹងនិន្នាការធម្មជាតិរបស់ខ្លួន ដែលដាក់ខ្លួនឯងជាអាទិភាពទី១ ។
    - ✶ ហេតុនេះបានជាវាសំខាន់ ដើម្បីពិនិត្យខ្លួនអ្នកជាបន្តបន្ទាប់កុំឲ្យហេតុផលរបស់អ្នកវិលត្រឡប់ថយក្រោយទៅរកភាពអាត្មានិយមឡើងវិញ ។
- តើអ្នកចង់ពិនិត្យមើលហេតុផលរបស់អ្នកដែរឬទេ ?
    - ✶ ជារៀងរាល់ថ្ងៃ អ្នកត្រូវសាកសួរខ្លួនឯងពីរសំណួរ :
        - ◈ តើអ្វីល្អខ្លះដែលខ្ញុំត្រូវធ្វើក្នុងថ្ងៃនេះ ? (ពេលព្រឹក)
        - ◈ តើអ្វីល្អខ្លះដែលខ្ញុំបានធ្វើក្នុងថ្ងៃនេះ ? (ពេលចូលដេក)
    - ✶ ប្រសិនបើអ្នកអាចឆ្លើយសំណួរទាំងពីរនេះដោយជឿជាក់ច្បាស់លាស់ (Selflessness) និងសុចរិតភាព (Integrity) អ្នកអាចថែរក្សាខ្លួនឯងនៅក្នុងផ្លូវត្រូវ ។

## សូមផ្តល់ពេលដែលអ្នករស់នៅ

✶ យើងអាចជាអ្នកគិតមិនអាត្មានិយមដែលដាក់អ្នកដទៃជាអាទិភាពទី១ និងផ្តល់តម្លៃដល់ជីវិតរបស់ពួកគេ ។

- អ្នកអាចធ្វើការជាមួយពួកគេដើម្បីឲ្យពួកគេដើរទៅមុខបានឆ្ងាយ ជាងអ្វីដែលពួកគេគិតថាមានលទ្ធភាព ។ ឧទាហរណ៍ : អ្នកពន្លត់ភ្លើងកាលព្រឹត្តិការណ៍ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០១ ។

×

× ×

# ជំពូកទី១១
# សូមផ្អែកលើការគិតឈរលើមូលដ្ឋានគ្រឹះ
# RELY ON BOTTOM-LINE THINKING

- នៅកន្លែងនេះពុំមានច្បាប់អនុញ្ញាតឡើយ ។ យើងសាកល្បងសម្រេចអ្វីៗមួយចំនួន ។
  - ✶ តើអ្នករកឃើញនូវមូលដ្ឋានគ្រឹះសម្រាប់ស្ថាប័ន, ធុរកិច្ច, នាយកដ្ឋាន, ក្រុមការងារ ឬក្រុមយ៉ាងដូចម្តេច?
  - ✶ ផលចំណេញ (Profit) កំណត់ថាតើអ្នកជោគជ័យដែរឬអត់ ។ ប៉ុន្តែប្រាក់ដុល្លាពុំមែនសុទ្ធតែជារង្វាស់បឋមសម្រាប់ជោគជ័យឡើយ ។
  - ✶ តើអ្នកវាស់វែងជោគជ័យរបស់គ្រួសារអ្នកតាមរយៈទឹកប្រាក់ដែលអ្នកមាននៅចុងខែ ឬក៏ឆ្នាំដែរឬទេ ?
  - ✶ ប្រសិនបើអ្នកជាស្ថាប័នមិនរកចំណេញ ឬស្ម័គ្រចិត្ត តើអ្នកមានស្នាដៃក្នុងសក្តានុពលខ្ពស់របស់អ្នកបានយ៉ាងដូចម្តេច? តើអ្នកគិតអំពីមូលដ្ឋានគ្រឹះនៅក្នុងស្ថានការណ៍នេះយ៉ាងដូចម្តេច?

## <u>មូលដ្ឋានគ្រឹះនៃការមិនរកផលចំណេញ (A Non-Profits Bottom Line)</u>

- អង្គការសប្បុរសធម៌ឈរលើមូលដ្ឋានគ្រឹះដែលពុំវាស់វែងដោយទឹកប្រាក់ដុល្លា ប៉ុន្តែវាស់វែងជាការផ្លាស់ប្តូរជីវិត (In changed lives) ។

## <u>តើហេតុដូចម្តេចបានយើងត្រូវរីករាយជាមួយនឹងលទ្ធផលនៃការគិតឈរលើមូលដ្ឋានគ្រឹះ</u>

- ប្រសិនបើអ្នកមានទម្លាប់នៃការគិតឈរលើមូលដ្ឋានគ្រឹះ តែតាមការពាក់ព័ន្ធទៅនឹងផ្នែកហិរញ្ញវត្ថុនោះ នោះអ្នកនឹងបាត់បង់នូវរបស់សំខាន់មួយចំនួនដល់ខ្លួនអ្នក និងស្ថាប័នរបស់

អ្នក ។

✶ ជាជំនួសវិញ សូមគិតឈរលើមូលដ្ឋានគ្រឹះធ្វើជាទីបញ្ចប់ (The end) ជាម្ហូបយកតាមខ្លួន (The take away) ជាលទ្ធផលដែលចង់បាន (The desired results) ។

✶ សកម្មភាពនីមួយៗមានមូលដ្ឋានគ្រឹះដោយឡែកផ្ទាល់ ។

✶ ប្រសិនបើអ្នកមានមុខការធ្វើ ការងាររបស់អ្នកគឺជាមូលដ្ឋានគ្រឹះ ។

✶ ប្រសិនបើអ្នកបំរើនៅវត្ត សកម្មភាពរបស់អ្នកមានមូលដ្ឋានគ្រឹះ ក៏ដូចជាការទិតទំរបស់អ្នកជាឪពុកម្តាយ ជាភរិយា.....ដូច្នេះដែរ ។

## **១.ការគិតឈរលើមូលដ្ឋានគ្រឹះផ្តល់នូវភាពច្បាស់លាស់ជាក់ស្តែង (Great Clarity)**

- តើមានភាពខុសគ្នាដូចម្តេចរវាងការលេងប៊ូល និងការធ្វើការ?

✶ កាលណាលេងប៊ូល វាប្រើពេលត្រឹមតែ ៣វិនាទីប៉ុណ្ណោះដើម្បីដឹងថា តើអ្នកសម្រេចបានលទ្ធផល ឬអត់? នេះគឺជាមូលហេតុមួយដែលមនុស្សស្រឡាញ់កីឡាយ៉ាងច្រើន ។ ពុំមានការរង់ចាំ និងការទស្សន៍ទាយអំពីលទ្ធផលដែលចេញមក (The outcome)។

- ការគិតឈរលើមូលដ្ឋានគ្រឹះ ធ្វើឱ្យអ្នកមានលទ្ធភាពវាស់វែងអំពីផលសម្រេច (Outcome) បានលឿន និងដោយងាយស្រួលច្រើនជាង ។

✶ វាផ្តល់ដល់អ្នកនូវសន្ទស្សន៍មួយ (Benchmark) ដែលអ្នកប្រើប្រាក់សម្រាប់វាស់វែងសកម្មភាព ។

✶ ការគិតឈរលើមូលដ្ឋានគ្រឹះអាចយកទៅប្រើប្រាស់ធ្វើជាវិធីប្រមូលផ្តុំ(A focused way) ដើម្បីធានាថា សកម្មភាពតូចតាចរបស់អ្នកមានគោលបំណង (Purposeful) ហើយបន្តគ្នាដើម្បីសម្រេចនូវគោលដៅធំជាងនោះរបស់អ្នក (A larger goal)។

## ២.ការគិតឈរលើមូលដ្ឋានគ្រឹះជួយឱ្យអ្នកវាយតម្លៃបានអំពីស្ថានការណ៍នីមួយៗ

- កាលណាអ្នកដឹងអំពីមូលដ្ឋានគ្រឹះរបស់អ្នក វាមានភាពងាយស្រួលដើម្បីបានដឹងថាតើអ្នកកំពុងធ្វើអ្វីនៅក្នុងវិស័យណាមួយនោះ (Any given area) ។
  - ✶ អង្គការនារីសប្បុរសធម៌វាស់វែងអ្វីៗទៅនឹងគោលដៅរបស់ស្ថាប័ន ដើម្បីជួយនារីណាម្នាក់ឱ្យបានសម្រេចបាននូវសក្ដានុពលខ្ពស់របស់ខ្លួន (មានឋានៈ តួនាទី និងចំណូលខ្ពស់) ÷ គ្មានអ្វីជារង្វាស់ដែលប្រសើរជាងមូលដ្ឋានគ្រឹះឡើយ ។

## ៣.ការគិតឈរលើមូលដ្ឋានគ្រឹះជួយអ្នកឱ្យធ្វើសេចក្ដីសម្រេចដ៏ល្អប្រសើរបំផុត

- សេចក្ដីសម្រេចនឹងកាន់តែងាយស្រួល កាលណាអ្នកបានដឹងអំពីមូលដ្ឋានគ្រឹះរបស់អ្នក ។

## ៤.ការគិតឈរលើមូលដ្ឋានគ្រឹះបង្កើតឡើងនូវសីលធម៌ខ្ពស់

- កាលណាអ្នកបានដឹងអំពីមូលដ្ឋានគ្រឹះរបស់អ្នក ហើយដើរតាមមូលដ្ឋានគ្រឹះនោះ អ្នកនឹងបង្កើនខ្លាំងក្លានូវសក្ដានុពលដើម្បីជោគជ័យ ។
  - ✶ គ្មានអ្វីបង្កើតបាននូវសីលធម៌ខ្ពស់ដូចបានទទួលជោគជ័យឡើយ ។
  - ✶ ក្រុមកីឡាដែលទទួលបានជើងឯក ឬក៏ផ្នែករបស់ក្រុមហ៊ុនដែលសម្រេចបាននូវគោលដៅរបស់ខ្លួន ឬក៏អ្នកស្ម័គ្រចិត្តដែលសម្រេចបាននូវបេសកកម្មរបស់ខ្លួនពួកគេរំភើបរីករាយ ។
- បាញ់តម្រង់ឱ្យបានចំគោលដៅ (Hitting the target) ធ្វើឱ្យអារម្មណ៍រីករាយណាស់ ។ តែអ្នកបាញ់តម្រង់ចំបាន លុះណាតែអ្នកដឹងថាអ្វីទៅជាគោលដៅនោះ ។

## ៥.ការគិតឈរលើមូលដ្ឋានគ្រឹះធានានូវអនាគតរបស់អ្នក

- ប្រសិនបើអ្នកចង់ទទួលបានជោគជ័យនៅថ្ងៃស្អែក អ្នកត្រូវគិតដោយឈរលើមូលដ្ឋានគ្រឹះនាថ្ងៃនេះ ។
  - ✶ ក្រុមហ៊ុនណាមួយដែលទទួលបានជោគជ័យយូរអង្វែង អ្នកនឹងរកឃើញថា អ្នកដឹកនាំក្រុមហ៊ុនទាំងនោះបានដឹងអំពីមូលដ្ឋានគ្រឹះរបស់ខ្លួន ។

★ ពួកគេធ្វើសេចក្ដីសម្រេចបែងចែកធនធាន ជ្រើសរើសបុគ្គលិក និងរៀបចំរចនាសម្ព័ន្ធរបស់ពួកគេដើម្បីសម្រេចបាននូវមូលដ្ឋានគ្រឹះ ។

- វាប្រាកដជាពិបាកដើម្បីមើលឃើញអំពីតម្លៃនៃមូលដ្ឋានគ្រឹះ ។
- មនុស្សជាច្រើនឯកភាពថា ការគិតឈរលើមូលដ្ឋានគ្រឹះនាំឲ្យមានលទ្ធផលត្រឡប់មកវិញខ្ពស់ ។

★ ប៉ុន្តែការរៀនថាតើក្លាយខ្លួនជាអ្នកគិតឈរលើមូលដ្ឋានគ្រឹះយ៉ាងដូចម្ដេច គឺជាការប្រឈមមួយ ។

## ❶ សូមកំណត់អំពីមូលដ្ឋានគ្រឹះជាក់ស្ដែង (The Real Bottom Line)

- ដំណើរការនៃការគិតលើមូលដ្ឋានគ្រឹះ ចាប់ផ្ដើមជាមួយនឹងអ្វីដែលកំពុងដើរស្វះស្វែងរកពិតប្រាកដ ។

★ វាអាចខ្ពស់ត្រដែតដូចជាចក្ខុវិស័យក្ដោបរូបភាពធំ (Big-picture vision) បេសកកម្ម (Mission) ឬគោលបំណង (Purpose) របស់ស្ថាប័នណាមួយ ។

★ ឬវាអាចត្រូវប្រមូលផ្ដុំយកចិត្តទុកដាក់ដូចជាអ្វីដែលអ្នកចង់សម្រេចបានពីក្នុងគម្រោងការណាមួយ ។

★ អ្វីដែលសំខាន់នោះ សម្រាប់អ្នកនោះគឺត្រូវជាក់ស្ដែងបំផុត (As specific as possible)។

- ប្រសិនបើគោលដៅ(Goal)របស់អ្នកគឺជាអ្វីមិនច្បាស់លាស់ដូចជា "ជោគជ័យ" អ្នកនឹងមានពេលវេលាដ៏សែនពិបាកដើម្បីទិតខំទទួលបានលទ្ធផលពីការគិតឈរលើមូលដ្ឋានគ្រឹះដើម្បីសម្រេចវាឲ្យបាន ។
- ជំហានទី១ គឺដាក់ "បំណង Wants" របស់អ្នកដោយឡែក ។ សូមចាប់យកលទ្ធផលដែលអ្នកខិតខំសម្រេចឲ្យបាន ដែលជាខ្លឹមសារពិតប្រាកដនៃគោលដៅរបស់អ្នក ។

★ សូមទម្លាក់ចោលឲ្យឆ្ងាយនូវការរំភើបចិត្តរបស់អ្នក ដែលអាចរារាំងដល់សុភិ-

និច្ច័យ (Judgement)របស់អ្នក ហើយដកចេញនូវនយោបាយណាមួយ (Politics) ដែលអាចមានឥទ្ធិពលដល់ការយល់ឃើញ (Perception) របស់អ្នក ។

* តើអ្វីខ្លះទៅជាពិតប្រាកដដែលអ្នកខិតខំចង់សម្រេចឱ្យបាន ។
* កាលណាអ្នកជម្រុះចេញឱ្យឆ្ងាយនូវរបស់ទាំងអស់ដែលជាពិតប្រាកដមិនសំខាន់ តើអ្វីខ្លះដែលជម្រុញអ្នកដើម្បីសម្រេចឱ្យបាន? តើអ្វីខ្លះត្រូវកើតឡើង? តើអ្វីខ្លះដែលអាចទទួលយកបាន? នោះហើយគឺជាមូលដ្ឋានគ្រឹះពិតប្រាកដ ។

## ❷ សូមដាក់មូលដ្ឋានគ្រឹះជាចំណុចគន្លឹះ

- តើអ្នកធ្លាប់បានសន្ទនាជាមួយនរណាម្នាក់ដែលមានគោលបំណង (Intentions) ហាក់ដូចជានៅក្រៅពីអ្វីដែលបាននិយាយរួចហើយ ?
  * ពេលខ្លះ ស្ថានការណ៍នេះច្បះបញ្ជាំងឱ្យឃើញនូវការខកចិត្ត (Intentional deception) ។
  * តែវាអាចកើតឡើង កាលណាមនុស្សនោះពុំបានដឹងអំពីមូលដ្ឋានគ្រឹះរបស់ខ្លួន ។
  * រឿងដដែលនេះកើតឡើងនៅក្នុងក្រុមហ៊ុន ជាឧទាហរណ៍ បេសកកម្មដែលបានបញ្ជាក់ជាឧត្តមគតិ (An idealistically stated mission) និងមូលដ្ឋានគ្រឹះពិតប្រាកដ (The real bottom-line) ពុំស្របគ្នា ។ គោលបំណង និងផលប្រយោជន៍ប្រកួតប្រជែងគ្នា ។
  * យើងខិតខំដើម្បីកុំឱ្យភ្លេចទាល់តែសោះថា ឱសថគឺសម្រាប់មនុស្ស ។ វាពុំមែនដើម្បីផលប្រយោជន៍ទេ ។ ផលប្រយោជន៍មកតាមក្រោយ ។ ប្រសិនបើយើងចងចាំរឿងនេះជាប់ជានិច្ចនោះ ផលប្រយោជន៍ពិតជាមិនខកខាននឹងកើតឡើងឡើយ ។ នេះជារឿងដែលត្រូវចងចាំសម្រាប់ស្ថាប័ន ÷ ផលប្រយោជន៍បំរើគោលបំណង (Profits serve purpose) ផលប្រយោជន៍ពុំប្រកួតប្រជែងជាមួយគោលបំណងឡើយ ។

* ប្រសិនបើផលប្រយោជន៍ (Profit) គឺជាមូលដ្ឋានគ្រឹះនោះ ការជួយមនុស្សគ្រាន់តែជាមធ្យោបាយដើម្បីសម្រេចផលប្រយោជន៍តែប៉ុណ្ណោះ ។ ក្រុមហ៊ុនមុខតែរងគ្រោះ ។ គោលបំណងរបស់ក្រុមហ៊ុនត្រូវបែងចែក វាពុំអាចជួយមនុស្សហើយក៏ពុំអាចសម្រេចបាននូវផលប្រយោជន៍ដូចដែលចង់បាននោះ ។

❸ ~ **<u>បង្កើតផែនការយុទ្ធសាស្ត្រដើម្បីសម្រេចមូលដ្ឋានគ្រឹះ</u>**

- ការគិតលើមូលដ្ឋានគ្រឹះធ្វើឱ្យសម្រេចលទ្ធផល
  * ដូច្នេះត្រូវមានជំហាន : ផែនណាមួយដែលចេញពីការគិតបែបនេះត្រូវផ្សារភ្ជាប់ទៅនឹងមូលដ្ឋានគ្រឹះ ។ វាអាចមានត្រឹមតែមួយប៉ុណ្ណោះ ឬក៏ពីរ ឬបី (មូលដ្ឋានគ្រឹះ) ។
  * ពេលដែលមូលដ្ឋានគ្រឹះត្រូវបានកំណត់រួចហើយ យុទ្ធសាស្ត្រមួយត្រូវបានបង្កើតឡើងដើម្បីសម្រេចវា ។
  * នៅក្នុងស្ថាប័ន មានន័យថា ការកំណត់អំពីអង្គធាតុសំខាន់ៗ (Core elements) ឬមុខងារ (Functions) ដែលត្រូវប្រតិបត្តិការឱ្យបានត្រឹមត្រូវ ដើម្បីសម្រេចឱ្យបាននូវមូលដ្ឋានគ្រឹះ ។
- របស់ដែលសំខាន់គឺថា កាលណាមូលដ្ឋានគ្រឹះនៃសកម្មភាពនីមួយៗត្រូវសម្រេចបាននោះ ដូច្នេះមូលដ្ឋានគ្រឹះត្រូវសម្រេចបានដែរ ។
  * ប្រសិនបើផលបូកនៃគោលដៅតូចៗពុំបានបំពេញបន្ថែមទៅលើមូលដ្ឋានគ្រឹះពិតប្រាកដទេនោះ ផែនការយុទ្ធសាស្ត្ររបស់អ្នកមានខ្វះចន្លោះ (Flawed) ឬក៏អ្នកពុំបានកំណត់អំពីមូលដ្ឋានគ្រឹះពិតប្រាកដរបស់អ្នក ។

❹ ~ **<u>សូមតម្រង់ជួរសមាជិកក្រុមការងារជាមួយនឹងមូលដ្ឋានគ្រឹះ</u>**

- កាលណាអ្នកមានយុទ្ធសាស្ត្រក្នុងដៃរួចហើយនោះ សូមធានាឱ្យជាក់ច្បាស់ថា មនុស្សរបស់អ្នកឈរតម្រង់ជួរជាមួយនឹងយុទ្ធសាស្ត្ររបស់អ្នកនោះ ។

★ ជាប្រសើរបំផុត សមាជិកក្រុមការងារទាំងអស់ត្រូវដឹងអំពីគោលដៅ (Big goal) ព្រមទាំងតួនាទីរបស់បុគ្គលម្នាក់ៗដើម្បីសម្រេចគោលដៅនោះ ។ ពួកគេត្រូវដឹងមូលដ្ឋានគ្រឹះផ្ទាល់ខ្លួនម្នាក់ៗរបស់ពួកគេ ហើយតើមូលដ្ឋានគ្រឹះផ្ទាល់ខ្លួនរបស់ពួកគេត្រូវធ្វើយ៉ាងដូចម្ដេចដើម្បីសម្រេចឲ្យបាននូវមូលដ្ឋានគ្រឹះរបស់ស្ថាប័ន ។

## ❺ ~ ប្រកាន់ខ្ជាប់ស្ថិតជាមួយប្រព័ន្ធតែមួយ និងតាមដានលទ្ធផលជាប់ជាបន្តបន្ទាប់

- ស្ថាប័នមួយចំនួនដើរចូលកលិយុគ(Trouble) ដោយខិតខំសាកល្បងនូវប្រព័ន្ធចម្រុះ (Mix systems)។ ពួកគេរក្សាដដែលនូវប្រព័ន្ធជាច្រើនប្រភេទ ដែលអាចនាំមកនូវជោគជ័យ ។

★ ប៉ុន្តែការលាយគ្នានូវប្រព័ន្ធខុសប្លែកគ្នា ឬក៏ផ្លាស់ប្ដូរជាបន្តបន្ទាប់ពីប្រព័ន្ធមួយទៅកាន់ប្រព័ន្ធមួយទៀត នាំទៅដល់បរាជ័យ ។

★ ការគិតលើមូលដ្ឋានគ្រឹះពុំអាចរបស់តែមួយលើកឡើយ (A one-time thing) ÷ វាត្រូវកសាងឡើងនៅក្នុងប្រព័ន្ធការងារ និងទំនាក់ទំនង ព្រមទាំងសម្រេចលទ្ធផល (The system of working and relating and achieving)។

★ អ្នកពុំអាចត្រឹមតែសម្របទៅនឹងលទ្ធផលចង់បានពេលនេះ និងពេលក្រោយប៉ុណ្ណោះទេ ។ ការសម្រេចបានលទ្ធផលជាមួយនឹងការគិតលើមូលដ្ឋានគ្រឹះ គឺជាទម្លាប់នៃជីវិត (A way of life) ឬក៏នឹងផ្ញើចេញនូវសារបម្លែងចម្រាស់ (Conflicting messages) ។

★ បើអ្នកជាអ្នកគិតលើមូលដ្ឋានគ្រឹះ វាជាផ្នែកមួយនៃប្រព័ន្ធរបស់អ្នកដើម្បីសម្រេចបានលទ្ធផល ។ អ្នកអនុវត្តជារៀងរាល់ថ្ងៃ ។ គ្មានវង្វាស់ដទៃទៀត គ្មានការខិតខំអត់បានការ ។

★ សម្រាប់ក្រុមហ៊ុនត្រូវសាកសួរសំណួរអំពីមូលដ្ឋានគ្រឹះជារៀងរាល់ថ្ងៃ (The bottom-line question) ដើម្បីពឹងទុកអំពីលទ្ធផល ។ អ្នកត្រូវតាមមើលជាប់នូវមូលដ្ឋានគ្រឹះរបស់ក្រុមហ៊ុន ដោយតាមដានមើលនូវវិស័យសំខាន់នីមួយៗ ។

- មិនថាអ្វីជាមូលដ្ឋានគ្រឹះរបស់អ្នក អ្នកអាចធ្វើឲ្យមូលដ្ឋានគ្រឹះនេះកាន់តែល្អប្រសើរតាមរយៈការគិត ។
- ការគិតលើមូលដ្ឋានគ្រឹះនាំឲ្យមានលទ្ធផលដ៏ធំធេង វាជួយអ្នកឲ្យប្រែក្លាយគំនិតរបស់អ្នកជាលទ្ធផល ។
- វាដូចជាដំណើរការស្មារតី(Mental process) ផ្សេងទៀត តែវាអាចជួយអ្នកឲ្យមានសក្តានុពលខ្លាំងក្លាក្នុងការគិត ហើយសម្រេចបាននូវអ្វីដែលអ្នកចង់បាននោះ ។

×

× ×

# គំនិតមួយចុងក្រោយ

- សូមចងចាំ ÷

## ១_អ្វីៗចាប់ផ្តើមជាមួយការគិត

- លោក Ralph Waldo Emerson ÷ ជីវិតតែងផ្គុំឡើងដោយអ្វីដែលមនុស្សម្នាក់កំពុងគិតជារៀងរាល់ថ្ងៃ ។

## ២_អ្វីដែលយើងគិតជាកំណត់ថា តើយើងជានរណា តើយើងជានរណា ជាកំណត់នូវអ្វីដែលយើងធ្វើ

- អំពើរបស់មនុស្សគឺជាអ្នកកែប្រែដ៏ល្អប្រសើរអំពីការគិតរបស់មនុស្សនោះ (លោក John Locke) ។

## ៣_គំនិតរបស់យើងកំណត់នូវជោគវាសនារបស់យើង ជោគវាសនារបស់យើងកំណត់នូវមរតករបស់យើង

- អ្នកនៅកន្លែងនេះថ្ងៃនេះ ជាកន្លែងដែលគំនិតរបស់អ្នកបាននាំអ្នកទៅដល់ អ្នកនៅកន្លែងថ្មីថ្ងៃស្អែក ជាកន្លែងដែលគំនិតរបស់អ្នកនឹងនាំអ្នកទៅដល់ទីនោះ (លោក James Allen)

## ៤_មនុស្សដែលធ្វើដំណើរទៅកាន់កន្លែងខ្ពស់គិតខុសប្លែកពីអ្នកដទៃ

- គ្មានអ្វីដែលអាចកំរិតព្រំដែនដល់សមិទ្ធផលបានដូចការគិតតូចតាចឡើយ ។ គ្មានអ្វីដែលពង្រីកលទ្ធភាពនានាបានដូចការគិតអត់ព្រំដែនឡើយ (លោក (William Arthur Ward) ។

## ៥_យើងអាចផ្លាស់ប្តូរនូវវិធីដែលយើងគិត

- មិនថារបស់អ្វីដែលពិតប្រាកដ ថ្លៃថ្នូរ យុត្តិធម៌ បរិសុទ្ធ គួរឲ្យស្រឡាញ់ គឺជារបាយការណ៍ដ៏ល្អមួយ ។ ប្រសិនបើមានគុណធម៌ ហើយប្រសិនបើមានអ្វីមួយដែលថ្លៃថ្លានោះ សូមគិតអំពីរបស់ទាំងនោះ *(លោក Paul The Aposttle)*។

×

× ×